## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច


## សារណាបញ្ចប់ការសិក្សា

# ជំរុញការអភិវឌ្ឍកសិទេសចរណ៍

(ករណីសិក្សា តំបន់កោះឧកញ៉ាតី)

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ២០១៧


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **រន កុសមា**

**អឿន លក្ខិណា**

សាស្ត្រាចារ្យណែនាំ

លោក **ស៊ូ គឹមព្រឹទ្ធា**


ថ្នាក់បរិញ្ញាបត្រ ទេសចរណ៍ និងបដិសណ្ឋារកិច្ច
ជំនាន់ទី៣

ឆ្នាំចូលសិក្សា ២០១៣
ឆ្នាំសរសេរសារណា ២០១៧

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំ ក.អឿន លក្ខិណា និង ក.រន កុសមា ជានិស្សិតឆ្នាំទី៤ ជំនាន់ទី៣ ផ្នែកគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមធ្វើការថ្លែងអំណរអរគុណចំពោះលោក-អ្នកមានគុណទាំងឡាយ។

ជាដំបូងពួកយើងខ្ញុំទាំងអស់គ្នា សុំធ្វើការប្រណិបត្តចំពោះអ្នកមានគុណទាំងទ្វេរ ដែលបានផ្តល់កំណើត ព្រមទាំងខិតខំចិញ្ចឹមបីបាច់ថែរក្សាពួកយើងខ្ញុំទាំងអស់គ្នា តាំងពីតូចរហូតដល់ធំពេញវ័យ ប្រកបទៅដោយរូបសម្បត្តិសមរម្យ និងមានចំណេះដឹង។ ពួកយើងខ្ញុំទាំងអស់គ្នានឹងចងចាំមិនភ្លេចនូវរាល់ គុណដ៏ខ្ពង់ខ្ពស់ដែលមិនមានអ្វីអាចកាត់ថ្លៃបាន។

ជាងនេះទៅទៀត ពួកខ្ញុំក៏មិនអាចភ្លេចបានដែរនូវគុណរបស់លោកគ្រូ-អ្នកគ្រូ ព្រមទាំងលោកសាស្ត្រាចារ្យទាំងឡាយ ដែលបានខិតខំប្រឹងប្រែងបង្ហាត់បង្រៀនពួកយើងខ្ញុំរហូតដល់មានចំណេះដឹងដូចសព្វថ្ងៃនេះ។ ជាពិសេស លោកសាស្ត្រាចារ្យ **ស៊ូ គឹមព្រឹទ្ធា** ដែលលោកបានខិតខំប្រឹងប្រែងជួយជ្រោមជ្រែង និងដឹកនាំយើងខ្ញុំដើម្បីសរសេរសារណាមួយនេះ។

លើសពីនេះទៅទៀត ពួកយើងខ្ញុំ ក៏សូមសម្តែងនូវសេចក្តីថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅ ចំពោះលោកស្រីប្រធានមន្ទីទេសចរណ៍រាជធានីភ្នំពេញ លោកប្រធានភូមិ ឃុំ រួមទាំងប្រជាជនកសិករ អាជីវករ និងទេសចរទាំងអស់ដែលបានផ្តល់ឱកាស និងអនុញ្ញាតឲ្យពួកយើងខ្ញុំធ្វើការសម្ភាសន៍។

ជាចុងក្រោយ ពួកយើងខ្ញុំទាំងអស់គ្នា សូមលើកដៃប្រណម្យដោយសុទ្ធចិត្ត សូមឲ្យលោកអ្នកមានគុណទាំងឡាយជួបប្រទះតែនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

វិស័យទេសចរណ៍ ជាវិស័យសេដ្ឋកិច្ចដ៏សំខាន់មួយដែលសកលលោកបានផ្តោតការយកចិត្តទុកដាក់ ព្រោះថាវិស័យនេះ បាននាំមកនូវចំណូលជាតិ និង បង្កើតឱកាសការងារយ៉ាងច្រើនដល់ប្រជាពលរដ្ឋ ។ រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកវិស័យនេះជាមាសបៃតង និងជាការនាំចេញនៅនឹងកន្លែង ដែលបានចូលរួមចំណែក អភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម តាមរយៈការបង្កើតប្រាក់ចំណូលជូនជាតិ បង្កើតការងារ ជំរុញការវិនិយោគ និងចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ប្រទេសកម្ពុជា ជាប្រទេសមួយដែលមានសក្តានុពលធម្មជាតិ និងដីមានលក្ខណៈអំណោយផល ក្នុងការប្រកបរបរកសិកម្ម។ តាមការស្រាវជ្រាវបានឲ្យដឹងថា ៨០%នៃប្រជាជនកម្ពុជាសរុបប្រកបរបរកសិកម្ម ប៉ុន្តែក្រសួងទេសចរណ៍ និងស្ថាប័នពាក់ព័ន្ធមួយចំនួនពុំទាន់មានយកចិត្តទុកដាក់ខ្ពស់ក្នុងបង្កើត និងជម្រុញឲ្យមានការអភិវឌ្ឍទេសចរណ៍បែបកសិកម្មនោះទេ បើទោះបីជាក្នុងប្រទេសមានតំបន់ជាច្រើនមានសក្តានុពលអាចកែច្នៃឲ្យក្លាយជារមណីយដ្ឋានកសិទេសចរណ៍ក៏ដោយ។ កោះឧកញ៉ាតី ជាតំបន់មួយដែលស្ថិតនៅជិតរាជធានីភ្នំពេញ ដែលប្រមូលផ្តុំទៅប្រជាជនប្រកបមុខរបរកសិកម្ម ធ្វើចំការដាំដុះបន្លែផ្លែឈើ ។ កោះមួយនេះ គ្របដណ្តប់ដោយដើមឈើតូចធំជាច្រើនខៀវស្រងាត់ ព្រមទាំងមានទឹកទន្លេព័ទ្ធជុំវិញ និងជាតំបន់មួយដ៏មានលក្ខណៈល្អប្រសើរក្នុងការប្រកបរបរកសិកម្មរបស់អ្នកស្រុកនៅទីនោះ។

ដោយសារតែមើលឃើញពីចំណុចដែលល្អប្រសើរជាច្រើនទាក់ទងនិងតំបន់នេះទើបធ្វើឲ្យក្រុមយើងខ្ញុំសម្រេចចិត្ត លើកយកតំបន់នេះមកសិក្សាស្រាវជ្រាវ និងមានគំនិតក្នុងការជំរុញឲ្យក្លាយជារមណីយដ្ឋានកសិទេសចរណ៍ សម្រាប់ទេសចរជាតិ និងអន្តរជាតិមកកំសាន្ត និងស្នាក់នៅ ក្នុងតំបន់ធម្មជាតិមួយនេះ។ ក្នុងគោលបំណងជួយអភិរក្ស ព្រមទាំងអភិវឌ្ឍន៍ ដែលវាជាកត្តាមួយដ៏សំខាន់ក្នុងការលើកស្ទួយដល់កំរិតជីវភាពប្រជាពលរដ្ឋក្នុងតំបន់នោះ ឲ្យកាន់តែមានភាពល្អប្រសើរជាងនេះទៅទៀត។

តាមរយៈការសិក្សាស្រាវជ្រាវ ក៏ដូចជាការផ្តល់ជាមតិយោបល់ទាំងឡាយ យើងខ្ញុំ សង្ឃឹមថារាល់ពត៌មានទាំងឡាយដែលយើងខ្ញុំបានខិតខំប្រមូលផ្តុំ អាចចូលរួមជាគំនិតយោបល់មួយដ៏ល្អសម្រាប់យកទៅធ្វើការអភិវឌ្ឍតំបន់កោះឧកញ៉ាតី ឲ្យក្លាយជាតំបន់កសិទេសចរណ៍មួយដ៏ទាក់ទាញនាពេលអនាគត។ ដោយសារតែពេលវេលា នៃការចុះសរសេររបាយការណ៍មានពេលកំណត់ឬកើតឡើងដោយសារប្រការណាមួយនោះ។ យើងខ្ញុំរង់ចាំទទួលនូវការរិះគន់ ក្នុងការស្តាបនាទាំងឡាយ ពីសំណាក់លោក លោកស្រី សាស្ត្រាចារ្យ និងមិត្តនិស្សិតដោយក្តីសោមនស្សដើម្បីកែសម្ផស្នាដៃនេះអោយកាន់តែប្រសើរថែមទៀត។

# មាតិកា

បញ្ជីឧបសម្ព័ន្ធ.... ........................................................ v

## សេចក្ដីផ្ដើម

១. លំនាំបញ្ហា.. ........................................................ ១
២. ចំណោទបញ្ហា ........................................................ ២
៣. គោលបំណងនៃការស្រាវជ្រាវ ........................................................ ៣
៤.  ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........................................................ ៣
៥. អត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវ ........................................................ ៣
៦. វិធីសាស្ត្រស្រាវជ្រាវ ........................................................ ៤
    ក. ប្រភពទិន្នន័យ ........................................................ ៤
    ខ. ការប្រមូលទិន្នន័យ ........................................................ ៤
    គ. ការវិភាគទិន្នន័យ ........................................................ ៥
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................................ ៦

## ជំពូកទី ១
## រំលឹកទ្រឹស្ដី

១.១ ទស្សនទាននៃការអភិវឌ្ឍទេសចរណ៍ ........................................................ ៧
    ១.១.១ ទេសចរណ៍ជាអ្វី? ........................................................ ៧
    ១.១.២ ប្រភេទទេសចរណ៍ ........................................................ ៨
    ១.១.៣ គោលដៅទេសចរណ៍ ........................................................ ៩
    ១.១.៤ សម្បទាទេសចរណ៍ ........................................................ ១១
    ១.១.៥ រមណីយដ្ឋានទេសចរណ៍ ........................................................ ១១
    ១.១.៦ យុទ្ធសាស្ត្រគ្រប់គ្រងទេសចរណ៍ ........................................................ ១២
    ១.១.៧ ផលិតផល និង សេវាកម្មទេសចរណ៍ ........................................................ ១២
១.២ អត្ថន័យទូទៅនៃការអភិវឌ្ឍ ........................................................ ១៣
    ១.២.១ ការអភិវឌ្ឍសហគមន៍ ........................................................ ១៤
    ១.២.២ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ........................................................ ១៤
      ក. និយមន័យ ............ ........................................................ ១៤

១.៣ ទស្សនទានអំពីកសិទេសចរណ៍ ........ ១៦
ក.និយមន័យ........ ១៧
១.៣.១ ប្រភេទនៃកសិទេសចរណ៍........ ១៩
១.៤ សារៈប្រយោជន៍ដែលទទួលបានពីការអភិវឌ្ឍឲ្យក្លាយទៅជាតំបន់កសិទេសចរណ៍ ........ ២០
១.៤.១ សារៈប្រយោជន៍នៃកសិទេសចរណ៍........ ២០
១.៤.២ ផលប៉ះពាល់ដែលបណ្ដាពីកសិទេសចរណ៍ ........ ២១
ករណីយសិក្សាក្នុងប្រទេសថៃ........ ២៣
ករណីសិក្សាភូមិទំពាំងបាយជូរក្នុងខេត្តសិនថែង ទីក្រុងចូលូវាន ប្រទេសចិន ........ ២៦

## ជំពូកទី ២

## ស្ថានភាពទូទៅនៃតំបន់កោះឧកញ៉ាតី

២.១ លក្ខណៈទូទៅនៃតំបន់កោះឧកញ៉ាតី........ ២៩
២.១.១ ទីតាំងភូមិសាស្ត្រ........ ២៩
២.១.២ លក្ខណៈអាកាសធាតុ........ ៣០
២.១.៣ ស្ថានភាពប្រជាជនក្នុងតំបន់........ ៣០
២.១.៤ សន្តិសុខ និងសុវត្ថិភាពក្នុងតំបន់........ ៣០
២.១.៥ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ........ ៣១
ក. ផ្លូវធ្វើដំណើរ........ ៣១
ខ. ការផ្គត់ផ្គង់អគ្គិសនី ........ ៣១
គ. ការផ្គត់ផ្គង់ទឹកស្អាត........ ៣១
ឃ. ប្រព័ន្ធទូរគមនាគមន៍........ ៣១
ង. ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុ........ ៣២
២.១.៦ សក្ដានុពលទេសចរណ៍ក្នុងតំបន់កោះឧកញ៉ាតី........ ៣២
២.១.៧ លក្ខណៈពិសេសនៃកសិទេសចរណ៍ ........ ៣៤
២.២ ការវិភាគភាពខ្លាំង ភាពខ្សោយ កាលានុវត្តន៍ភាព និងការគំរាមកំហែង ........ ៣៤
ក. ភាពខ្លាំង........ ៣៤
ខ. ភាពខ្សោយ ........ ៣៥
គ. កាលានុវត្តន៍ភាព ........ ៣៥

ឃ. ការគំរាមគំហែង ................. ................................................................. ៣៥
២.៣ បញ្ហាប្រឈមនៅតំបន់កោះឧកញ៉ាតី ................................................................. ៣៦
២.៣.១ បង្គន់អនាម័យ ................ ................................................................. ៣៦
២.៣.២ បរិស្ថានសំរាម ................ ................................................................. ៣៧
២.៣.៣ សេវាកម្មម្ហូបអាហារ និង ការស្នាក់នៅ ................................................. ៣៧
២.៤ របបគំហើញនៃការសិក្សាស្រាវជ្រាវនៃតំបន់កោះឧកញ៉ាតី.. ...................................... ៣៨
២.៤.១ ការសម្ភាសជាមួយប្រជាជន .. ................................................................. ៣៨
២.៤.២ ការសម្ភាសជាមួយទេសចរ ... ................................................................. ៤៥

## ជំពូកទី ៣

## ទស្សនាទានក្នុងការរៀបចំអភិវឌ្ឍន៍តំបន់កោះឧកញ៉ាតីក្លាយជា តំបន់កសិទេសចរណ៍

៣.១ អនាម័យ និងបរិស្ថាន .. ................................................................. ៥១
ក. បង្គន់អនាម័យ ..... ................................................................. ៥១
ខ. សំរាម................. ................................................................. ៥២
៣.២ ហេដ្ឋារចនាសម្ព័ន្ធ ....... ................................................................. ៥៣
៣.៣ សេវាកម្មម្ហូបអាហារ និង ស្នាក់នៅ ................................................................. ៥៤
៣.៤ គ្រប់គ្រងធនធានធម្មជាតិ ................................................................. ៥៤
៣.៥ ការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ ............................................. ៥៥
៣.៦ ការបណ្តុះបណ្តាលធនធានមនុស្ស ................................................................. ៥៥
៣.៧ ការអភិវឌ្ឍផលិតផល ការស្វែងរកទីផ្សារ និងការផ្សព្វផ្សាយ ................................... ៥៦
ក.ការអភិវឌ្ឍផលិតផល ................................................................. ៥៧
ខ. ការស្វែងរកទីផ្សារ និងការផ្សព្វផ្សាយ ................................................................. ៥៧
៣.៨ ការជំរុញ និងលើកទឹកចិត្តឲ្យមានការវិនិយោគនៅក្នុងតំបន់ ..................................... ៥៨
៣.៩ ការចូលរួមរវាងអ្នកជាប់ពាក់ព័ន្ធ ................................................................. ៥៨
ក.ការចូលរួមពីរដ្ឋាភិបាល និងអាជ្ញាធរដែនដី ................................................. ៥៩
ខ. ការចូលរួមពីផ្នែកឯកជន ................................................................. ៥៩
គ. ការចូលរួមពីអង្គការ សមាគមន៍ក្នុង និងក្រៅរដ្ឋាភិបាល ......................................... ៥៩

ឃ. ការចូលរួមពីប្រជាជនក្នុងតំបន់ ............................................................ ៦០
ង. ការចូលរួមពីទេសចរ (ក្នុងស្រុក និងបរទេស) ............................................ ៦០
៣.១០ យុទ្ធសាស្ត្រក្នុងការច្នៃប្រឌិតដើម្បីឲ្យតំបន់កោះឧកញ៉ាតីក្លាយទៅជាកសិទេសចរណ៍............ ៦១

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១. សេចក្តីសន្និដ្ឋាន ................................................................................ ៦៤
២. ការផ្តល់អនុសាសន៍ ................................................................................ ៦៥
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# បញ្ជីឧបសម្ព័ន្ធ

បញ្ជីឧបសម្ព័ន្ធទី១ ៖ កម្រងសំណួរ

បញ្ជីឧបសម្ព័ន្ធទី២ ៖ រូបភាព

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

សមាហរកម្មសេដ្ឋកិច្ចពិភពលោក បានធ្វើឲ្យបណ្តាប្រទេសជាច្រើនមានកាលានុវត្តភាពក្នុងការអភិវឌ្ឍស្ទើរគ្រប់វិស័យ ដូចជា ឧស្សាហកម្ម កសិកម្ម ធុរកិច្ច និងវិស័យទេសចរណ៍។ ឧស្សាហកម្មទេសចរណ៍ ជាឧស្សាហកម្មមួយដែលបាននិងកំពុងចូលរួមចំណែកយ៉ាងសកម្មក្នុងការជម្រុញ កំណើនសេដ្ឋកិច្ច និងអភិវឌ្ឍន៍សង្គម។ យោងតាមរបាយការណ៍របស់អង្គការទេសចរណ៍ពិភពលោក ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ មានទេសចរធ្វើដំណើរ១,២៣៥លាននាក់ ទូទាំងពិភពលោក ក្នុងឆ្នាំ២០១៦ មានការកើនឡើង៣.៩% បើប្រៀបធៀបនឹងឆ្នាំ២០១៥ ដែលបានផ្តល់ចំណូលសរុប ១,២៦០ ពាន់លានដុល្លារ។ កម្ពុជា គឺជាអាណាចក្រមួយនៅក្នុងតំបន់អាស៊ីភាគអាគ្នេយ៍ ទទួលនូវអាកាសធាតុត្រូពិច(ក្តៅសើម) ដែលមានព្រំប្រទល់ជាប់និងប្រទេសថៃ ឡាវ វៀតណាម មួយផ្នែកទៀតជាប់ឈូងសមុទ្រថៃ ស្ថិតនៅចន្លោះប្រទេសមហាអំណាចពីរគឺ ចិន និងឥណ្ឌា លក្ខខណ្ឌបែបនេះធ្វើឲ្យកម្ពុជាមានភាពអំណោយផលដល់ការលូតលាស់នៃរុក្ខជាតិ កសិកម្ម និងវប្បធម៌។ ផ្អែកលើលក្ខខណ្ឌនេះ កម្ពុជាបានកំណត់គោលនយោបាយជាតិទេសចរណ៍ ជាទេសចរណ៍វប្បធម៌និងធម្មជាតិ និងបានកំណត់តំបន់ទេសចរណ៍នៅប្រទេសកម្ពុជាជា ៤តំបន់ធំៗគឺ តំបន់ភ្នំពេញនិងតំបន់ជុំវិញ សៀមរាបអង្គរនិងតំបន់ជុំវិញ តំបន់ឆ្នេរ និងតំបន់អេកូទេសចរណ៍។

វិស័យទេសចរណ៍ ជាវិស័យមាសបៃតង ដែលចូលរួមចំណែកចំបងក្នុងការចូលរួមអភិវឌ្ឍន៍លើកកំពស់ជីវភាពប្រជាជន និងសេដ្ឋកិច្ចប្រទេសកម្ពុជា។ យោងទៅតាមស្ថិតិទេសចរណ៍កម្ពុជា ឆ្នាំ២០១៦ មានទេសចរអន្តរជាតិជាង៥លាននាក់ មកកម្សាន្តកម្ពុជា ក្នុងនោះមាន៦០%នៃទេសចរមកទស្សនាកម្ពុជាមានគោលបំណងទាក់ទងនឹងវប្បធម៌ ៣០%គោលបំណងផ្សេងៗ និង ៥% ទាក់ទងនឹងសកម្មភាពដាំដុះ និងការរស់នៅប្រចាំថ្ងៃ។ បើយោងតាមឯកសារស្រាវជ្រាវរបស់វិទ្យាស្ថានស្រាវជ្រាវទេសចរណ៍អាស៊ាន បានបង្ហាញថា នៅប្រទេសថៃនិងហ្វីលីពីន មានទេសចរជាង ៣០% និងប្រទេសវៀតណាមមានទេសចរ២៥% ទៅទស្សនាក្នុងគោលបំណងកសិកម្ម តួលេខនេះបង្ហាញថាកម្ពុជាមានសកម្មភាពទេសចរ ដែលទាក់ទងនឹងកសិកម្មមានចំនួនតិចជាងប្រទេសជិតខាងរបស់ខ្លួន ក្នុងខណៈដែលប្រទេសថៃនិងវៀតណាម ជាប្រទេសស្ថិតនៅតាមដងទន្លេមេគង្គ និងមានអាកាសធាតុដូចគ្នា។ ផ្អែកតាមរបាយការណ៍ជំរឿនរបស់ក្រសួងផែនការកម្ពុជា មានប្រជាជនជិត៨០%ជាកសិករពឹងផ្អែកទៅលើវិស័យកសិកម្ម។ ទន្ទឹមនឹងនេះ កសិកម្មជាផ្នែកមួយ ដែលបានចូលរួមយ៉ាងសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ចំណាកស្រុក និងនិកម្មភាពតាមរយៈការលក់

ផលិតផល ដូចជា ផលិតផលទេសចរណ៍ ដែលទាក់ទងទៅនឹងកសិកម្ម និងអេកូទេសចរណ៍ដូចបណ្ដាប្រទេស ដែលមានសេដ្ឋកិច្ចពឹងផ្អែកទៅលើវិស័យកសិកម្មផងដែរ។ បើទេសចរណ៍និងកសិកម្ម រួមបញ្ចូលគ្នា ធ្វើឲ្យកត្តាជីវភាពប្រជាជនក្នុងសហគមន៍កាន់តែមានភាពល្អប្រសើរ ដោយសារចំណូលពីទេសចរបានដល់ដៃប្រជាពលរដ្ឋមូលដ្ឋានផ្ទាល់ ព្រមទាំងអាចអភិវឌ្ឍន៍នូវផលិតផលទេសចរណ៍ថ្មីមួយទៀតគឺ កសិទេសចរណ៍។

បច្ចុប្បន្ន ទេសចរណ៍ដែលទាក់ទងនឹងសកម្មភាពកសិកម្មត្រូវបានប្រទេសមួយចំនួននៅលើពិភពលោកបាន និងកំពុងរៀបចំជាយុទ្ធសាស្ត្រជម្រុញការទាក់ទាញទេសចរ ក្នុងសកម្មភាពកសិទេសចរណ៍។ សម្រាប់កម្ពុជា ក៏បានយកចិត្តទុកដាក់លើសកម្មភាពកសិទេសចរណ៍នេះផងដែរ ដោយសារតែមើលឃើញថា ផលិតផលបែបកសិទេសចរណ៍មានសក្ដានុពល ក្នុងការជំរុញឲ្យមានកំណើនទេសចរជាតិ និងអន្តរជាតិចូលទស្សនាដល់សហគមន៍មូលដ្ឋាន ប្រើប្រាស់សេវាស្នាក់នៅ និងស្វែងយល់ដោយផ្ទាល់នូវរបៀបដាំដុះដំណាំរបស់កសិករខ្មែរ និងធ្វើឲ្យភ្ញៀវអាចស្នាក់នៅតាមផ្ទះជនបទជាមួយប្រជាកសិករ ហើយផលប្រយោជន៍នេះ កសិករជាអ្នកទទួលផ្ទាល់ តាមរយៈការផ្ដល់សេវាស្នាក់នៅ ហូបចុក និងទិញផលិតផលពីកសិករ។ ដោយសារតែតំបន់ជាច្រើននៅកម្ពុជា ជាពិសេសតំបន់ ដែលនៅតាមដងទន្លេមេគង្គមានភាពអំណោយផលដល់សកម្មភាពកសិទេសចរណ៍។

កោះឧញ៉ាតី ជាតំបន់ដែលមានសក្ដានុពលក្នុងសកម្មភាពកសិទេសចរណ៍ ដោយសារមានប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់នេះភាគច្រើន មានកសិដ្ឋានសម្រាប់ដាំដុះដំណាំបន្លែ និងផ្លែឈើសរីរាង្គគ្មានជាតិគីមី សំរាប់ផ្គត់ផ្គង់ដល់ភ្ញៀវ ហើយតំបន់នេះអាចនឹងអភិវឌ្ឍឲ្យទៅជាកសិទេសចរណ៍ដ៏មានសក្ដានុពល បន្ទាប់ពីកោះនេះមានសក្ដានុពលទេសចរណ៍វប្បធម៌ និងរមណីយដ្ឋានធម្មជាតិជាច្រើនដែរនោះ ទើបក្រុមនិស្សិតយើងខ្ញុំបានយកតំបន់កោះនេះមកធ្វើការសិក្សាស្រាវជ្រាវក្រោមប្រធានបទ “ជំរុញការអភិវឌ្ឍកសិទេសចរណ៍ (ករណីសិក្សាតំបន់កោះឧញ៉ាតី)” ។

## ២. ចំណោទបញ្ហា

យោងតាមរបាយការណ៍ស្ថិតិរបស់ក្រសួងផែនការ មានប្រជាពលរដ្ឋជិត៨០%ជាកសិករ ហេតុអ្វី បានជាប្រទេសកម្ពុជាមិនអាចស្រូបទាញទេសចរ ដែលមានសកម្មភាពទាក់ទងនឹងកសិកម្ម ឲ្យបានចំនួនច្រើនដូចប្រទេសថៃ និងវៀតណាមដែលមានសណ្ឋានដី និងអាកាសធាតុដូចកម្ពុជា? តើតំបន់កោះឧកញ៉ាតី អាចមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការជំរុញឲ្យមានសកម្មភាពកសិទេសចរណ៍បានដែរឬទេ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវស្តីពី ជំរុញការអភិវឌ្ឍកោះឧញ៉ាតីជាតំបន់កសិទេសចរណ៍ មានដូចខាងក្រោមៈ

- ស្វែងយល់អំពី សក្តានុពលកសិទេសចរណ៍ក្នុងតំបន់កោះឧកញ៉ាតី
- ជំរុញឲ្យមានការអភិវឌ្ឍកសិទេសចរណ៍កោះឧកញ៉ាតី
- លើកកំពស់កំរិតជីវភាពប្រជាជនក្នុងតំបន់កោះឧកញ៉ាតី
- ជំរុញការអភិរក្សតំបន់ធម្មជាតិទេសចរណ៍
- បង្កើនទីផ្សារផលិតផលកសិកម្ម។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី ជំរុញការអភិវឌ្ឍកោះឧកញ៉ាតីឲ្យក្លាយជាតំបន់កសិទេសចរណ៍ ដែលស្ថិតនៅឃុំកោះឧកញ៉ាតី ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ធ្វើឡើងចន្លោះពីថ្ងៃទី២ ដល់ថ្ងៃ ១៦ ខែមិថុនា ឆ្នាំ២០១៧ ចំពោះប្រជាពលរដ្ឋក្នុងតំបន់កោះឧកញ៉ាតីផ្ទាល់មានចំនួន១០០ នាក់ ដែលមានទាំងបុរស ស្ត្រី អាយុចាប់ពី១៨ ដល់៦០ឆ្នាំ រួមមាន ជនមានចំណេះដឹង និងអនក្ខរជន និង ស្ថិតនៅក្នុងកម្រិតជីវភាពក្រីក្រ មធ្យម និងធូរធារ អាជ្ញាធរចំនួន១០រូប រួមមាន មន្ត្រីឃុំ មន្ត្រីស្នាក់ការ ភូមិ និងអាជ្ញារធរមានសមត្ថកិច្ចក្នុងឃុំទាំងមូលទេសចរចំនួន ៥៥នាក់ និងមានវ័យចាប់ពី១៨ ដល់ ៦០ឆ្នាំ ដែលបានចូលមកទស្សនាកំសាន្តនៅក្នុងតំបន់កោះឧកញ៉ាតី។ ដោយផ្តោតសំខាន់ទៅលើ ចំណុចមួយចំនួនដូចខាងក្រោមៈ

- សកម្មភាពនៃការដាំដុះ ការទទួលបានចំណូល ស្ថានភាពទូទៅរបស់ប្រជាពលរដ្ឋ
- វិភាគទៅលើចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគំរាមកំហែង
- យុទ្ធសាស្ត្រការអភិវឌ្ឍកសិទេសចរណ៍ និងការគ្រប់គ្រង ។

## ៥. អត្ថប្រយោជន៍នៃការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី ជំរុញការអភិវឌ្ឍកោះឧញ៉ាតីជាតំបន់កសិទេសចរណ៍ បានផ្តល់នូវ អត្ថប្រយោជន៍មួយចំនួនដូចខាងក្រោមៈ

- **ចំពោះអាជ្ញាធរក្នុងតំបន់** ៖ អាចផ្តល់ជាទ្រឹស្តី និងគោលការណ៍ណែនាំសម្រាប់ដំណើរការ អភិវឌ្ឍ និងគ្រប់គ្រងនូវតំបន់មូលដ្ឋាននៅជុំវិញមូលដ្ឋាននោះ ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។ យើងអាចលើកជាចំណុចយុទ្ធសាស្ត្រ និងទិសដៅសម្រាប់បង្ហាញពីយុទ្ធសាស្ត្រអភិវឌ្ឍ និងដើម្បីធ្វើ ឲ្យសេដ្ឋកិច្ច សង្គម វប្បធម៌ របៀបរស់នៅ ការធ្វើអាជីវកម្ម ព្រមទាំងការការពារធនធានធម្មជាតិ និង

ជីវៈចម្រុះគ្រប់ប្រភេទដែលនៅក្នុងតំបន់នេះ។ ម្យ៉ាងទៀត អាជ្ញាធរក្នុងតំបន់អាចដឹងពីចំណុចខ្វះខាតទាំងឡាយសម្រាប់ធ្វើការអភិវឌ្ឍបន្ថែមនៅក្នុងតំបន់ឲ្យកាន់តែល្អប្រសើរ។

- **ចំពោះសិស្ស និស្សិត៖** គឺជាឯកសារដែលកើតចេញពីការសិក្សាស្រាវជ្រាវ វាជាឯកសារបន្ថែមសម្រាប់សិស្ស និស្សិតសម្រាប់អាន ស្វែងយល់បន្ថែម និងអ្នកស្រាវជ្រាវជំនាន់ក្រោយស្វែងយល់ពីទ្រឹស្តី និងការអនុវត្តជាក់ស្តែងអំពីការអភិវឌ្ឍ និងការគ្រប់គ្រងតំបន់នោះ។
- **ចំពោះប្រជាជនក្នុងតំបន់៖** យល់ច្បាស់ពីទេសចរណ៍ អាចស្វែងយល់ពីការធ្វើកសិកម្មមកបម្រើក្នុងវិស័យទេសចរណ៍ អត្ថប្រយោជន៍កសិកម្មចំពោះវិស័យទេសចរណ៍ បង្កើនកំរិតប្រាក់ចំណូល កាត់បន្ថយហានីយភ័យពីការចំណាកស្រុកដើម្បីស្វែងរកការងារ កង្វះទីផ្សារសំរាប់លក់ផលិតផល បង្កើនការទំនាក់ទំនងរវាងប្រជាជនក្នុងមូលដ្ឋាន ប្រជាជនជាមួយទេសចរ និង កាត់បន្ថយអក្ខរភាពជាដើម។
- **ចំពោះប្រជាជាតិកម្ពុជា៖** ផ្សព្វផ្សាយឲ្យប្រជាជនកម្ពុជាបានស្គាល់ពីទេសចរណ៍បែបថ្មីកសិ-ទេសចរណ៍ អត្ថប្រយោជន៍ បណ្តុះគំនិតក្នុងការចូលរួមអភិរក្ស និងអភិវឌ្ឍន៍។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីសម្រេចបានលទ្ធផលល្អនៃកាស្រាវជ្រាវ វិធីសាស្ត្រមួយចំនួន ត្រូវបានលើកយកមកប្រើប្រាស់ ក្នុងនោះរួមទាំងប្រភពទិន្នន័យ ការប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ។

### ក. ប្រភពទិន្នន័យ

ទិន្នន័យត្រូវបានដកស្រង់ចេញពីឯកសារមួយចំនួនពីក្រសួងទេសចរណ៍ មន្ទីរទេសចរណ៍ មន្ទីរដែលពាក់ព័ន្ធផ្សេងៗ បណ្ណាល័យជាតិ និងបណ្ណាល័យក្នុងសាកលវិទ្យាល័យមួយចំនួន ក្រៅពីនេះ ឯកសារផ្សេងៗទៀតក៏ត្រូវបានដកស្រង់ពីវចនានុក្រមខ្មែរសម្តេចសង្ឃរាជ ជួន ណាត និងតាមគេហទំព័រ បណ្តាញអ៊ីនធឺណែត ដូចជា google និង ករណីសិក្សាជា PDF ជាដើម។

ជាងនេះទៅទៀត ទិន្នន័យត្រូវបានស្រាវជាវចេញពីការចុះអង្កេតពីស្ថានភាពតំបន់ផ្ទាល់ ការថតរូបផ្តិតយកទិដ្ឋភាពទូទៅនៃតំបន់កោះឧកញ៉ាតី និងការចុះសម្ភាសក្នុងភូមិ ក៏ដូចជាទេសចរជាតិ អន្តរជាតិ ដែលមកកំសាន្តនៅតំបន់នោះផងដែរ ។

### ខ. ការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យមានដូចជា: ទ្រឹស្តី សៀវភៅបោះពុម្ពផ្សាយ របាយការណ៍ ផែនការនិក្ខេបបទ ព័ត៌មានកាសែត ទស្សនាវដ្តី និងផ្សេងៗ។

ទិន្នន័យ សំដៅដល់បណ្តុំព័ត៌មានដែលដកស្រង់ដោយផ្ទាល់ចេញពីការសម្ភាស និងអង្កេតស្ថានភាពទូទៅនៃតំបន់ ដែលឆ្លងកាត់ជំហានអនុវត្តដូចខាងក្រោម៖

**ការកំណត់គំរូតាង** : ការចុះសម្ភាសផ្ទាល់ ដើម្បីប្រមូលបានបឋមទិន្នន័យត្រូវបានផ្តោតយ៉ាងសំខាន់ទៅលើ ១៥០នាក់ ក្នុងនោះត្រូវបានបែងចែកជាបីប្រភេទគំរូតាង ដែលរួមមាន ប្រជាពលរដ្ឋក្នុងតំបន់កោះឧកញ៉ាតី ផ្ទាល់មានចំនួន ១០០ នាក់ ដែលមានទាំងបុរស ស្ត្រី អាយុចាប់ពី ១៨ ដល់៦០ឆ្នាំ រួមជនដែលមានចំណេះដឹង អនក្ខរជន និងជនដែលស្ថិតនៅក្នុងកម្រិតជីវភាពក្រីក្រ មធ្យម និងធូរធារ អាជ្ញាធរចំនួន៣ រូប រួមមាន មន្ត្រីឃុំ មន្ត្រីស្នាក់ការភូមិ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងឃុំទាំងមូល ទេសចរ ចំនួន១០០នាក់ និងមានវ័យចាប់ពី១៨ ដល់៦០ឆ្នាំ ដែលបានចូលមកទស្សនាកំសាន្តនៅក្នុងតំបន់កោះឧកញ៉ាតី។

**កម្រងសំណួរ** : ការចុះអង្កេតត្រូវបានរៀបចំមានចំនួន៣ប្រភេទ៖សំរាប់ធ្វើការសំភាន៍ជាមួយ៖

- ប្រជាជនក្នុងតំបន់មាន ១០ សំនួរ
- ទេសចរជាតិ ១៣ សំនួរ
- អាជ្ញាធរ ៨ សំនួរ
- ទេសចរអន្តរជាតិ ៨ សំនួរ

សរុប ៣៩ សំណួរ ទាក់ទងនឹងភេទ អាយុ កម្រិតយល់ដឹងពីតំបន់កោះឧកញ៉ាតី កម្រិតពេញចិត្តចូលរួមអភិវឌ្ឍន៍ និងការសហការបម្រើសេវាទេសចរណ៍របស់ប្រជាពលរដ្ឋទៅកាន់ទេសចរ។

**ការចុះអង្កេត** : ការចុះអង្កេតត្រូវបានធ្វើឡើង តាមរយៈការចុះពិនិត្យមើលដំណាំកសិផលផ្សេងៗនៅក្នុងតំបន់នោះ ធម្មជាតិនៅជុំវិញ និងបន្ទាប់បន្សំ គួបផ្សំនឹងបញ្ហាប្រឈម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងភូមិ។

**ការសម្ភាស** : រាល់ការសម្ភាសន៍នីមួយៗត្រូវបានធ្វើឡើងជាលក្ខណៈបុគ្គល ដែលធ្វើមួយនាក់ ទៅមួយនាក់ផ្សេងទៀត ដោយធ្វើការដើរសាកសួរតាមលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ និងចុះជជែកជាមួយមន្ត្រីក្រុមប្រឹក្សាឃុំនៅសាលាឃុំ សមត្ថកិច្ចនៅប៉ុស្ត៍នគរបាលឃុំ និងសាកសួរទេសចរដែលកំពុងដើរកម្សាន្តនៅក្នុងតំបន់កោះឧកញ៉ាតី។

### គ. ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យត្រូវបានធ្វើឡើង តាមរយៈការប្រមូលចម្លើយពីការសម្ភាសគំរូតាងទាំង ១៥៥នាក់ ដោយគិតតែគណនាជាភាគរយនៃចម្លើយរបស់គំរូតាងទាំងអស់ ដោយប្រើប្រាស់កម្មវិធីកុំព្យូទ័រ Microsoft Excel លើក្រាបផ្លិត (Pie Chart)។ ដូចនេះទាំងចំនួនគំរូតាង និងការចុះអង្កេតស្ថាន

ភាពតំបន់ផ្ទាល់ គឺអាចយកទៅប្រើជា ការវិភាគទិន្នន័យបែបបរិមាណ (Quantitative) និងបែបគុណភាព (Qualitative) បាន។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានេះត្រូវបានរៀបចំជា៥ ផ្នែកធំៗដូចខាងក្រោម ៖

**ផ្នែកទី១** : សេចក្តីផ្តើម ផ្តោតទៅលើចំណុចចំនួន៦ ដូចជា ប្រវត្តិបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់ស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះតែម្តង។

**ផ្នែកទី២** : ខ្លឹមសារ បង្ហាញពីខ្លឹមសារនៃសារណា ដែលរួមមានបីជំពូកធំៗ ដូចខាងក្រោម៖

**ជំពូក១.** ទ្រឹស្តី ជាគន្លឹះដែលរំលឹករាល់ទ្រឹស្តីទាក់ទងនឹងប្រធានបទ តាមរយៈការធ្វើសំយោគពាក្យនីមួយៗ ចេញពីអត្ថន័យ ដែលត្រូវបានកំណត់ដោយអ្នកនិពន្ធ និងប្រភពផ្សេងៗគ្នា និងធ្វើការសន្និដ្ឋានអំពីអត្ថន័យនៃប្រធានបទជារួម។

**ជំពូក២.** ស្ថានភាពនៃទេសចរណ៍នៅក្នុងតំបន់កោះឧកញ៉ាតី ជាជំពូកស្នូលមួយដែលរៀបរាប់អំពីស្ថានភាពនៅតំបន់នោះផ្ទាល់ សក្តានុពល ចំណុចខ្លាំង និងចំណុចខ្សោយក្នុងតំបន់កោះឧញ៉ាតី និងបញ្ហាប្រឈមនានាក្នុងការអភិវឌ្ឍ និងបង្ហាញអំពីក្រាបទិន្នន័យដែលបានវិភាគ។

**ជំពូក៣.** ទស្សនទានក្នុងការអភិវឌ្ឍតំបន់កោះឧកញ៉ាតី ជាជំពូកសំខាន់ដែលបង្ហាញពីការរកឃើញគំនិតជាគន្លឹះថ្មីៗ និងទ្រឹស្តីអភិវឌ្ឍន៍តំបន់កោះឧកញ៉ាតីអោយក្លាយជា រមណីយដ្ឋានបែបកសិទេសចរណ៍ ប្រកបដោយភាពទាក់ទាញ និងនិរន្តភាព ជារួម តាមការថ្លឹងថ្លែងវិភាគទិន្នន័យចំបងដែលបានប្រមូលបាន ទិន្នន័យបន្ទាប់បន្សំទាក់ទងនឹងទ្រឹស្តី ដែលត្រូវបានរៀបរាប់ក្នុងជំពូកពីរខាងលើ រួមផ្សំនឹងសំណុំឯកសារអភិវឌ្ឍន៍របស់សាលាឃុំ និងស្ថាប័នពាក់ព័ន្ធដទៃទៀត។

**ផ្នែកទី៣** : សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ជាការសេរុបសេចក្តីអំពីសារណា និងផ្តល់អនុសាសន៍ជាយោបល់បន្ថែមពីអ្វីដែលបានបកស្រាយ និងរកឃើញ។

**ផ្នែកទី៤** : ឯកសារយោង ជាផ្នែកមួយដែលផ្ទុកនូវរាល់ប្រភពសំណុំឯកសារពាក់ព័ន្ធក្នុងការស្រាវជ្រាវទាំងមូល។

**ផ្នែកទី៥** : ឧបសម្ព័ន្ធ សំដៅដល់ភស្តុតាងជាលិខិតរដ្ឋបាលពាក់ព័ន្ធ ឯកសារស្រាវជ្រាវ កម្រងសំណួរ និងកម្រងរូបភាពដែលទាក់ទងនឹងស្ថានភាពនៃទីតាំងរបស់ប្រធានបទ។

# ជំពូកទី ១
# រំលឹកឡើងវិញ

# ជំពូកទី ១
# រំលឹកទ្រឹស្តី

ជំពូកមួយនេះ គឺបកស្រាយរាល់ទ្រឹស្តីទាំងឡាយដែលយើងធ្លាប់សិក្សា ព្រមទាំងឯកសារផ្សេងៗទៀត ពាក់ពន្ធ័និងប្រធានបទនៃការសិក្សាស្រាវជ្រាវ។ ទ្រឹស្តីក្នុងជំពូកនេះនិងត្រូវបានបកស្រាយតាមផ្នែកសំខាន់ដូចជា ទស្សនទាននៃការអភិវឌ្ឍទេសចរណ៍ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ទស្សនទានអំពីកសិទេសចរណ៍ និងប្រភេទនៃកសិទេសចរណ៍ជាដើម។ យើងនឹងធ្វើការបង្ហាញផ្នែកខាងលើ ព្រមទាំងចំណុចសំខាន់ៗទាំងឡាយលម្អិតដូចខាងក្រោមៈ

## ១.១ ទស្សនទាននៃការអភិវឌ្ឍទេសចរណ៍

### ១.១.១ ទេសចរណ៍ជាអ្វី?

តាមការសិក្សា និងស្រាវជ្រាវអំពីនិយមន័យទេសចរណ៍ ត្រូវបានអ្នកប្រាជ្ញជាច្រើនធ្វើការកំណត់និយមន័យដែលមានដោយផ្អែកតាមទស្សនៈផ្សេងៗគ្នា។

យោងតាមវចនានុក្រម **Oxford Learner's Pocket Dictionary** ទេសចរណ៍អាចឲ្យនិយមន័យថាជាសកម្មភាពជំនួញដែលទាក់ទងនឹងការផ្តល់ទីកន្លែងស្នាក់នៅ សេវាផ្សេងៗ និងការកម្សាន្តដល់មនុស្សដែលទស្សនាកន្លែងណាមួយដើម្បីភាពសប្បាយរីករាយ [1]។

អង្គការសហប្រជាជាតិទេសចរណ៍ពិភពលោក បានកំណត់និយមន័យទេសចរណ៍ ថាទេសចរណ៍ជាសកម្មភាពកម្សាន្តដែលមានឥទ្ធិពល ដល់ការពង្រឹងសុវត្ថិភាព ការរីកចម្រើន និងអភិវឌ្ឍន៍កម្លាំងកាយ និងចិត្តរបស់មនុស្សដែលធ្វើចលនា ឬធ្វើដំណើរចេញពីកន្លែងរស់នៅជាប្រចាំរបស់ខ្លួនក្នុងរយៈពេលណាមួយ[2]។

ផ្អែកតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា "**ទេសចរណ៍**" សំដៅដល់សកម្មភាពទាំងឡាយរបស់បុគ្គលដែលធ្វើដំណើរទៅ និងស្នាក់នៅកន្លែងផ្សេងៗ ក្រៅពីបរិយាកាសប្រក្រតីរបស់ពួកគេសម្រាប់រយៈពេលដែលបានកំណត់ជាក់លាក់មួយ (មិនតិចជាងមួយថ្ងៃ មួយយប់ និងមិនលើសពីមួយឆ្នាំ) ដើម្បីសំរាក លំហែកាយ ធុរកិច្ច និងក្នុងគោលបំណងទេសចរណ៍ផ្សេងៗ [3]។

*កម្រងគតិយុត្តិទេសចរណ៍ រៀបចំដោយសាស្ត្រាចារ្យ ស៊ូ គឹមព្រឹទ្ធា ឆ្នាំ២០១៥ [1]

*វចនានុក្រម Oxford Learner's Pocket Dictionary[2]

*សេចក្តីផ្តើមទេសចរណ៍ រៀបរៀងដោយ បណ្ឌិត ឈុន ពហុ អនុបណ្ឌិត ជា ស៊ីថា, ហុង វណ្ណៈ, និង សាំង ចន្ទ បោះពុម្ពថ្ងៃទី០១ តុលា ២០១៥[3]

សរុបសេចក្ដីមក ទេសចរណ៍ ជាការធ្វើដំណើររបស់ពលរដ្ឋ ក្នុងរយៈពេលមួយ ពីតំបន់មួយ (ទីក្រុង ភូមិ ឃុំ ប្រទេស) ទៅតំបន់មួយ ដោយមិនសំដៅលើការផ្លាស់ប្ដូរកន្លែងរស់នៅ និងទីកន្លែងធ្វើការងារ។

ទេសចរណ៍ ជាភាពសប្បាយរីករាយ ដែលបំពេញដល់ពលរដ្ឋនូវតម្រូវការ ដែលគេចង់បាន និងរងចាំក្នុងកំឡុងពេលដែលគេបំពេញការងារតាម រយៈការធ្វើដំណើរក្នុងគោលបំណងសំរាកលំហែកាយ អារម្មណ៍ ព្យាបាល ចូលរួមក្នុងពិធីបុណ្យ វិទ្យាសាស្ត្រ និងអាជីវកម្ម (Business)។

**១.១.២ ប្រភេទទេសចរណ៍**

យោងតាមការសិក្សា គេសង្កេតឃើញថាទេសចរណ៍ត្រូវបានបែងចែកជាច្រើនប្រភេទប៉ុន្តែ យើងខ្ញុំសុំយកតែប្រភេទទេសចរណ៍មួយចំនួន ដើម្បីលើកយកមកបកស្រាយជានិយមន័យដូចខាងក្រោម៖

- ទេសចរណ៍ក្នុងស្រុក (Domestic Tourism)
- ទេសចរណ៍ជាតិ (National Tourism)
- ទេសចរណ៍អន្តរជាតិ (International Tourism)
- ទេសចរណ៍សង្គម (Social Tourism)
- ទេសចរណ៍ផ្ទៃក្នុង (Internal Tourism)

**ទេសចរណ៍ជាតិ (National Tourism)** ជាចង្កោមសកម្មភាពការងារដែលបំរើឲ្យវិស័យទេសចរណ៍ក្នុងប្រទេស និងទេសចរណ៍ក្រៅប្រទេស។

**ទេសចរណ៍ក្នុងស្រុក (Domestic Tourism)** ជាសកម្មភាពទេសចរណ៍ដែលភ្ជាប់ជាមួយការធ្វើដំណើរជាទេសចរណ៍ និងធ្វើសកម្មភាពទេសចរណ៍របស់ប្រជាពលរដ្ឋនៅលើទឹកដីនៃប្រទេសកំណើត (ប្រទេសដែលគេរស់នៅជាអចិន្ត្រៃយ៍) ។

**ទេសចរណ៍អន្តរជាតិ (International Tourism)** ជាសកម្មភាពដែលចងភ្ជាប់ជាមួយនឹងការធ្វើដំណើរជាទេសចរណ៍ របស់ពលរដ្ឋប្រទេសមួយទៅប្រទេសមួយទៀត ។

**ទេសចរណ៍អន្តរជាតិ** ជាសកម្មភាពទេសចរណ៍អន្តរជាតិដែលត្រូវបានបែងចែកជា ២គឺ ៖

- **Inbound Tourism** : សំដៅទៅលើជនទាំងឡាយណាដែលធ្វើដំណើរចូលមកកាន់ប្រទេសណាមួយ ហើយស្នាក់នៅទីនោះលើសពីរយៈពេល២៤ម៉ោង តែតិចជាងមួយឆ្នាំ ក្នុងគោលបំណងផ្សេងៗដែលមិនពាក់ព័ន្ធនឹងការស្វែងរកការងារ។

- **Outbound Tourism :** សំដៅលើជនទាំងឡាយណាដែលធ្វើដំណើរទៅកាន់ប្រទេស ណាមួយហើយស្នាក់នៅប្រទេសនោះរយៈពេល ២៤ម៉ោង តែតិចជាងមួយឆ្នាំ ក្នុងគោលបំណងសំរាកលំហែរកាយសិក្សាស្វែងយល់ពោល គឺមិនពាក់ព័ន្ធនឹងការស្វែងរកការងារនឹងមិនមែនជាការផ្លាស់ប្តូរកន្លែងរស់នៅ។

**ទេសចរណ៍អន្តរជាតិ** សំដៅទៅលើទេសចរណ៍ដែលធ្វើដំណើរឆ្លងកាត់ព្រំដែនប្រទេស។ អង្គការទេសចរណ៍ពិភពលោកបានកំណត់ទេសចរដូចជាមនុស្សដែល«ធ្វើដំណើរទៅនិងស្នាក់នៅក្នុងកន្លែងខាងក្រៅបរិស្ថានធម្មតារបស់ពួកគេ មិនលើសពីមួយឆ្នាំជាប់គ្នាដើម្បីការកំសាន្តអាជីវកម្ម និងគោលបំណងផ្សេងទៀត ។

**ទេសចរណ៍សង្គម “Social Tourism”** ជាប្រភេទមួយនៃទេសចរណ៍ដែលត្រូវបានបង្កើតឡើងដោយរដ្ឋាភិបាលសម្រាប់បង្ករជាលទ្ធភាពដល់ស្រទាប់មហាជនដូចជា សិស្ស និស្សិត យុវវ័យ អ្នកចូលនិវត្តន៍ ជនពិការ និងពលរដ្ឋប្រទេសនេះ ធ្វើដំណើរកម្សាន្ត លំហែជាទេសចរណ៍ក្នុងរដូវទេសចរណ៍តិច (Low Season) ។

នៅខែឧសភាឆ្នាំ 1959 នៅក្នុងកិច្ចប្រជុំលើកទីពីរនៃទេសចរណ៍សង្គមនៅក្នុងប្រទេសអូទ្រីស លោក **Walter Hunziker** បានស្នើឡើងនូវនិយមន័យដូចខាងក្រោមៈ “ទេសចរណ៍សង្គមគឺជាប្រភេទនៃវិស័យទេសចរណ៍បានអនុវត្តដោយក្រុមដែលមានប្រាក់ចំណូលទាប ព្រមទាំងមានការសម្របសម្រួលសេវាកម្មទាំងស្រុង” ។

**ទេសចរណ៍ផ្ទៃក្នុង “Internal Tourism”** ជាចង្កោមនៃសកម្មភាពកាងារមាននៅផ្ទៃខាងក្នុងនៃតំបន់មួយ ទីកន្លែងមួយ ឬប្រទេសមួយ។ សកម្មភាពទេសចរណ៍បែបនេះជាទូទៅជាសកម្មភាពដែលបំរើ ឲ្យទេសចរណ៍ក្នុងស្រុកនិងទេសចរណ៍បរទេស។ វាជាប្រភេទទេសចរណ៍ដែលធ្វើឡើងនៅផ្ទៃខាងក្នុងតំបន់ កន្លែង ឬប្រទេសមួយជាក់លាក់ [4]។

### ១.១.៣ គោលដៅទេសចរណ៍

ទស្សនៈរួមស្តីពីគោលដៅទេសចរណ៍:

**គោលដៅទេសចរណ៍** គឺជាទីកន្លែងទាំងមូល និងផលិតផលទេសចរណ៍ទាំងអស់ មាននៅក្នុងតំបន់ ដែលជាសេចក្តីប្រាថ្នាចង់ទៅទស្សនារបស់អ្នកទេសចរ។ អាចមានន័យថាគោលដៅ គឺក្តោបយកតំបន់ទាំងមូលណាមួយដែលចង់ទៅហើយដែលតំបន់នោះរួមមាន តំបន់ទេសចរណ៍ ផលិតផល

[4]សេចក្តីផ្តើមទេសចរណ៍ រៀបរៀងដោយ បណ្ឌិត ឈុន ពហុ អនុបណ្ឌិត ជា ស៊ីថា, ហុង វណ្ណៈ, និង សាំង ចន្ធូ បោះពុម្ភថ្ងៃទី០១ តុលា ២០១៥[4]

ទេសចរណ៍ ភាពទាក់ទាញទេសចរណ៍ មណ្ឌលកម្សាន្ត ទេសចរណ៍ រមណីយដ្ឋានទេសចរណ៍ អេកូ-ទេសចរណ៍សហគមន៍ទេសចរណ៍ ។ល។

**គោលដៅទាក់ទាញទេសចរណ៍** គឺសំដៅដល់កន្លែង ដែលមានភាពទាក់ទាញទេសចរណ៍ មានសម្បទាទេសចរណ៍ មានសេវាបម្រើប្រកបដោយផាសុកភាព និងមានលទ្ធ ភាពអាចចូលទៅដល់បាន។

**តំបន់ទេសចរណ៍** គឺសំដៅដល់តំបន់ទាំងឡាយក្នុងព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានជ្រើសរើស រៀបចំ និងអភិវឌ្ឍន៍បម្រើឲ្យគោលបំណង និងសកម្មភាពទេសចរណ៍។

**មណ្ឌលកម្សាន្តទេសចរណ៍** គឺសំដៅដល់ទីតាំងសេវាកម្មទាំងឡាយ ដែលធ្វើអាជីវកម្មបម្រើឲ្យការសម្រាក លំហែ និងកម្សាន្ត តាមគោលបំណងទេសចរណ៍ស្របច្បាប់ ហើយប្រភេទអាជីវកម្មទាំងនោះត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

នៅក្នុងឧស្សាហកម្មទេសចរណ៍តំបន់មួយអាចក្លាយជាតំបន់គោលដៅទេសចរណ៍នៅពេលដែលតំបន់នោះបំពេញបាននូវលក្ខខណ្ឌ ៥ A ដូចតទៅ៖

- ✓ មានភាពទាក់ទាញ (Attraction)
- ✓ ភាពអាចទៅដល់ (Access)
- ✓ មានកន្លែងស្នាក់នៅ (Accommodations)
- ✓ មានសេវាកម្មទេសចរណ៍ (Amenities)
- ✓ អាចធ្វើសកម្មភាព (Activities) ផ្សេងៗ[5]

**ភាពទាក់ទាញ (Attraction)** ជាលក្ខណៈសំខាន់ជាងគេ ដែលតំបន់គោលដៅទេសចរណ៍មួយចាំបាច់ត្រូវតែមាន។ ឧទាហរណ៍ សម្រាប់មនុស្សដែលមានចាប់អារម្មណ៍ទៅលើសិល្បៈ ឬប្រវត្តិសាស្ត្របុរាណ ការធ្វើដំណើររយៈពេលបីម៉ោងតាមផ្លូវដ៏សែនលំបាកទៅកាន់រូងភ្នំមួយដែលមានគំនូរបុរាណ គឺជាដំណើរកំសាន្តដ៏មានប្រយោជន៍ណាស់សម្រាប់ពួកគេ។

**ភាពអាចទៅដល់ (Access)** មានន័យថាមានលទ្ធភាពទៅដល់កន្លែងដែលមានភាពទាក់ទាញ។ រួមមាន មធ្យោបាយធ្វើដំណើរចូលទៅក្នុង និងចេញទៅក្រៅប្រទេស និងចូលទៅក្នុង និងចេញទៅក្រៅតំបន់ពិសេសណាមួយដែលមានភាពទាក់ទាញ។ មានកន្លែងស្នាក់នៅ (Accommodations) បន្ទាប់ពីបានជ្រើសរើសកន្លែង ដែលមានភាពទាក់ទាញ និងមានផ្លូវដើម្បីទៅដល់កន្លែងនោះហើយ

---

*សេចក្ដីផ្ដើមទេសចរណ៍ រៀបរៀងដោយ បណ្ឌិត ឈុន ពហុ អនុបណ្ឌិត ជា ស៊ីថា, ហុង វណ្ណៈ, និង សាំង ចន្ទ្ធ បោះពុម្ពថ្ងៃទី០១ តុលា ២០១៤[5]

កត្តាសំខាន់បន្ទាប់ដែលត្រូវពិចារណាគឺកន្លែងស្នាក់នៅ (Accommodations)។ ប្រសិនបើតំបន់នោះបានៈភិវឌ្ឍន៍ ហើយវាអាចមានន័យថា ងាយស្រួលទៅដល់កន្លែង ដែលមានភាពទាក់ទាញ និងកន្លែង ស្នាក់នៅ។

សេវាកម្មទេសចរណ៍ (Amenities) រួមមាន បង្គន់ ទឹក និងអគ្គិសនី សម្ភារអាំងសាច់និងវត្ថុប្រើប្រាស់ផ្សេងៗ ដែលអ្នកទស្សនាអាចត្រូវការ។

**សកម្មភាព (Activities)** គឺជាមូលហេតុចម្បង ដែលធ្វើឲ្យគេជ្រើសរើសតំបន់គោលដៅទេសចរណ៍មួយជាក់លាក់។ សកម្មភាពអាចជួយកាត់បន្ថយភាពមិនសប្បាយចិត្តរបស់ទេសចរ ដោយបញ្ចូលភាពទាក់ទាញ និងសកម្មភាពតំបន់មួយអាចកាន់តែមានភាពទាក់ទាញខ្លាំងឡើងដល់ទេសចរ។

**ភាពទាក់ទាញ** គឺជាភាពអាចទៅដល់ កន្លែងស្នាក់នៅសេវាកម្មទេសចរណ៍ និងសកម្មភាពទាំងអស់នេះ ជាចារឹកលក្ខណៈដែលនាំឲ្យតំបន់គោលដៅទេសចរណ៍មួយមានស្ថេរភាព។ ទោះជាយ៉ាងណាក៏ដោយតំបន់គោលដៅទេសចរណ៍ទាំងអស់មានចំណុចទាំងប្រាំនេះគ្រាន់តែមានកំរិតខុសគ្នាប៉ុណ្ណោះ។

### ១.១.៤ សម្បទាទេសចរណ៍

សម្បទាទេសចរណ៍ សំដៅលើរចនាសម្ព័ន្ធ និងសេវាកម្ម ដែលត្រូវបានគេកសាងឡើងនៅក្នុងតំបន់ទេសចរណ៍ ដើម្បីបំពេញតំរូវការរបស់ភ្ញៀវទេសចរ ឧទាហរណ៍ សណ្ឋាគារ ផ្ទះសំណាក់ បន្ទប់ទឹកសាធារណៈ ភោជនីយដ្ឋាន សេវាកម្មមគ្គុទេសទេសចរណ៍ -ល-។ ជាការពិតណាស់ នៅក្នុងតំបន់គោលដៅទេសចរណ៍នីមួយៗ គេទាមទារឲ្យមានការអភិវឌ្ឍ និងមាន ធនធានគ្រប់គ្រាន់សំរាប់បំរើឲ្យភ្ញៀវទេសចរ ។

### ១.១.៥ រមណីយដ្ឋានទេសចរណ៍

រមណីយដ្ឋានទេសចរណ៍ គឺជាផ្នែកមួយយ៉ាងសំខាន់ ក្នុងចំណោមផលិតផលទេសចរណ៍ ដែលបានបង្កើនប្រាក់ចំនូលដល់ប្រជាពលរដ្ឋ និងរក្សាបាននូវភាពគង់វង្សជាធានទាំងឡាយដែលមាននៅក្នុងតំបន់។ មិនតែប៉ុណ្ណោះការអភិវឌ្ឍរមណីយដ្ឋានទេសចរណ៍ បានដើរតួនាទីយ៉ាងចម្បងក្នុងការចូលរួមចំណែកដល់ការទប់ស្កាត់ និងកាត់បន្ថយបាននូវមួយកំរិតនូវការឡើងកំដៅផែនដី ប្រសិនជាការអភិវឌ្ឍ គ្រប់គ្រងផ្អែកលើទស្សនៈ "រមណីយដ្ឋានទេសចរណ៍ ធម្មជាតិ"។

រមណីយដ្ឋានទេសចរណ៍ ត្រូវបានគេឲ្យជានិយមន័យថា តំបន់គោលដៅ ដែលមានទំនាក់ទំនងបណ្តុំសមាសភាគច្រើន និងផ្តល់មកនូវទំរង់ ឬប្រភេទនៃរូបធាតុសម្បទាទេសចរណ៍ និងសេវា

កម្មជាមួយការរួមបញ្ចូលនូវគំរូរចនាបថសម្រាប់ការកំសាន្ត និង ទស្សនា ដែលអាចនាំឈានដល់ការបង្កើតឡើង សម្រាប់ទីក្រុង ទីប្រជុំជន ឬភូមិ តាមមុខនាទីនៃការទាក់ទាញទេសចរ។

### ១.១.៦ យុទ្ធសាស្ត្រគ្រប់គ្រងទេសចរណ៍

**យុទ្ធសាស្ត្រគ្រប់គ្រងទេសចរណ៍** គឺជាយុទ្ធសាស្ត្រផែនការដែលកំណត់ពីចក្ខុវិស័យ គោលការណ៍ ការវិភាគ និងការស្រាវជ្រាវ ដែលគេដាក់ចេញក្នុងគោលបំណង ពង្រឹងមូលដ្ឋាន និងការអភិវឌ្ឍវិស័យទេសចរណ៍ ប្រកបដោយការទទួលខុសត្រូវ ព្រមទាំងមានប្រសិទ្ធភាព។

### ១.១.៧ ផលិតផល និងសេវាកម្មទេសចរណ៍

ផលិតផល គឺជាទំនិញ សេវាកម្ម គំនិត រឺជាបន្សំណាមួយដែលអាចត្រូវបានផ្គត់ផ្គង់ទៅកាន់ទីផ្សារ សំរាប់ការយកចិត្តទុកដាក់ ការទិញ មកប្រើប្រាស់ រឺចំណាយដែលអាចបំពេញនូវការចង់បានរឺសេចក្តីត្រូវការបាន [6]។

ផលិតផលទេសចរណ៍ ត្រូវបានគេផ្តល់នូវនិយមន័យច្រើនប្រភេទផ្សេងៗគ្នាទៅតាមប្រទេស និងតំបន់នីមួយៗ។ យោងទៅតាមលោក **Burns and Holden (1989:172)** បានឲ្យនិយមន័យថា ផលិតផលទេសចរណ៍ គឺជាផលិតផលទាំងឡាយដែលគេអាចបង្កើតឡើង និងលក់ ដោយរួមបញ្ចូលនូវកត្តាផលិតដូចជា ចំណង់ចំណូលចិត្តអតិថិជន គោលដៅទេសចរណ៍ ព្រមទាំងតំបន់វប្បធម៌ និងតំបន់ទាក់ទាញផ្សេងៗ។

- **Kotler and Armstrong (1989:463)** ផលិតផលទេសចរណ៍ គឺជាផលិតផល ដែលគេផ្តល់ទៅ ឱ្យអ្នកប្រើប្រាស់ ឬចំណែកទីផ្សារដើម្បីបំពេញបំណងប្រាថ្នា និងចំណង់ត្រូវបានរួមបញ្ចូលនូវសេវាកម្ម ធនធានមនុស្ស ការរៀបចំ និងគំនិត រឺផលិតផលថ្មីៗ [7]។

ផលិតផលទេសចរណ៍ គឺជាការរួមបញ្ចូលគ្នានូវទំនិញ (បែបរូបិយ) និង សេវាកម្ម (អរូបិយ) ទំនិញដែលសំដៅលើផលិតផលទាំងឡាយណាដែលយើងអាចកាន់ រឺ ប៉ះបាន មានដូចជា ទីកន្លែងកំសាន្ត គ្រឿងបរិភោគ រីឯទំនិញអរូបិយ មានដូចជាការសំដែងសិល្បៈ មគ្គុទេសក៏ទេសចរណ៍ សេវាកម្មស្នាក់នៅ និងសេវាកម្មដឹកជញ្ជូនជាដើម។

សេវាកម្ម គឺជាកិច្ចព្រមព្រៀង រឺអំពើ (Actions)។ សេវាកម្ម គឺជាសកម្មភាព រឺខ្សែសង្វាក់នៃសកម្មភាព ដែលមានលក្ខណៈអរូបិយតិច រឺច្រើន ហើយតាមធម្មតាតែងប្រព្រឹត្តទៅដោយមានអន្តរ

---

* សេចក្តីផ្តើមទេសចរណ៍ រៀបរៀងដោយ បណ្ឌិត ឈុន ពហុ អនុបណ្ឌិត ជា ស៊ីថា, ហុង វណ្ណៈ, និង សាំង ចន្ធូ បោះពុម្ពថ្ងៃទី០១ តុលា ២០១៤ [6]

* Tourism Product Definition ~ New Atlantis [7]

កម្មរវាងអតិថិជន និងអ្នកបំរើ រវាងទំនិញ រឺធនធានរូបវន្ត័ និងប្រពន្ធ័ផ្គត់ផ្គង់សេវាកម្ម ដើម្បីផ្តល់ដំណោះស្រាយចំពោះបញ្ហារបស់អតិថិជន [៥]។

សេវាកម្មទេសចរណ៍ សំដៅទៅលើការផ្តល់សេវាបន្ថែមទៅលើសេវាកម្មមូលដ្ឋានសំរាប់អ្នកធ្វើដំណើររួមមាន បង្គន់ ទឹក និងអគ្គីសនី សម្ភារៈសំរាប់អាំងសាច់ និងវត្ថុផ្សេងៗទៀត ដែលអ្នកទេសចរអាចត្រូវការ។ សេវាកម្មទេសចរណ៍ទាំងនោះ ទោះបីជាកន្លែងស្នាក់នៅអាចនៅឆ្ងាយពីទីនោះក៏ដោយ។

## ១.២ អត្ថន័យទូទៅនៃការអភិវឌ្ឍ

អ្វីទៅជាការអភិវឌ្ឍ? ការអភិវឌ្ឍគឺជាការធ្វើឲ្យមានភាពប្រសើរ ខ្ពង់ខ្ពស់ និងរីកចំរើន។ សំដៅលើការធ្វើយ៉ាងណាដើម្បីបំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋរស់នៅនាពេលបច្ចុប្បន្នពោលគឺ ធ្វើឲ្យមានជីវភាពល្អប្រសើរក្នុងការរស់នៅប្រកបដោយផាសុខភាព សម្ភារៈប្រើប្រាស់ទាន់សម័យកាលស្របតាមការវិវត្តន៍របស់សង្គម និងពិភពលោក ដែលមានការរីកចំរើនខាងផ្នែកបច្ចេកវិទ្យា។ អត្ថន័យទូទៅ របស់ការអភិវឌ្ឍគឺជាសកម្មភាពដែលឈានទៅសម្រេចបានគោលបំណងបី (១) ការបំពេញបាននូវតំរូវការជាមូលដ្ឋាននៃជីវិត ដូចជា ចំណីអាហារ ទឹកស្អាត អនាម័យ សុខភាព ជម្រកនឹងសោភណ្ឌភាព ការគោរពស្រលាញ់ ការសរសើរ និងការគាំពារ។ (២) ការលើកកំពស់កម្រិតជីវភាពរស់នៅដូចជាការបង្កើនចំណូល ការងារ និងការអប់រំបន្ថែម ការយកចិត្តទុកដាក់ខ្ពស់លើតំលៃវប្បធម៌ តំលៃជាមនុស្ស ការបំពេញបាននូវសុខុមាលភាពខាងសម្ភារៈ និងការគោរពខ្លួនឯង។ (៣) ការពង្រីកដែនសេដ្ឋកិច្ច និងជម្រើសសម្រាប់បុគ្គល និងមនុស្សទូទៅ ដូចជាការរំដោះមនុស្សឲ្យចេញពីភាពល្ងង់ខ្លៅ និង ទុរគតភាព។

យោងទៅតាមអត្ថន័យខាងលើ **ការអភិវឌ្ឍ** គឺជាការបង្កើត រឺច្នៃប្រឌិតអ្វីដែលមិនទាន់មានឈានទៅរកអ្វីដែលមាន។ សំដៅដល់ កែប្រែតំបន់ និងផលិតផលមួយ ឲ្យកាន់តែមានភាពប្រសើរឡើងពោល គឺជាការផ្លាស់ប្តូរនូវអ្វី ដែលអាចជាឥទ្ធិពលដល់សង្គម សេដ្ឋកិច្ចជាតិ ជីវភាពប្រជាពលរដ្ឋជាដើម។

**អ្នកសេដ្ឋកិច្ចអង់គ្លេសសាក់សុង** "ការអភិវឌ្ឍន៍ គឺជាដំណើរការឈានឡើងគ្មានឈប់ឈររបស់សេដ្ឋកិច្ចដែលនាំទៅរកការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំមួយសំរាប់ធ្វើឲ្យដំណើរការផ្សេងៗទៀត មានការជឿនលឿនទាំង ផ្នែកស្មារតី និង សំភារៈរបស់មនុស្សគ្រប់ៗរូបនៅក្នុងសង្គម"។

[៥]ការគ្រប់គ្រងសេវាកម្ម សាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី (២០១២) [៥]

មានន័យថា ការអភិវឌ្ឍផ្តោតសំខាន់ទៅលើផលិតផលក្នុងស្រុក ផលិតផលជាតិសរុប ការបែងចែកសំរាប់ប្រជាពលរដ្ឋម្នាក់ៗ ចំណូលរួម និងការប្រែប្រួលរបស់វា។

**ក្រុមសេដ្ឋកិច្ចវិទូប្រាំងកូហ្វូនី** "អភិវឌ្ឍន៍ គឺជាដំណើរការប្រែក្លាយនូវផ្នត់គំនិតឥទរិយាបថ ទំនាក់ទំនងរវាងមនុស្ស និងមនុស្ស ដែលនាំទៅសាងនូវមូលដ្ឋានគ្រឹះរឹងមាំមួយក្នុងការធ្វើឲ្យមានកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង"។ មានន័យថា ការអភិវឌ្ឍត្រូវផ្តោតទៅលើវិធានសង្គមទាំងមូលកត្តាសង្គម និងលក្ខខណ្ឌសង្គម កត្តាទស្សនៈវិជ្ជា រឺ ទស្សនៈអភិវឌ្ឍន៍ រឺកត្តាមូលដ្ឋានសេដ្ឋកិច្ច[៦]។

### ១.២.១ ការអភិវឌ្ឍសហគមន៍

ការអភិវឌ្ឍសហគមន៍ចាត់ទុកការអភិវឌ្ឍជាការអភិវឌ្ឍធនធានមនុស្ស និងជាលទ្ធផលដែលផ្តោតលើការរៀនសូត្ររបស់បុគ្គល និងការកសាងសមត្ថភាពជារួមបន្ថែមលើការរីកលូតលាស់សេដ្ឋកិច្ច។គំនិតដែលការចូលរួមក្នុងការសំរេចចិត្ត នៅក្នុងសហគមន៍នាំមកនូវការសិក្សារៀនសូត្រដែលពង្រីកទស្សនរបស់បុគ្គលដែលចូលរួម ជាការផ្តល់ត្រលប់មកវិញនូវធនធានដ៏ច្រើនដល់សហគមន៍សំរាប់ការខំប្រឹងខ្នះខ្នែងដ៏មានសក្តានុពលទៅថ្ងៃអនាគត។ ការប៉ុនប៉ងក្នុងការអភិវឌ្ឍសហគមន៍មានការកើនឡើងដែលមានគោលដៅបន្តនូវការអភិវឌ្ឍសមត្ថភាពរបស់សមាជិកសហគមន៍។

**ការអភិវឌ្ឍសហគមន៍** ជាដំណើរការសំរាប់ការផ្តល់អំណាច និងការផ្លាស់ប្តូរ។ ការផ្តោតអារម្មណ៍ទៅលើការអភិវឌ្ឍសហគមន៍គឺដើម្បីស្វែងរកនិងដោះស្រាយបញ្ហាសង្គម នយោបាយដែលមាននៅក្នុងសហគមន៍តាមរបៀបដែលលក្ខខណ្ឌទាំងនេះត្រូវបានផ្លាស់ប្តូរ ឬក៏ធ្វើឲ្យបានល្អប្រសើរពីទស្សនរបស់សមាជិកសហគមន៍។ គោលបំណងនៃការអភិវឌ្ឍសហគមន៍ គឺការជួយខ្លួនឯង ការកសាងសមត្ថភាពសហគមន៍ និងការរួបរួម។

### ១.២.២ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព

#### ក. និយមន័យ

ពាក្យអភិវឌ្ឍន៍ បានវិវត្តពីន័យចង្អៀត និងឈានទៅកាន់តែទូលំទូលាយទៅ។ សម្តេចសង្ឃរាជ ជួន ណាត ក្នុងវចនានុក្រមរបស់គាត់បានពន្យល់ថា អភិវឌ្ឍគឺចម្រើនក្រៃលែង និងលូតលាស់ចម្រើន។ Encarta Dictionary បញ្ជាក់ថា អភិវឌ្ឍ គឺជាហេតុការណ៍មួយដែលនាំឲ្យ ឬបណ្តាលឲ្យសភាពការណ៍ មួយមានការផ្លាស់ប្តូរឬមានការរីកចម្រើន។ តាមការស្រាវជ្រាវរបស់សាស្ត្រាចារ្យបណ្ឌិត សួន វ៉ានី យល់ថាអភិវឌ្ឍគឺជាការកែប្រែ អ្វីដែលមិនទាន់មានឲ្យមាន និងកែប្រែអ្វីដែលមិន

*ការគ្រប់គ្រង និង អភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ បណ្ឌិត ឯក រដ្ឋា ~ គឹម ប៊ុនណារ៉ា អនុបណ្ឌិត ឯម ខេឌី ~ នួន សារី (២០១២) [៦]

ទាន់ល្អឲ្យល្អ ឧទាហរណ៍ កែប្រែ មនុស្ស និងធនធានមនុស្ស កែប្រែសម្ភារ និងមធ្យោបាយប្រើប្រាស់ កែប្រែរៀបប្រើប្រាស់នូវបណ្តាធនធានធម្មជាតិ ឲ្យកាន់តែប្រើសើរឡើង [10]។

**អភិវឌ្ឍន៍** សំដៅដល់ការធ្វើសកម្មភាពទាំងឡាយណាលើធនធាន ដែលមានក្នុងសហគមន៍ប្រែក្លាយ បំរើផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច សង្គមជាចំបងនិងសេចក្តីត្រូវការជីវភាពរស់នៅរបស់ប្រជាជន។ មានន័យថា ការអភិវឌ្ឍលើធនធានដែលមានក្នុងសហគមន៍ ដើម្បីទាញយកផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច និងអភិវឌ្ឍសង្គមរស់នៅរបស់ប្រជាពលរដ្ឋឲ្យមានភាពល្អប្រសើរ និងរួចផុតពីភាពអត់ឃ្លាន ។

**ការអភិវឌ្ឍ** គឺជាដំណើរការពហុមាត្រាដ្ឋាន រួមបញ្ចូលនូវការផ្លាស់ប្តូរ និងការវិវឌ្ឍទាំងបរិមាណនិងទាំងគុណភាព។ ការអភិវឌ្ឍគឺធ្វើយ៉ាងណាឲ្យសង្គមមួយ មានការរីកចម្រើនលូតលាស់ជឿនលឿនលើគ្រប់វិស័យ ដូចជាប្រព័ន្ធរដ្ឋបាល នយោបាយ រចនាសម្ព័ន្ធ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌។

**និរន្តភាព** គឺជាពាក្យមួយដែលមានន័យយូរអង្វែង ឬរស់នៅជាហូរហែរហូតទៅ។ ពាក្យនេះត្រូវបានពិភពលោកចាប់អារម្មណ៍ ដោយហេតុផលថាការអភិវឌ្ឍជាច្រើន ត្រូវបានគេជំរុញដើម្បីបំពេញបំណងបច្ចុប្បន្ន ហើយភ្លេចដល់អនាគត និងថាការអភិវឌ្ឍជាច្រើនត្រូវបានគេជំរុញដើម្បីបំពេញបំណងបច្ចុប្បន្ន ដោយរៀបចំគិតគូរ មិនបានត្រឹមត្រូវ។ ទីបំផុត ការអភិវឌ្ឍមួយចំនួននោះ ដើរយឺត និងមានលក្ខណៈជាការបំផ្លាញច្រើនជាង។ ហេតុផលនេះបាននាំឲ្យពាក្យនិរន្តភាព ត្រូវបានចាប់អារម្មណ៍ជាចម្បង និងជាថាក្នុងគ្រប់ការអភិវឌ្ឍគេត្រូវតែគិតគូរដល់និរន្តរភាព។

**និរន្តភាព** សំដៅដល់ភាពស្មើគ្នា ឥតលម្អៀងរវាងការអភិរក្ស ៖ ធនធានធម្មជាតិ វប្បធម៌ប្រវត្តិសាស្ត្រ បរិស្ថាន និងផលប្រយោជន៍បម្រើឲ្យសេដ្ឋកិច្ច-សង្គម និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ មានន័យថា ដើម្បីឲ្យមាននិរន្តភាពធនធានសហគមន៍ គឺមិនធ្វើសកម្មភាពអ្វីទាំងអស់ក្នុងសហគមន៍ ទាំងការប្រើប្រាស់ក្នុងន័យផលប្រយោជន៍ និងសកម្មភាពអ្វីទាំងអស់ក្នុងសហគមន៍ ទាំងការប្រើប្រាស់ក្នុងន័យផលប្រយោជន៍ និងសកម្មភាពអសកម្មផ្សេងៗពីសំណាក់មនុស្ស។ អ្វីៗគ្រប់យ៉ាងត្រូវបានរក្សាភាពដើម។

ទស្សនៈស្តីពី និរន្តភាពនៃការអភិវឌ្ឍ ត្រូវបានកត់សម្គាល់ជាលើកដំបូងនៅក្នុងកំឡុងឆ្នាំ ១៩៨៧ នៅក្នុងរបាយការណ៍មួយ ចេញផ្សាយដោយគណៈកម្មាធិការពិភពលោកស្តីពីបរិស្ថាន និងការអភិវឌ្ឍ។ តាមការស្រាវជ្រាវ និងពិនិត្យរបាយការណ៍ គេឃើញថាពាក្យ **ការអភិវឌ្ឍប្រកបដោយ**

---

* វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា -ការអភិវឌ្ឍកសិទេសចរណ៍នៅរមណីយដ្ឋានពិកនិកស្រុកកំពង់សិលា ខេត្តព្រះសីហនុ (២០១៦) [10]

**និរន្តរភាព** ត្រូវបានផ្តល់និយមន័យឲ្យថា ការអភិវឌ្ឍដែលធ្វើឲ្យសម្រេចបាននូវសសេចក្តីត្រូវការនាពេលបច្ចុប្បន្ន ដោយពុំបានធ្វើឲ្យបាត់បង់នូវសមត្ថភាព ហើយអាចផ្តល់ឲ្យអ្នកជំនាន់ក្រោយទទួលបានផលប្រយោជន៍តាមសេចក្តីត្រូវការរបស់គេដែរ។

ក្រោយឆ្នាំ ១៩៩២ ប្រទេសជាច្រើនលើពិភពលោក បានកំណត់យក និរន្តរភាព ធ្វើជាគោលនយោបាយអភិវឌ្ឍដ៏សំខាន់បំផុត និងក្នុពេលតែមួយនោះ អង្គការទេសចរណ៍ពិភពលោក (UNWTO) បានចាប់ផ្តើមជ្រើសរើសយកនីតិវិធីនៃនិរន្តរភាព មកអនុវត្តចំពោះវិស័យទេសចរណ៍ និងដាក់គោលការណ៍អភិវឌ្ឍប្រកដដោយនិរន្តរភាពទៅក្នុងគ្រប់ផែនការនិងការអភិវឌ្ឍទេសចរណ៍ទាំងអស់។ UNWTO បានអះអាងថា ការអភិវឌ្ឍទេសចរណ៍ប្រកដដោយនិរន្តរភាព គឺជាការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ទេសចរ និងម្ចាស់ស្រុកក្នុងតំបន់នាពេលបច្ចុប្បន្នដោយមានការការពារ និងបង្កើតជាឱកាសសម្រាប់ប្រើប្រាស់នាពេលអនាគត។ និរន្តរភាព ត្រូវបានគេគ្រោងសម្រាប់ជាគោលសំខាន់ ដើម្បីធ្វើការគ្រប់គ្រងបណ្តាធនធាននានា និងក្នុងនោះវាត្រូវបានចាត់ថាជាវិធានការមួយ ដើម្បីបំពេញនូវសេចក្តី ត្រូវការខាងសេដ្ឋកិច្ច សង្គម និងសោភ័ណភាព ដែលអាចជួយធ្វើឲ្យមានភាពគង់វង្សនៃវប្បធម៌ ដំណើរនៃប្រព័ន្ធអេកូឡូស៊ី ជីវៈចម្រុះ និងប្រព័ន្ធទ្រទ្រង់ជីវិតដទៃទៀត។

**ការអភិវឌ្ឍប្រកបដោយនិរន្តភាព** សំដៅដល់ការអភិវឌ្ឍទាំងឡាយណា ដែលគិតគូរដល់ផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច សង្គម និងគិតគូរដល់ការការពារ និង អភិរក្សធនធានដែលមានក្នុងសហគមន៍ផងដែរ។ មានន័យថា គោលដៅអភិវឌ្ឍន៍ គឺសំដៅទាញយកផលប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច សង្គម និងគិតគូរដល់ការការពារ និង អភិរក្សធនធានដែលមានក្នុងសហគមន៍ផងដែរ។ មានន័យថា គឺជាការអភិវឌ្ឍន៍ដែលមិនមានការគំរាមកំហែងនៅថ្ងៃអនាគត ម្យ៉ាងគោលដៅអភិវឌ្ឍន៍ គឺសំដៅទាញយកផលប្រយោជន៍បម្រើខាងផ្នែកសេដ្ឋកិច្ច-សង្គម តែត្រូវធ្វើយ៉ាងណាឲ្យការអភិវឌ្ឍនោះ គិតគូរដល់ការបាត់បង់លើធនធានធម្មជាតិ វប្បធម៌ ប្រវត្តិសាស្ត្រ និង បរិស្ថានក្នុងកំរិតមួយតិចតួចបំផុត ដោយធានាថាមិនធ្វើឲ្យមានការខាតបង់ រឺបាត់បង់ផលប្រយោជន៍ប្រជាពលរដ្ឋ និងទេសចរដោយមិនមានការគំរាមគំហែងនៅថ្ងៃអនាគត។

## ១.៣ ទស្សនទានអំពីកសិទេសចរណ៍

ផ្អែកទៅលើឯកសារដែលចេញដោយក្រសួងទេសចរណ៍ប្រទេសកម្ពុជា (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ ២០១២ - ២០២០) បានបង្ហាញនូវចក្ខុវិស័យច្បាស់លាស់ និងយូរអង្វែងសំរាប់ការអភិវឌ្ឍន៍ទេសចរណ៍កម្ពុជា ដោយផ្អែកទៅលើធនធាន "វប្បធម៌និងធម្មជាតិ"។ ទេសចរណ៍

វប្បធម៌ត្រូវបាន គេផ្តល់អាទិភាពខ្ពស់ក្នុងការអភិវឌ្ឍន៍កម្ពុជា ព្រមជាមួយនឹងការធ្វើឲ្យប្រសើរឡើង អេកូ-ទេសចរណ៍ដែលជាចក្ខុវិស័យ និងជាគោលដៅទេសចរណ៍ថ្មីរួមចំណែកដល់ការទប់ទល់បម្រែបម្រួលអាកាសធាតុសកលផង និងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតងផងដែរ។

វិស័យកសិទេសចរណ៍ នៅបរទេសត្រូវបានគេស្គាល់ផងដែរថាជា "អេកូទេសចរណ៍" រឺ "ទេសចរណ៍បៃតង", "ទេសចរណ៍កសិកម្ម", "ទេសចរណ៍តាមជនបទ"ជាដើម។ ទេសចរណ៍ប្រភេទនេះជាផលិតផលទេសចរណ៍ថ្មី ដែលត្រូវបានគេរួមគ្នារវាងទេសចរណ៍ និងកសិកម្ម ដោយបានចូលរួមចំណែកយ៉ាងខ្លាំងក្នុងការលើកកំពស់វិស័យកសិកម្ម និងសម្រេចបាននូវសេដ្ឋកិច្ច កសិកម្មចម្រុះនៅតាមតំបន់ជនបទ ហើយព្រមទាំងក្លាយជាផ្នែកសំខាន់មួយ នៃការធ្វើឱ្យប្រសើរឡើងសំរាប់ផ្នែកឧស្សាហកម្មទេសចរណ៍។ កសិទេសចរណ៍ មានប្រវត្តិយូរលង់ណាស់ហើយនៅតាមបណ្តាទ្វីបអឺរ៉ុប ដូចជា ប្រទេសអាល្លឺម៉ង់ បារាំង អង់គ្លេស អ៊ីតាលី អេស្ប៉ាញ -ល- ហើយ ចំនេរក្រោយមកទើបមានការរីករាលដាលមកទ្វីបអាស៊ី ដូចជា ជប៉ុន កូរ៉េ សឹង្ហបុរី និងចិនតៃវ៉ាន់ជាដើម។ ការអភិវឌ្ឍវិស័យទេសចរណ៍បែបកសិកម្មរបស់ប្រទេសរីកចំរើនមួយចំនួន ជាបទពិសោធដ៏មានតម្លៃ មានភាពសក្តិសមសំរាប់យើងយកមកសិក្សាស្រាវជ្រាវក្នុងការអភិវឌ្ឍន៍ វិស័យកសិទេសចរណ៍កម្ពុជាឲ្យរីកចំរើនបាន [11]។

**ក.និយមន័យ**

កសិទេសចរណ៍ អាចហៅថា Agricultural tourism ឬ Ago tourism មានប្រវត្តិយូរលង់ណាស់មកហើយក្នុងទ្វីបអឺរ៉ុប កសិទេសចរណ៍ភាគច្រើនមាននៅតាមតំបន់កសិដ្ឋាន ដែលគេនាំភ្ញៀវទេសចរទៅទស្សនាកំសាន្តកន្លែងចិញ្ចឹមសត្វ សួនបន្លែ និងចំការផ្លែឈើ ជាពិសេសចំការទំពាំងបាយជូរ ទេសចរអាចចូលរួមសកម្មភាពផ្សេងៗ ដែលរៀបចំដោយកសិដ្ឋាន រឺ ទិញផលិតផលកសិកម្មទាំងនោះជាដើម។

យោងទៅតាមឯកសារដែលចេញផ្សាយជាភាសាចិនរបស់ Chinese Journal of Agricultural Resources and Regional Planning (Guo Huan Cheng- Beijing:2010) បានឲ្យនិយមន័យ **កសិទេសចរណ៍** គឺជាទេសចរណ៍ដែលពឹងផ្អែកទៅលើធនធានធម្មជាតិ និង កសិកម្ម រួមមាន ការដើរទស្សនាទេសភាពវាលស្រែ ផលិតផលកសិកម្ម វប្បធម៌ក្នុងការធ្វើស្រែ កសិដ្ឋាន បច្ចេកទេសកសិកម្ម កសិកម្មអេកូឡូស៊ី របៀបរបបរស់នៅ/រចនាបទ របស់ប្រជាជនក្នុងតំបន់ជនបទ និងលក្ខខណ្ឌធនធានធម្មជាតិ សំរាប់ផ្តល់ឲ្យអ្នកទេសចរទីក្រុងបានគយគន់ សំរាកលំហែ ទទួលបានបទពិសោធន៍ ការអប់រំ ការកំសាន្ត និង សេវាកម្មកសិ អាជីវកម្ម ជាដើម។

---

♣ http://lokatourconsultant.blogspot.com/2013/04/tourism-product-definition.html

Chinese Academy Agricultural science- 农业旅游发展的国际经验[11]

សំរាប់ប្រជាជនក្នុងសហគមន៍**កសិទេសចរណ៍** គឺជាការរួមបញ្ចូលវិស័យកសិកម្ម និង វិស័យទេសចរណ៍ បង្កើតជាទេសចរណ៍ប្រភេទថ្មីមួយ ដែលមានការរួមបញ្ចូលចំនុចធំៗបី គឺ "ការផលិត ប្រពន្ធ័អេកូឡូស៊ី និងការរស់នៅ" បង្កើតជាទេសចរណ៍ បែបកសិកម្មមួយយ៉ាងល្អឯក។

**កសិទេសចរណ៍** គឺជាប្រភេទទេសចរណ៍ដែលរួមបញ្ចូល កសិកម្ម និង អេកូទេសចរណ៍ ប្រើប្រាស់ទេសភាព ផលិតកម្មកសិកម្ម បរិស្ថាន កសិកម្មជនបទ និងគំរូអាជីវកម្មដើម្បីទាក់ទាញភ្ញៀវទេសចរឱ្យចូលមកទស្សនានិងរីករាយជាមួយ ការអប់រំ យល់ដឹង បទពិសោធ សម្បទា ការការពារបរិស្ថាន វិស្សមកាល ទិញកសិផលពីចំការផ្ទាល់ជាដើម [12]។

**ទេសចរណ៍កសិកម្ម** គឺជានិន្នាការទូទាំងពិភពលោកដែលអាចឱ្យអ្នករស់នៅទីក្រុង នូវឱកាសដើម្បីគេចពីបរិយាកាសដ៏ស្មុគស្មាញនៅតាមទីក្រុង និងទទួលបានបរិយាកាសស្រស់ស្រាយនៅតំបន់ជនបទ។

"ទេសចរណ៍កសិកម្ម" រួមបញ្ចូលទាំងសកម្មភាពសេដ្ឋកិច្ចនិងសង្គមដែលកើតឡើងនិងផ្សារភ្ជាប់វិស័យទេសចរណ៍ជាមួយនឹងផលិតផលសេវាកម្ម និងបទពិសោធន៍កសិកម្ម។ ទេសចរណ៍កសិកម្មគឺជាប្រភេទនៃវិស័យទេសចរណ៍ ដែលមានការកើនឡើងនៃប្រជាប្រិយភាពក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ។ ទេសចរណ៍កសិកម្មគឺជាទីផ្សារថ្មីមួយសម្រាប់ទេសចរ វាអនុញ្ញាតឱ្យប្រជាពលរដ្ឋអាចមានបទពិសោធន៍រស់នៅផ្ទះក្នុងកសិដ្ឋាន ដើម្បីទទួលបានចំនេះដឹងមើលទម្លាប់ការងារនិងសកម្មភាពដែលត្រូវបានធ្វើនៅក្នុងអាជីវកម្មកសិកម្មជារៀងរាល់ថ្ងៃ។ នេះគឺជាឱកាសដ៏ល្អសម្រាប់មនុស្សជាច្រើនដែលចង់មានបទពិសោធន៍របៀបរស់នៅដែលខុសពីបរិបទរស់នៅរបស់ពួកគេជា មួយភាពស្រស់ស្អាត និងស្ងប់ស្ងាត់នៅក្នុងតំបន់ជនបទ។

**ការអភិវឌ្ឍកសិទេសចរណ៍ប្រកបដោយនិរន្តភាព** គឺជាទម្រង់ឬសកម្មភាពទាំងឡាយណាដែលពាក់ព័ន្ធជាមួយសកម្មភាព ឬផលិតផលកសិកម្មហើយអាចបំពេញបាននូវសេចក្តី ត្រូវការរបស់ប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន និងទេសចរនាពេលបច្ចុប្បន្នដោយធានា ថាធ្វើឲ្យមានការខាតបង់ ឬបាត់បង់ផលប្រយោជន៍ប្រជាពលរដ្ឋ និងទេសចរ និងមិនមានការគំរាមកំហែងនៅថ្ងៃអនាគត។

យោងតាមសៀវភៅកសិទេសចរណ៍របស់បណ្ឌិត គឹម ប៉ុណ្ណារ៉ា ឆ្នាំ២០១៥ ការអភិវឌ្ឍកសិទេសចរណ៍ប្រកបដោយនិរន្តរភាព គឺជាគំនិតថ្មីមួយនៃសកម្មភាពរបស់ទេសចរណ៍នេះ
វិស័យទេសចរណ៍ប្រកដោយនិរន្តរភាព ការសញ្ជ័យរបស់ផ្នែកទីផ្សារជាមួយនឹងទម្រង់អេកូឡូស៊ីដែលបានសម្គាល់។

កសិទេសចរណ៍ ជាទំរង់ពិសេសមួយនៃទេសចរណ៍ដែលភ្ញៀវទេសចរ ត្រូវបាននាំទៅទស្សនាកំសាន្ត និងស្វែងយល់ពីសកម្មភាពធ្វើកសិកម្ម និងជីវភាពរស់នៅរបស់ប្រជាកសិករនៅក្នុងតំបន់ណាមួយ ដោយអាចធ្វើដំណើរកំសាន្តវិលល្ងាច រឺស្នាក់នៅគោលដៅនោះ។

### ១.៣.១ ប្រភេទនៃកសិទេសចរណ៍

កសិទេសចរណ៍ មានច្រើនប្រភេទទៅតាមការច្នៃប្រឌិតគំនិតបែបថ្មីៗ ឲ្យចេញជាទំរង់ទេសចរណ៍មួយដែលអាចទាក់ទាញឲ្យចូលមកទស្សនាកំសាន្ត។ ប្រភេទកសិករទេសចរ ភាគច្រើនដែលពេញនិយមមានដូចជា [12]៖

- កសិដ្ឋានបន្លែ ផ្លែឈើ
- កសិដ្ឋានចិញ្ចឹមសត្វ
- រមណីយដ្ឋានចំការផ្កា
- កន្លែងស្នូចត្រី

កសិទេសចរណ៍ប្រភេទដែលកំពុងពេញនិយមនៅក្នុងទ្វីបអឺរ៉ុប ដែលអាចផ្តល់ចំនូលដល់កសិដ្ឋាន ប្រភេទកសិទេសចរណ៍បែបនេះ កំពុងក្លាយជាតំរូវការរបស់ទេសចរណ៍ជាច្រើន។

✓ ការធ្វើស្រូវ (Rice Cultivation) មិនថាជាការធ្វើស្រូវប្រាំង រឺ វស្សា ការសាបសំនាប ស្ទូង ច្រូត បោករឺបុក ស្រូវ ដោយការនាំអ្នកទេសចរណ៍ទៅមើលរបៀបនៃការធ្វើស្រែ ព្រមទាំងអនុវត្តសកម្មភាពដូចជាអ្នកស្រែ ទាំងការស្នាក់នៅ ម្ហូបអាហារ កំពុងក្លាយជាប្រភេទទេសចរណ៍មួយដ៏ល្បីនៅប្រទេសក្រៅ។

✓ សួនច្បារ (Cutting Flowers) សួនផ្កាគឺជា វិស័យកសិទេសចរណ៍មួយទៀតដែលទទួលបានការពេញនិយមយ៉ាងខ្លាំងនៅតាមបណ្តាប្រទេសអឺរ៉ុប និង ប្រទេសអាស៊ីមួយចំនួន។ ដូចជា ផ្កាអ័រគីដេ ផ្កាឈូករ័ត្ន ដែលជាប្រភពនៃសុភមង្គល រីករាយជាមួយនិងធម្មជាតិ គឺជាកន្លែងរូបថតមួយ គំនូរ ឬសូម្បីតែការផ្តល់នូវចំណេះដឹង និងការសិក្សា។

✓ សួនផ្លែឈើ (Horiculture) ប្រភេទកសិទេសចរណ៍គឺជាដែលនិយមយ៉ាងខ្លាំង ដែលមានទាំងការចូលទស្សនា និងការទិញផ្លែឈើពីកសិដ្ឋានផ្ទាល់ ដែលអាចផ្តល់ចំនូលបន្ថែមដល់កសិករច្រើនជាងការលក់ផលិតផលទៅតាមទីផ្សារទៀតផងដែរ។ ចំការកសិទេសចរណ៍ដែលកំពុងពេញនិយមរួមមាន ចម្ការសារម៉ាវ មៀន ក្រូច និង ចម្ការទំពាំងបាយជូរ ។

* http://www.farmthailand.com/163 **การท่องเที่ยวเชิงเกษตร**[12]

✓ សួនបន្លែ (Vegetables) គឺជាកន្លែងទេសចរណ៍ដែលគេនិយម ក្នុងសួនមានប្រភេទបន្លែជាច្រើនដែលគេហៅថាជាបន្លែ អូកានិច គ្មានជាតិគីមី។

✓ សួនឪសថបុរាណ (Herbs) ដែលជាទូទៅអាចនិងមាននៅតាមសួនបន្លែមួយចំនួន រឺ គឺជាការដាំជាប្រភេទជារុក្ខជាតិឃិន សុិន ដើម្បីលក់ឲ្យភ្ញៀវដែលមានតំរូវការឪសថរុក្ខជាតិ ។

✓ កសិដ្ឋានចិញ្ចឹមសត្វ (Animals Farming) ជាប្រភេទកសិដ្ឋានចិញ្ចឹមដូចជាសេះ ចៀម គោក្របី រឺប្រភេទសត្វចិញ្ចឹមផ្សេងៗ ដែលគេអាចលក់ជាពូជសត្វ រឺ ផលិតផលដែលបានពីសត្វនានា។

✓ ការតាំងពិពណ៌កសិកម្ម ការចាត់ដែលឲ្យមានពិពណ៌ពាក់ពន្ធ័និងផ្លែឈើ និងបន្លែជាដើម បណ្តាប្រទេសជាច្រើនមានការចាត់ឲ្យមាន ក្រូច ប៉េងប៉ោះ និង ស្រាទំពាំងបាយជូរជាដើម ដែលជាឱកាសអាចឲ្យភ្ញៀវបរទេសចូលមកទស្សនានិង ទទួលស្គាល់គុណភាពផ្លែឈើបានយ៉ាងមានប្រសិទ្ធភាព ព្រមទាំងអាចពង្រីកទីផ្សារបរទេសទៀតផង ។

## ១.៤ សារៈប្រយោជន៍ដែលទទួលបានពីការអភិវឌ្ឍឲ្យក្លាយទៅជាតំបន់កសិទេសចរណ៍

### ១.៤.១ សារៈប្រយោជន៍នៃកសិទេសចរណ៍

**Agricultural Tourism** ជាប្រភេទទេសចរណ៍ថ្មីមួយ ដែលជួយលើកស្ទួយជីវភាពគ្រួសារកសិករដែលមានកសិដ្ឋានច្រើនក្នុងការបន្តប្រពៃណីធ្វើកសិកម្មរបស់ពួកគេមិនតែប៉ុណ្ណោះកសិទេសចរណ៍ ក៏មានប្រយោជន៍ដូចជា៖

- ធ្វើឲ្យតំលៃផលិតផលកសិកម្មមានតុល្យភាព
- បង្កើតការងារក្នុងសហគមន៍
- បង្កើនប្រាក់ចំណូល
- លើកកំពស់កម្មវិធីរបស់រាជរដ្ឋាភិបាល
- ជួបនិងតំរូវការក្នុងទីផ្សារទេសចរណ៍
- មានការលើកទឹកចិត្តផ្នែកពន្ធដារ ឲ្យមានការកាត់បន្ថយពន្ធដារ
- ធ្វើឲ្យមានការចាប់អារម្មណ៍ចំពោះការអភិវឌ្ឍ
- ធ្វើឲ្យមានការប្រើប្រាស់ធនធានស្រែចំការឲ្យកាន់តែប្រសើរឡើង
- ការស្ទាបស្ទង់ផ្នែកកសិកម្ម ជាហេតុធ្វើឲ្យមានភាពជោគជ័យដល់ផ្នែកដទៃទៀត

✷ **សារៈសំខាន់ចំពោះប្រទេសជាតិ**

- កាត់បន្ថយការផ្លុះផ្លាយសេដ្ឋកិច្ច ផ្នែកទេសចរណ៍ តាមរយៈការលក់ផលិតផលកសិកម្ម
- កំណើនប្រាក់ចំនូលជាតិ

- លើកកំពស់វិស័យទេសចរណ៍ និង កសិកម្ម ក្នុងប្រទេស
- កាត់បន្ថយការនាំចូលផលិតផលកសិកម្មពីប្រទេសក្រៅ
- ធ្វើឲ្យកសិកម្មក្នុងប្រទេសមានលក្ខណស្តង់ដារ
- កំណើនភ្ញៀវទេសចរ ជាតិ និង អន្តរជាតិ

✷ សារៈសំខាន់ចំពោះប្រជាជនមូលដ្ឋាន

- កំណើនប្រាក់ចំនូល តាមការលក់ផលិតផលកសិកម្ម ទៅឲ្យភ្ញៀវទេសចរ
- បង្កើនអត្រាការងារ
- កាត់បន្ថយការធ្វើចំណាកស្រុកទៅប្រទេសក្រៅ
- បង្កើនចំនេះដឹង ការសិក្សាស្រាវជ្រាវ និង គំនិតបង្កើតថ្មី (បច្ចេកទេសខាងកសិកម្ម)
- លើកកំពស់ស្នាដៃផលិតផល ផលិតដោយកសិករ
- បណ្តុះឲ្យមានស្មារតី និង មនសិការក្នុងការអភិវឌ្ឍន៍
- ទទួលបានចំនេះដឹងថ្មីៗ និង បង្កើនការទំនាក់ទំនង រវាងប្រជាជនក្នុងសហគមន៍

✷ សារៈសំខាន់ចំពោះអ្នកទេសចរ

- ទទួលបានបទពិសោធន៍ ចំនេះដឹង និង របៀបរស់នៅរបស់ប្រជាជនក្នុងសហគមន៍
- ទទួលបានការសំរាកលំហែនៅតំបន់ធម្មជាតិ
- យល់ដឹងពីការផលិតផលកសិកម្មក្នុងតំបន់
- អភិវឌ្ឍន៍ទីផ្សារអ្នកប្រើប្រាស់ថ្មី
- បន្ថែមប្រាក់ចំនូលដោយផ្ទាល់ដល់គ្រួសារដែលធ្វើការក្នុងកសិដ្ឋាន
- ចូលរួមចំណែកក្នុងការបង្កើនស្មារតី និងលើកទឹកចិត្ត ដល់ការដាំផលិតផលកសិកម្មក្នុងស្រុក។

**១.៤.២ ផលប៉ះពាល់ដែលបណ្តាលពីកសិទេសចរណ៍**

ទន្ទឹមនឹងភាពជោគជ័យ ការអភិវឌ្ឍកសិទេសចរណ៍ក៏អាចទទួលរងនូវផលប៉ះពាល់អវិជ្ជមានមួយចំនួនផងដែរ ទៅលើប្រជាជនក្នុងតំបន់ ឬប្រជាជនក្នុងសហគមន៍។ គម្រោងសម្រាប់កសិទេសចរណ៍ទាមទារឲ្យមានការយកចិត្តទុកដាក់ទៅលើផលប៉ះពាល់តំបន់ជិតខាង និងការប្រកួតប្រជែងនឹងសហគមន៍កសិកម្ម។ អ្នកស្រុកតែងតែមានការបារម្ភអំពីឥទ្ធិពលនៃសម្លេងរំខាន ចរាចរណ៍ និងអ្នករំលោភបំពាន ពីព្រោះផលប៉ះពាល់ទាំងនេះមានឥទ្ធិពលក្នុងការផ្លាស់ប្តូរ អាកប្បកិរិយានៃសហគមន៍ទាំងមូល។ ចំពោះការរំខានដោយសម្លេង វាបង្កឡើងដោយសម្លេងរថយន្ត សម្លេងនៃឧបករណ៍សម្រាប់ប្រតិបត្តិការកសិកម្ម សម្លេងម៉ាស៊ីនផ្សេងៗ ពិតជាជះឥទ្ធិពលយ៉ាងខ្លាំង ដល់ការរស់នៅប្រចាំថ្ងៃរបស់

ប្រជាជននៅទីនោះ។ ការកើនឡើងនៃចរាចរណ៍អាចជាការព្រួយបារម្ភរបស់ម្ចាស់ដីដែលនៅជិតខាងផងដែរ។ រដ្ឋាភិបាលគួរតែរៀបចំកំណត់នូវចំនួនយានយន្ត និងការគិតទុកមុននៃការប្រើប្រាស់ផ្លូវសាធារណៈ ដែលវាអាចនឹងជះឥទ្ធិពលទៅលើចរាចរណ៍។ បន្ថែមពីនេះទៀតការប្រតិបត្តិកសិទេសចរណ៍តម្រូវឲ្យមានកន្លែងចតរថយន្តគ្រប់គ្រាន់។ ការរំលោភបំពាន គឺជាក្តីបារម្ភទាំងកសិ-ទេសចរណ៍ និងម្ចាស់ដីជិតខាង។ ដើម្បីជៀសវាងមានការរំលោភបំពាន យើងត្រូវមានការត្រួតពិនិត្យទីតាំងនោះឲ្យបានត្រឹមត្រូវ។

៦. ផលប៉ះពាល់របស់កសិទេសចរណ៍ទៅលើវិស័យផ្សេងៗ

ការអភិវឌ្ឍតែងតែមានផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានទៅលើវិស័យផ្សេងៗ ដូចជា៖

- **សេដ្ឋកិច្ច**

*ចំណុចវិជ្ជមាន*

- ចំណូលកើនឡើង
- ទាក់ទាញអ្នកវិនិយោគទុន
- បង្កើតការងារដល់ប្រជាជនក្នុង និងក្រៅតំបន់
- ការហូរចូលនូវរូបិយវត្ថុបរទេស

*ចំណុចអវិជ្ជមាន*

- ការកើនឡើងនៃការចំណាយក្នុងសេវាកម្មសង្គម និងហេដ្ឋារចនាសម្ព័ន្ធ
- ការកើនឡើងនៃតម្លៃ
- យើងអាចបាត់បង់រូបិយប័ណ្ណបរទេសមួយចំនួន ដែលបាននាំចូល

- **សង្គមវប្បធម៌**

*ចំណុចវិជ្ជមាន*

- សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ប្រជាជននៅក្នុងតំបន់
- សង្គមមានភាពស៊ីវីល័យ
- ផ្លាស់ប្តូរវប្បធម៌គ្នា
- ជំរុញឲ្យមានសន្តិភាព

*ចំណុចអវិជ្ជមាន*

- ការផ្លាស់ប្តូរនៅក្នុងរចនាបទជីវិតក្នុងតំបន់ និងវប្បធម៌ប្រពៃណី
- មានការកកស្ទះចរាចរណ៍ សំឡេងរំខាន និងការចម្លងរោគ

- ការកើនឡើងនូវអសុវត្ថិភាពក្នុងសង្គម

**បរិស្ថាន**

*ចំណុចវិជ្ជមាន*

- ការយល់ដឹងពីបរិស្ថានក៏កាន់តែច្រើន
- មានការថែរក្សាបរិស្ថាន
- ជំរុញអោយមាន

*ចំណុចអវិជ្ជមាន*

- សម្ពាធទៅលើប្រព័ន្ធអេកូឡូស៊ី និងទេសភាព
- កង្វះនៃធនធានថាមពល និងធនធានដទៃទៀត
- ការកើនឡើងនៅកាកសំណល់

✸ យោងតាមអត្ថបទ **A Sustainable Development for Rural Area of Korea** របស់ **STELA ZOTO** និង **ELENA QIRICI** បាននិយាយពីផលប៉ះពាល់ទៅលើវិស័យសេដ្ឋកិច្ចដូចខាងក្រោម៖

- ផលប៉ះពាល់ដោយផ្ទាល់ គឺសំដៅទៅលើសកម្មភាពសេដ្ឋកិច្ច ដែលបានបង្កើតឡើងនៅក្នុងវិស័យឧស្សាហកម្មដែលបានផ្តល់ឲ្យក្រុមហ៊ុនផលិតទំនិញ និងសេវាកម្ម ដោយបានប្រើកសិករនៅក្នុងអាជីវកម្មកសិទេសចរណ៍របស់ពួកគេ (ឧទាហរណ៍ អ្នករចនាម៉ូដផ្ទាំងសិលាពោតមួយ) និងពង្រីកអាជីវកម្មរបស់ខ្លួនខណៈដែលវិស័យឧស្សាហកម្មកសិទេសចរណ៍មានការកើនឡើង និងមានកំណើនពាណិជ្ជកម្ម។

- ផលប៉ះពាល់ដោយប្រយោល ស្រដៀងគ្នានេះដែរប្រាក់ឈ្នួលដែលទទួលបាន និងពន្ធដែលបង់ដោយកសិករ គឺមានផលប៉ះពាល់ទៅដល់វិស័យផ្សេងៗទៀតនៃសេដ្ឋកិច្ច តាមរយៈការបង្កើនការចំណាយរបស់គ្រួសារលើអាហារ ភោជនីយដ្ឋាន អចលនទ្រព្យ ថែទាំវេជ្ជសាស្ត្រ ឧបករណ៍បច្ចេកទេស ទំនិញ ជាមួយនឹងសេវាកម្មផ្សេងៗទៀត។ ការរីករាលដាលនៅក្នុងវិស័យសេដ្ឋកិច្ចទាំងមូល ខណៈការចំណាយរបស់អតិថិជនបានជំរុញដល់ប្រាក់ចំណូលដែលទាក់ទងនឹងកសិទេសចរណ៍ បណ្តាលឲ្យអាជីវកម្ម ផ្សេងទៀត ពង្រីកការលក់របស់ខ្លួន បង្កើនការទិញ និងជួលកម្មករបន្ថែមទៀត។

## ករណីយសិក្សាក្នុងប្រទេសថៃ

វិស័យទេសចរណ៍ គឺជាឧស្សាហកម្មធំសារៈសំខាន់នៃការដែលអាចបង្កើតប្រាក់ចំណូលសម្រាប់ប្រទេសថៃ។ កំណើននៃឧស្សាហកម្មទេសចរណ៍នេះ បានបន្ថែមផលប្រយោជន៍ដល់ប្រជា

ជន ក្នុងស្រុកប៉ុណ្ណោះទេថែមទាំងបង្កើតការងារនិងអាជីពនៅក្នុងវិស័យជាច្រើនដែលបង្កឱ្យមានការចែកចាយប្រាក់ចំណូលតាមរូបភាពផ្សេងៗគ្នាជាច្រើនដល់ប្រជាជនមូលដ្ឋាន។ វិស័យទេសចរណ៍ត្រូវបានគេផ្សព្វផ្សាយនៅក្នុងសេដ្ឋកិច្ចជាអាទិភាពនៃការអភិវឌ្ឍជាតិ។ ដូច្នេះអ្នកអាចនិយាយបានថា វិស័យទេសចរណ៍ជាឧស្សាហកម្មធំមួយដែលចូលរួមចំណែក និងជាគន្លឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចមួយរបស់ប្រទេសថៃ។

ក្រៅពីឆ្នេរសមុទ្រ និងប្រាសាទដ៏ស្រស់ស្អាតរបស់ប្រទេសថៃមានទិដ្ឋភាពជាច្រើននៃវប្បធម៌ថៃដែលមានតម្លៃក្នុងការស្វែងរកហើយមួយក្នុងចំណោមចំណុចទាំងនេះ ប្រភេទទេសចរណ៍ដែលកំពុងរីកលូតលាស់យ៉ាងឆាប់រហ័សគឺ ទេសចរណ៍បែបកសិកម្មដ៏សម្បូរបែបរបស់ប្រទេសថៃ។ ប្រទេសថៃគឺជាប្រទេសមួយដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញខាងស្រូវ សូត្រ និងផលិតផលអាហារនៅទូទាំងពិភពលោក។ មានការទទួលស្គាល់ ការចាប់អារម្មណ៍ កើនឡើងក្រសួងទេសចរណ៍ និងថៃកីឡាបានរួមជាមួយក្រសួងកសិកម្មនិងសហករណ៍ បង្កើតទេសចរណ៍ប្រភេទថ្មី គឺ: កសិទេសចរណ៍។ អាជ្ញាធរទេសចរណ៍ថៃ (TAT - The Tourism Authority of Thailand) ឆ្លើយតបនិងការផ្តួចផ្តើមគំនិត របស់រាជរដ្ឋាភិបាលថៃដើម្បីបង្កើនចំណូលរបស់សហគមន៍មូលដ្ឋានតាមរយៈការជំរុញវិស័យទេសចរណ៍កសិទេសចរណ៍ ដែលផ្តល់ឱកាសឱ្យភ្ញៀវទេសចររីករាយជាមួយសកម្មភាពបរិស្ថាន និងរបៀបរស់នៅតាមជនបទ ក៏ដូចជាការទស្សនាការផលិត សិប្បកម្មក្នុងស្រុក។ គំនិតផ្តួចផ្តើមនេះក៏ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងរបស់ TAT ក្នុងការលើកកម្ពស់និងអភិវឌ្ឍន៍ទេសចរណ៍សហគមន៍ដែលមានមូលដ្ឋាននៅតាមគោលដៅក្នុងស្រុកនៅទូទាំងប្រទេស។

ទីក្រុង Khlong Mahasawat គឺជាគោលដៅកសិទេសចរណ៍មួយក្នុងចំណោមទិសដៅកសិ-ទេសចរណ៍ចំនួន៤ ដែលបានបើកដំណើរការកាលពីខែសីហាឆ្នាំមុន ក្រោមគំរោងផែនការទេសចរណ៍បីដំណាក់កាលសម្រាប់ឆ្នាំ ២០១៥-២០១៧ ដោយក្រសួងទេសចរណ៍ កីឡានិងក្រសួងកសិកម្មនិងសហករណ៍ របស់ប្រទេសថៃ។ គម្រោងនេះអាជ្ញាធរទេសចរណ៍ថៃផ្តោតលើ តំបន់កសិ-ទេសចរណ៍ដែលបានកំណត់គោលដៅសក្តានុពលទាំង ១២ កន្លែងដែលមានភាពប្លែកភ្នែកនិងភាពត្រៀមខ្លួនដើម្បីស្វាគមន៍ភ្ញៀវទេសចរក៏ដូចជា ដើម្បីដឹកនាំភ្ញៀវទេសចរពីគោលដៅសំខាន់ៗ។ តំបន់ទេសចរណ៍ចំនួនបីផ្សេងទៀតគឺ Pak Phanang នៅ Nakhon Si Thammarat, Ban Khok Muang នៅ Buri Ram និង Khao Kho នៅ Phetchabun ។

សម្រាប់ភ្ញៀវទេសចរទៅកាន់ទីក្រុងបាងកក TAT បានផ្តល់អនុសាសន៍តំបន់ទេសចរណ៍តាមសហគមន៍នៅតាមបណ្តោយមហាវិថី Mahasawat ដែលគេស្គាល់ថាជា "Khlong Mahasawat"

នៅខេត្តខេត្តណាខនបាធំ ចម្ងាយប្រហែល ៣០ គីឡូម៉ែត្រ ភាគខាងលិចនៃរដ្ឋធានីរបស់ថៃ កន្លែងដែលនៅជិតបំផុតគឺទីក្រុងបាងកកគឺជាតំបន់តាមបណ្តោយ Khlong Mahasawat ដែលជាប្រឡាយដ៏ល្បីល្បាញមួយនៅខេត្តណាខនបាធំ ។ ប្រឡាយនេះគឺជាផ្នែកមួយក្នុងចំណោមផ្លូវជាច្រើនដែលឆ្លងកាត់ខេត្តនេះហើយត្រូវបានជីកតាំងពី ១៥៦ ឆ្នាំមុនមកម្ល៉េះ ដើម្បីភ្ជាប់ទីក្រុង Khlong ទីក្រុងបាងកកជាមួយទន្លេណាខនឆៃស៊ី។ ការសាងសង់ពីឆ្នាំ ១៨៦០-១៨៦២ ដោយស្តេចរាមាទី៤ ហើយនៅពេលដែលផ្លូវទឹកបានបើកវាបានធ្វើឱ្យដីស្រែមានជីជាតិល្អ ហើយបំរើឲ្យដីកសិកម្មជិត ២0,000 រ៉ៃ (៣២គីឡូម៉ែត្រក្រឡា) អាចដំណើរការកសិកម្មបានយ៉ាងល្អ។

អ្នកទស្សនានៅតំបន់នេះនឹងអាចទៅទស្សនាចម្ការ វាលស្រែ និងទស្សនាកសិដ្ឋានអ័រគីដេក្នុងស្រុកដើម្បីទទួលបាន ការយល់ដឹងច្បាស់អំពីជីវិតរបស់កសិករថៃ។ នេះជាឱកាសថ្មីដ៏ល្អមួយដើម្បីរៀនសូត្រអំពីវប្បធម៌ជនបទរបស់ប្រទេសថៃ ការស្នាក់នៅ homestay របស់ប្រជាជនក្នុងស្រុកនិងគាំទ្រដល់សហគមន៍ជនបទទាំងនេះស្វែងរកប្រាក់ចំណូល ដែលនឹងជួយធានាដល់ការរស់នៅរបស់ពួកគេ។ តំបន់នៅជុំវិញ Khlong Mahasawat ត្រូវបានកំណត់សម្រាប់វិស័យទេសចរណ៍កសិកម្មមានភាពល្បីល្បាញទៅលើកសិ ទេសចរណ៍ ដូចជា ចំការផ្លែឈើ ស្រែចម្ការដំណាំអ័រគីដេ និងស្រះឈូក។ អ្នកទេសចរអាចធ្វើដំណើរដោយទូកវែង ៦ កៅអីពី Wat Suwannaram ទៅមើលកសិដ្ឋានស្រះឈូក និងជិះទូកតូចចូលទៅមើលគេប្រមូលផ្កា។ ពួកគេអាចជិះត្រាក់ទ័រនៅជុំវិញតំបន់ចំការមុនពេលសាកល្បងផ្លែឈើក្នុងតំបន់និងជួបកសិករម្ចាស់ចំការ។មជ្ឈមណ្ឌលសិក្សាសំរាប់សហគមន៍នៅ Ban Saladin បានអនុញ្ញាតឱ្យភ្ញៀវទេសចរមើលពីរបៀបធ្វើម្ហូបអ្នកភូមិក្នុងស្រុក ដូចជា នំអង្ករសំរូបដែលមានសាច់ជ្រូកផ្អែមនិងពងទា។ កន្លែងមួយទៀត សំរាប់ដំណើរកំសាន្តនៅតាមទូកគឺជាកសិដ្ឋានអ័រគីដេ ដែលជាកន្លែងដែលមានផ្កាចម្រុះពណ៌ហើយត្រូវបានដាំដុះយ៉ាងល្អសម្រាប់នាំចេញ។ នេះគឺសមស្របរបស់ TAT ទៅនឹងគោលដៅទេសចរណ៍សហគមន៍ដែលមានមូលដ្ឋាន ក្នុងការជួយពង្រីកការចំណាយរបស់ភ្ញៀវទេសចរ និងបង្កើនចំនូលទៅដល់ប្រជាជនក្នុងស្រុក។

លោក Yuthasak Supasorn អាជ្ញាធរទេសចរណ៍ថៃ មានប្រសាសន៍ថា "នេះជាមធ្យោបាយដ៏អស្ចារ្យមួយសម្រាប់ភ្ញៀវទេសចរ ដែលអាចឃើញនិងស្គាល់ពីវិធីសាមញ្ញមួយនៃជីវិតជនបទរបស់ប្រជាជនកសិករថៃ ដែលទីតាំងមានចម្ងាយជិត ១ ម៉ោងពីទីក្រុងបាងកក។ សហគមន៍កសិករដូចជានៅតាមបណ្តោយមហាវិថី Khlong Mahasawat គឺជាឆ្អឹងខ្នងនៃការផ្គត់ផ្គង់មួយដែលជួយបង្កើនផលិតផលមួយចំនួនដែលចាត់ទុកជារបស់សំខាន់និងមានតំលៃក្នុងប្រទេសថៃ ដូចជាផ្កាអគ្គីដេ ផ្កាឈូករត្ន័អង្ករ និងផ្លែឈើជាដើម។ តាមរយៈការមកទស្សនាកន្លែងទាំងនេះភ្ញៀវទេសចរនឹង

ទទួលបានការយល់ដឹងពីវប្បធម៌ថៃនិងឱកាសដើម្បីទទួលបានផលិតផលដ៏អស្ចារ្យ ខណៈដែលកសិករនិងទទួលបានប្រាក់ចំណូលបន្ថែម "។

គម្រោងកសិទេសចរណ៍នេះ កំណត់យកទេសចរណ៍ទាំង ក្នុងស្រុកនិងអន្តរជាតិក្នុងការទាក់ទាញភ្ញៀវទេសចរ ឲ្យយល់ដឹងពីវិធីជីវិតកសិកររស់នៅតាមជនបទ គុណភាពទេសចរណ៍ និង ជួយការពារបរិស្ថាន ថែរក្សាសហគមន៍ប្រពៃណី ព្រមទាំងការបង្កើនកំរិតជីវភាពប្រជាជន។

**ករណីសិក្សាភូមិទំពាំងបាយជូរក្នុងខេត្តសិនជៃង ទីក្រុងធូលូវាន ប្រទេសចិន**

ភូមិទំពាំងបាយជូ មានទីតាំងស្ថិតនៅចម្ងាយ ១១ គីឡូម៉ែត្រភាគឦសាននៃទីក្រុងធូលូវាន។ ស្ថិតនៅក្រោមជ្រលងភ្នំភ្លើង ដែលមានចំនួនប្រជាជន ៨៩៧២ នាក់។ ទន្លេពូអ៊ីកធូហ្គឺក ជាប្រភពទឹកដែលកើតចេញពីការរលាយពីភ្នំទឹកកក ដែលធ្វើឲ្យផ្លែទំពាំងបាយជូរទទួលបានផលល្អជាងគេ ទើបធ្វើឲ្យទីនោះក្លាយជាគោលដៅទេសចរណ៍មួយដ៏ល្បី។ ក្នុងខែឧសភា ឆ្នាំ២០០៧ រដ្ឋបាលទេសចរណ៍ជាតិបានអនុម័តជាផ្លូវការ ដោយដាក់តំបន់នោះជាតំបន់ទេសចរណ៍កម្រិត A ផ្តោតលើទេសភាព។ ចំការទំពាំងបាយជូរ (Grape Valley) នេះដែរ ចាប់បើកទទួលភ្ញៀវពីម៉ោង ១០ព្រឹករហូតដល់៦:៣០ល្ងាច ចំពោះតំលៃសំបុត្រក្នុងភ្ញៀវម្នាក់ ៧៥ យ័ន (១២.៥ ដុល្លារ) ជាមួយការភ្លក់ទំពាំងបាយជូរដោយសេរី ការដើរមើលទេសភាព និង ការមើលរបាំរបស់ជនជាតិជាដើម។

ទីក្រុងធូលូវាន ជាទីក្រុងដែលមានអាកាសធាតុក្តៅខ្លាំង ក្នុងអំឡុងពេលខែសីហា សីតុណ្ហភាពនៅតំបន់ប្រហែល ៩២ អង្សាសេឡើងទៅ ចំណែកដីនៅតំបន់ភ្នំភ្លើងចាប់ពី ៨០ ដល់ ៩០ អង្សាសេ។ តែចំពោះជ្រលងទំពាំងបាយជូរ ដោយសារមានប្រភពទឹកត្រជាក់ រួមទាំងព្រៃក្រាស់ព័ទ្ធជុំវិញធ្វើឲ្យទំពាំងបាយជូរទទួលបានផលល្អជាប្រចាំ ក្លាយជាជ្រលងសួនដ៏សែនមនោរម្យ និងជាគោលដៅទេសចរណ៍មួយដែលមនុស្សគ្រប់គ្នាប្រាថ្នា។

តំបន់ទីមួយ មជ្ឈមណ្ឌលជ្រលងភ្នំទំពាំងបាយជូ មានការទទួលស្វាគមន៍ទាំងភ្ញៀវជាតិ និងអន្តរជាតិ ទស្សនាតំបន់ភ្នំក្បែរទឹកមានសភាពស្ងប់ស្ងាត់ ទេសភាពធម្មជាតិព័ទ្ធជុំវិញ ចំការទំពាំងបាយជូរ។ ភ្ញៀវទេសចរ អាចអង្គុយក្រោមដើមទំពាំងបាយជូររីករាយជាមួយទិដ្ឋភាពធម្មជាតិ ព្រមទាំងភ្លក់រសជាតិទំពាំងបាយជូរបានដោយសេរី។ នៅលើផ្លូវចូលចំការទំពាំងបាយជូរ មានតួអក្សរបីពណ៌ក្រហមឆ្លាក់ដោយសិលាចារិក នៅក្នុងនោះក៏មានជាភោជនីយដ្ឋានលក់អាហារជាលក្ខណៈជនជាតិភាគតិច សិប្បកម្មកាបូប ព្រមទាំងការ ជិះទូកលេងកម្សាន្ត។

**តំបន់ទីពីរ** ភូមិទំពាំងបាយជូរ នៅទីនោះជារមណីយដ្ឋានលក្ខណៈទំនើប ទាំងសេវាកម្មស្នាក់នៅ និងអាហារ។ សម្រាប់ភោជនីយដ្ឋានអាចផ្ទុកមនុស្សបាន ១២០នាក់ ព្រមទាំងមានបន្ទប់

ខាវ៉ាអូខេ អាងហែលទឹកជាដើម។ **តំបន់ទីបី** កន្លែងតាំងពិព័រណ៍ផ្លែទំពាំងបាយជូរ **តំបន់ទីបួន** សារមន្ទីរប្រពៃណីជនជាតិភាគតិច **តំបន់ទីប្រាំ** តំបន់ភូមិអ្នកស្រុកជនជាតិ។

**ការផ្តល់អនុសាសន៍**

ជារៀងរាល់ខែសីហា ជាខែប្រមូលផលទំពាំងបាយជូរ គេមានការប្រារព្ធឡើងនូវមហោស្រពទំពាំងបាយជូរ ដោយពេលនោះមានការភ្លក់រសជាតិស្រាទំពាំងបាយជូរ ការសម្តែងរបាំប្រជាប្រិយ រាំបទចម្រៀងខ្នាតធំ ការបង្ហាញក្បាច់រាំ និងសកម្មភាពប្លែកៗផ្សេងទៀតដែលត្រូវបានប្រមូលផ្តុំដើម្បីសំដែងឡើង ឲ្យទេសចរបានទស្សនាកំសាន្តនូវប្រពៃណីផ្សេងៗ របស់ទីក្រុងទំពាំងបាយជូរបុរាណមួយនេះ។ ម្យ៉ាងនូវតំបន់កសិកម្មផ្លែឈើមួយនេះ មិនត្រឹមតែមានភាពល្បីល្បាញខាងផ្នែកទំពាំងបាយជូរតែម្យ៉ាងនោះទេ ប៉ុន្តែផ្លែត្រសក់ស្រូវ និង ឪឡឹក ក៏ជាផ្លែឈើដ៏មានអំណោយផលផងដែរ។

**ផលប្រយោជន៍**

**១.ជួយពង្រីកវិសាលភាពអាជីវកម្មរបង្កើនតម្លៃបន្ថែមនៃផលិតផលកសិកម្ម**

កសិទេសចរណ៍ធម្មជាតិ ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងវិស័យកសិកម្ម និងឧស្សាហកម្មទេសចរណ៍ និងផលិតកម្ម វាគឺជាចំណុចកំណើនសេដ្ឋកិច្ចថ្មីនៃវិស័យឧស្សាហកម្មទេសចរណ៍មួយនេះ។ ដោយការអភិវឌ្ឍវិស័យទេសចរណ៍នៃធនធានកសិកម្មផ្តល់ជូនទេសចរនូវរសជាតិដំណាំហូបផ្លែ ការទិញផ្ទាល់ ការធ្វើលំហាត់ប្រាណ ការកំសាន្តរមណីយដ្ឋានធម្មជាតិនាពេលវិស្សមកាល និងសេវាកម្មផ្សេងទៀត។

**២. ចំណូលដល់ប្រជាជនក្នុងតំបន់**

ចំពោះប្រជាជនក្នុងតំបន់រមណីយដ្ឋានទំពាំងបាយជូរភាគឦសាននៃទីក្រុងធូលូវាន ពួកគាត់អាចរកបានចំណូលបានបន្ថែមពីការលក់សំបុត្រចូលទស្សនា ការលក់ផលិតផលដំណាំផ្ទាល់ដល់ភ្ញៀវទេសចរ និងការលក់ផលិតផលសិប្បកម្ម ការស្នាក់នៅ និង សេវាកម្មម្ហូបអាហារ។ ដោយអាចកាត់បន្ថយហានីយភ័យពីការកង្វះទីផ្សារលក់ផលិតផល ក៏ដូចជាការចំណាកស្រុកដើម្បីស្វែងរកការងារជាដើម។

**យុទ្ធសាស្ត្រគោលការណ៍អភិវឌ្ឍន៍តំបន់កសិទេសចរណ៍**

- កំណត់យុទ្ធសាស្ត្រដោយកតំបន់ដែលត្រូវអភិវឌ្ឍន៍ជាគោលដៅទេសចរណ៍ច្បាស់លាស់
- បង្កើតឲ្យមានជារមណីយដ្ឋានច្រើនប្រភេទ និងបែងចែកប្រភេទនីមួយៗឲ្យបានត្រឹមត្រូវ
- រៀបចំឲ្យមានជាសហគមន៍ទេសចរណ៍ទៅតាមតំបន់
- រៀបចំជាប្រពន្ធ័គ្រប់គ្រង ចៀសវាងមានជម្លោះផ្សេងៗ

- ការច្នៃប្រឌិតថ្មី អនុវត្តតាមចំណង់ចំណូលចិត្តនិងតម្រូវការរបស់ភ្ញៀវទេសចរ
- រៀបចំសេវាកម្មស្នាក់នៅ និង សេវាកម្មម្ហូបអាហារ
- រៀបចំនូវហេដ្ឋារចនាសម្ព័ន្ធ និង បច្ចេកទេសនៃការដាំដុះផ្សេងៗ។

# ជំពូកទី ២
# ស្ថានភាពទូទៅនៃតំបន់
# កោះឧកញ៉ាតី

# ជំពូកទី២

# ស្ថានភាពទូទៅនៃតំបន់ទេសចរណ៍កោះឧកញ៉ាតី

ជំពូកនេះ គឺសំដៅទៅលើស្ថានភាពទូទៅនៃតំបន់កោះឧកញ៉ាតី។ អ្វីដែលនឹងត្រូវបង្ហាញក្នុងជំពូកនេះ គឺយើងបានធ្វើការចែកជា៣ សំខាន់ៗដូចជា **ផ្នែកទី១** និយាយអំពីស្ថានភាពទូទៅនៃខេត្តកណ្តាល **ផ្នែកទី២** និយាយអំពីលក្ខណទូទៅនៃតំបន់កោះឧកញ៉ាតី ដូចជាទីតាំងភូមិសាស្ត្រ លក្ខណៈអាកាសធាតុ ស្ថានភាពប្រជាជន ស្ថានភាពប្រជាជនក្នុងតំបន់ សន្តិសុខ និងសុវត្ថិភាពក្នុងតំបន់ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងសក្តានុពលទេសចរណ៍នៃតំបន់កោះឧកញ៉ាតី **ផ្នែកទី៣** និយាយអំពីសារៈប្រយោជន៍ដែលទទួលបានពីការអភិវឌ្ឍក្នុងតំបន់ឲ្យក្លាយជាតំបន់កសិទេសចរណ៍។ យើងនឹងបង្ហាញចំណុចខាងលើនេះ តាមដំណាក់កាលយ៉ាងលម្អិតដូចខាងក្រោម៖

## ២.១ លក្ខណៈទូទៅនៃតំបន់កោះឧកញ៉ាតី

### ២.១.១ ទីតាំងភូមិសាស្ត្រ

កោះឧកញ៉ាតី គឺជាស្រុកមួយស្ថិតនៅខេត្តកណ្តាល មានផ្ទៃដីសរុប ៣១២ហិចតា ដែលបែងចែកជា ៥ ភូមិរួមមាន៖ ភូមិកោះតូច ភូមិក្បាលកោះ ភូមិកណ្តាលកោះ ភូមិចុងកោះ និងភូមិខ្ពប។ តំបន់កោះឧញ៉ាតី ជាកោះមួយហ៊ុំពទ្ធ័ទៅដោយផ្ទៃទឹក ដែលមានភាពងាយស្រួលក្នុងការរស់នៅព្រមទាំង មានសក្តានុពលដាំដុះដំណាំកសិកម្មផ្សេងៗ។

ប្រសិនបើយើងធ្វើដំណើរចេញពីរាជធានីភ្នំពេញឆ្ពោះទៅកាន់កោះឧកញ៉ាតី ត្រូវឆ្លងតាមបណ្តោយផ្លូវជាតិលេខ៦ ចម្ងាយប្រហែលជា ៥ ទៅ៧ គីឡូម៉ែត្រ ក្រឡេកមើលនៅខាងស្តាំដៃ យើងនឹងឃើញមានខ្លោងទ្វារវិហារលោកតាចិន "**ហុក តិច**" រួចធ្វើដំណើរចូលតាមច្រកទ្វារនោះ រួចបត់ឆ្វេង យើងនឹងឃើញមានកំពង់ចម្លងមួយ "**កំពង់ចម្លង ព្រែកលាប-កោះដាច់-កោះឧញ៉ាតី**" នៅខាងស្តាំដៃជួរមាត់ទន្លេ បន្ទាប់មកយើងត្រូវធ្វើការឆ្លងកំពង់ចម្លងទៅត្រើយម្ខាង ដោយចំណាយក្នុងមនុស្សម្នាក់ ៥០០រៀល ម៉ូតូ១គ្រឿង ៥០០រៀល រថយន្តធនមធ្យម១គ្រឿង ១ម៉ឺនរៀល និងរថយន្តធនតូច ១គ្រឿង ៦ពាន់រៀល។ (ដូចដែលបានបង្ហាញក្នុងរូបទី១)

ពេលដល់ត្រើយម្ខាង យើងនឹងឃើញមានផ្លូវបេតុងបំបែកជាពីរ ដែលមានស្លាកសញ្ញាប្រាប់ពីផ្លូវមួយទៅកោះដាច់ និងផ្លូវមួយទៀតទៅកោះឧកញ៉ាតី បន្ទាប់ពីឆ្លងពីស្ពានដែក ប្រវែង១៨០ម៉ែត្រ នោះលោកអ្នកចូលទៅដល់ទឹកដីកោះឧកញ៉ាតី។ហើយ យើងត្រូវបន្តដំណើរប្រមាណ៥ ទៅ១០ម៉ែត្រ រួចនៅខាងឆ្វេងដៃយើងនឹងឃើញមានស្លាកសញ្ញាប្រាប់ផ្លូវទៅចំការស្នេហ៍ និងផែនទីភូមិឃុំទាំងមូលក្នុងកោះឧកញ៉ាតីជាក់ជាពុំខាន។ បើសិនជាយើងធ្វើដំណើរពីស្ពានដែក ទៅត្រង់ដល់ផ្លូវ

ទល់រួចបត់ឆ្វេង រួចទៅត្រង់បន្តិចនៅខាងឆ្វេងដៃយើងនឹងឃើញ សាលាឃុំកោះឧកញ៉ាតី ដែលនៅជាប់នោះមានផ្សារធំជាងគេនៅក្នុងតំបន់នោះ ដែលហួសពីទីនោះបន្តិច នៅតាមបណ្តោយផ្លូវដែលអមទៅដោយដើមត្នោតសងខាង នៅខាងស្តាំដៃមានមណ្ឌលសុខភាព និងខាងឆ្វេងដៃមានសាលារៀនអនុវិទ្យាល័យកោះឧកញ៉ាតី។

### ២.១.២ លក្ខណៈអាកាសធាតុ

តំបន់កោះឧកញ៉ាតីមានលក្ខណៈត្រជាក់ល្មម និងមិនក្តៅពេក ដោយសារតែតំបន់នេះហ៊ុំព័ទ្ធដោយទឹកទន្លេ និងមានដើមឈើច្រើន វាបង្ករឲ្យមានលក្ខណៈអំណោយផល ក្នុងការរស់នៅ ការដាំបន្លែ ផ្លែឈើរបស់ប្រជាពលរដ្ឋក្នុងតំបន់ ព្រមទាំងមានលក្ខណៈងាយស្រួលដល់ទេសចរដែលចូលចិត្តជិះកង់លំហែស្រូបយកខ្យល់អាកាសបរិសុទ្ធ ចូលចិត្តភាពស្ងប់ស្ងាត់តាមរបៀបកសិកម្ម និងតាមភាពរស់នៅរបស់ប្រជាជនក្នុងតំបន់ ។

### ២.១.៣ ស្ថានភាពប្រជាជនក្នុងតំបន់

នៅក្នុងតំបន់កោះឧកញ៉ាតីមានភូមិចំនួន ៥ភូមិ ដែលមានប្រជាជនសរុប ៦,៦១៣នាក់ (ប្រជាពលរដ្ឋចាប់ពី១៨ឆ្នាំឡើងទៅ) ៦០% នៃប្រជាជនក្នុងតំបន់ប្រកបរបរកសិកម្ម ហើយបន្ទាប់ពីទំនេរពីការងារនេះ ពួកគេបានប្រកបរបរបន្ទាប់បន្សំដូចជា ធ្វើសិប្បកម្មត្បាញ(១០%) កម្មករ(២៥%)នៅភ្នំពេញ អាជីវករ(០៣%) និងមន្ត្រីរាជការ(០២%) ។ បរិបទរស់នៅរបស់ប្រជាជននៅទីនោះ មិនមានភាពស្មុគស្មាញច្រើនទេ បុរសៗភាគច្រើនបន្ទាប់ពីធ្វើចំការរួច គាត់ឆ្លៀតពេលជួសជុលកង់ម៉ូតូ និងរបស់របរប្រើប្រាស់ផ្សេងៗនៅតាមផ្ទះ ចំណែកឯស្ត្រីគាត់ប្រកបរបរជាអាជីវករលក់ដូរផ្សេងៗនៅតាមផ្សារពេលព្រឹក ដល់ម៉ោងប្រហែល ១០ ទៅម៉ោង ១១ គាត់ចាប់ផ្តើមរើតវ៉ាន់ ហើយត្រលប់មកលក់របស់របរ បន្លែ និង ចំណីអាហារតិចតួចនៅតាមផ្ទះ។

### ២.១.៤ សន្តិសុខ និងសុវត្ថិភាពក្នុងតំបន់

ដោយសារតំបន់កោះឧញ៉ាតី មិនទាន់ជាមានកន្លែងសំរាប់ភ្ញៀវទេសចរស្នាក់នៅក្នុងពេលយប់ ទើបធ្វើឲ្យការរក្សាសណ្តាប់ធ្នាប់ និង សន្តិសុខ ចំពោះភ្ញៀវទេសចរ ពុំទាន់ចោទជាបញ្ហាចំពោះទេសចរដែលទៅកំសាន្តនៅតំបន់នោះទេ។ បន្ទាប់ពីមានការសិក្សា និងសំភាសន៍ជាមួយស្មៀនភូមិនៅទីនោះផ្ទាល់ ពាក់ពន្ធ័ពីការទទួលបណ្តឹងពីទេសចរចំពោះបញ្ហាផ្សេងៗធ្ងន់ធ្ងរគឺពុំទាន់មាននៅឡើយទេ ដោយសារទេសចរដែលមកកំសាន្តតែងត្រលប់ទៅវិញនៅពេលរសៀល ចំនែកឯសុវត្ថិភាពចំពោះប្រជាជនក្នុងតំបន់ពេលយប់ តាមភូមិនីមួយៗមានការចល័តការយាមដោយប្រជាការពារក្នុងភូមិ ដែលអាចឲ្យយើងដឹងថា សន្តិសុខ សុវត្ថិភាព និង រក្សាសណ្តាប់ធ្នាប់នៅតំបន់នោះមានលក្ខណៈល្អឲ្យគួរកត់សំគាល់។

### ២.១.៥ ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ

#### ក. ផ្លូវធ្វើដំណើរ

ផ្លូវថ្នល់ គឺជាកត្តាមួយដ៏សំខាន់សម្រាប់មនុស្សធ្វើដំណើរទៅកាន់តំបន់ទេសចរណ៍គោលដៅដែលគេចង់ទៅទស្សនាកំសាន្ត ព្រមទាំងការធ្វើដំណើរក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។ បច្ចុប្បន្ននេះ ពាក់ព័ន្ធនឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជាច្រើនក្នុងតំបន់កោះឧកញ៉ាតីមានការស្ថាបនាកសាងឡើងជាផ្លូវប្រភេទបេតុងជាច្រើនខ្សែ ក្នុងគោលបំណងសម្រួលការធ្វើដំណើររបស់ទេសចរ និងប្រជាជនក្នុងតំបន់។ នៅឃុំកោះឧកញ៉ាតីបានអភិវឌ្ឍដោយមានផ្លូវបេតុង និងក្រៅពីនេះ ផ្លូវទាំងអស់ក្នុងភូមិក្រាលដោយគ្រួសក្រហម តាមដងផ្លូវក្នុងភូមិមានដើមឈើតូចធំ អមសងខាងបង្កភាពត្រជាក់ងាយស្រួលក្នុងការធ្វើដំណើរ។

#### ខ. ការផ្គត់ផ្គង់អគ្គិសនី

ប្រជាពលរដ្ឋនៅក្នុងតំបន់កោះឧកញ៉ាតីទាំងមូល បានប្រើប្រាស់អគ្គិសនីរបស់រដ្ឋស្ទើរតែទាំងស្រុង ដែលគិតក្នុង ១ គីឡូវ៉ាត់ម៉ោងតំលៃ ៧០០រៀល ប៉ុន្តែនៅតាមផ្ទះរបស់ប្រជាជនមួយចំនួនក៏មានការប្រើប្រាស់នូវថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ឬថាមពលសូឡាផងដែរ។

#### គ. ការផ្គត់ផ្គង់ទឹកស្អាត

ទឹកស្អាត គឺជាកត្តាយ៉ាងសំខាន់ក្នុងការទ្រទ្រង់ជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងតំបន់ក៏ដូចជាក្នុងការអភិវឌ្ឍវិស័យផ្សេងៗ និងវិស័យទេសចរណ៍ឲ្យមានភាពរីកចម្រើន។ ដោយឡែកដោយតំបន់កោះឧកញ៉ាតីមិនទាន់មានក្រុមហ៊ុនរដ្ឋ ឬឯកជនណាមួយមកតបណ្ដាញទឹកស្អាត និងផ្គត់ផ្គង់ទឹកស្អាតនៅឡើយទេ ដូច្នេះហើយបានជាធ្វើឲ្យប្រជាជននៅក្នុងតំបន់កោះឧកញ៉ាតីមិនទាន់មានប្រព័ន្ធទឹកស្អាតប្រើប្រាស់។ ពាក់ព័ន្ធជាមួយនឹងបញ្ហាទឹកក្នុងការប្រើប្រាស់នេះដែរ ប្រជាពលរដ្ឋនៅទីនោះបានប្រើប្រាស់ទឹកឯកជនដែលគេបូមពីទន្លេក្នុងតំលៃ ២០០០រៀលក្នុងមួយគីប សម្រាប់ទ្រទ្រង់ជីវភាពរស់នៅប្រចាំថ្ងៃ និងសម្រាប់ស្រោចស្រង់ដំណាំផ្សេងៗ ដែលពួកគេបានដាំដុះ។

#### ឃ. ប្រព័ន្ធទូរគមនាគមន៍

ពាក់ព័ន្ធនឹងប្រព័ន្ធទូរស័ព្ទ និងប្រព័ន្ធអ៊ីធើណែតនៅក្នុងតំបន់នេះ មិនមានអ្វីចោទជាបញ្ហានោះទេ ដែលវាធ្វើឲ្យមានលក្ខណៈងាយស្រួលក្នុងការទំនាក់ទំនង ស្វែងរកពត៌មាន ក៏ដូចជាទទួលដឹងលឺអំពីពត៌មានផ្សេងៗ និងការស្រាវជ្រាវក្នុងសង្គម។ នាពេលបច្ចុប្បន្នមាននេះ ក៏មានប្រព័ន្ធទូរទស្សន៍ខ្សែកាប និង ដុំឧបករណ៍TV Box ជាដើម។

**ខ. ធនាគារ និង គ្រឹះស្ថានហិរញ្ញវត្ថុ**

មិនតែប៉ុណ្ណោះ នៅក្នុងឃុំកោះឧកញ៉ាតី ក៏មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុឯកជនមួយកន្លែង (គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាក់ស៊ីម៉ា ភីអិលស៊ី) កន្លែងវេរលុយ និងផ្ញើរប្រាក់មួយចំនួនសម្រាប់ប្រជាពលរដ្ឋរស់នៅទីនោះប្រើប្រាស់សេវាកម្មផងដែរ។

## ២.១.៦ សក្តានុពលទេសចរណ៍ក្នុងតំបន់កោះឧកញ៉ាតី

បន្ទាប់ពីធ្វើដំណើរចេញពីកំពង់ចម្លង រហូតដល់ឆ្លងស្ពានដែកកោះឧកញ៉ាតី-កោះដាច់ បើសិនជាឈប់នៅលើស្ពាននោះ ហើយក្រលែកទៅខាងស្តាំដៃ យើងនឹងឃើញសំណង់អាគារសំខាន់ៗមួយចំនួននៅទីក្រុងភ្នំពេញបានយ៉ាងច្បាស់ ចំណែកឯខាងឆ្វេងដៃមានចំការ នៅតាមបណ្តោយដងទន្លេ ដែលបង្កើននូវទេសភាពដ៏ស្រស់ត្រកាល។ រីឯទេសភាពនៅក្នុងភូមិប្រៀបបីដូចជាទេសភាពនៅតាមតំបន់ជនបទ ដោយសំបូរទៅដោយដើមឈើតូចធំនៅតាមសងខាងផ្លូវ ដែលវាបង្កើតបានទៅជាម្លប់ ជាពិសេសមានចំហាយខ្យល់ត្រជាក់ពីទឹកទន្លេ ជាហេតុធ្វើឲ្យទីនោះមានបរិយាកាសស្រស់ស្រាយល្អ សម្រាប់ការជិះកង់កម្សាន្តលេងតាមភូមិ និងហាត់ប្រាណដើម្បីសុខភាព របស់ប្រជាជនម្ចាស់ស្រុក និងទេសចរពេលព្រឹក និងពេលល្ងាចផងដែរ។ នៅទីនោះមិនត្រឹមតែអំណោយផលនូវខ្យល់អាកាសបរិសុទ្ធនោះទេ ប៉ុន្តែព្រមទាំងមានរមណីយដ្ឋានកែច្នៃចំការស្នេហ៍ និងរមណីយដ្ឋានមួយទៀតដែលកំពុងធ្វើការជួសជុលឡើងវិញឈ្មោះ ម៉ូណៃកោះមេគង្គ។

- **រមណីយដ្ឋានចំការស្នេហ៍**

ស្ថិតក្នុងភូមិកោះតូច ឃុំកោះឧកញ៉ាតី្ត ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដែលកំពុងទទួលការចាប់អារម្មណ៍ពីភ្ញៀវទេសចរជាតិ និងអន្តរជាតិមកកម្សាន្តមិនដាច់។ រមណីយដ្ឋានចំការស្នេហ៍ រង់ចាំបើកទ្វារស្វាគមន៍ភ្ញៀវទេសចរគ្រប់ពេលវេលា ដើម្បីផ្លាស់ប្តូរបរិយាកាស និងរំសាយអារម្មណ៍បន្ទាប់ពីនឿយហត់ ក្រោយបំពេញការងារ។ រមណីយដ្ឋានកំពុងទទួលបានការចាប់អារម្មណ៍ពីភ្ញៀវទេសចរជាតិ និងអន្តរជាតិមកកម្សាន្តមិនដាច់ ។ ឱ្យតែថ្ងៃចុងសប្តាហ៍ ឬថ្ងៃបុណ្យជាតិម្តងៗមានភ្ញៀវទេសចរជាតិនិងអន្តរជាតិ នាំក្រុមគ្រួសារមិត្តភក្តិស្រី-ប្រុស ទៅទស្សនាកម្សាន្តលំហែកាយជាច្រើន ។

ចំការស្នេហ៍ បើកទ្វារទទួលភ្ញៀវជារៀងរាល់ថ្ងៃ ចាប់ពីម៉ោង៧ព្រឹកដល់ម៉ោង៥ល្ងាច ចំពោះភ្ញៀវទេសចរចូលទៅទស្សនាតំបន់រមណីយដ្ឋាន ចំការស្នេហ៍នេះ ត្រូវបង់ថ្លៃចំនួន២ពាន់រៀល ចំពោះភ្ញៀវជាតិ ៤ពាន់រៀល សម្រាប់ភ្ញៀវអន្តរជាតិ ។ ចំពោះចំនួនភ្ញៀវទេសចរជាតិមកកំសាន្តមានប្រហែលពី ២០នាក់ទៅ៥០នាក់ក្នុងមួយថ្ងៃ តែចំពោះភ្ញៀវអន្តរជាតិវិញ ក្នុងមួយថ្ងៃមានជាង១០០នាក់ ។

បើយើងនិយាយពីសក្តានុពល និងភាពទាក់ទាញរបស់រមណីយដ្ឋានចំការស្នេហ៍ ដែលធ្វើទេសចរចង់មកទស្សនាកំសាន្ត ស្វែកយល់ និងស្រាវជ្រាវនោះ គឺ

- ចំការដើមមន
- ការអភិរក្ស និងការចិញ្ចឹមដង្កូវនាងតាមបែបបុរាណ
- ការយកផលិតផលសូត្រពីដង្កូវនាង
- សកម្មភាពស្នាដៃកូនខ្មែរក្នុងការត្បាញជាក្រមា ហូល ផាមួង
- ទេសភាពធម្មជាតិខៀវសង្វាត់ សម្រាប់ភ្ញៀវដែលចង់លំហែលកាយផ្តិតយកទេសភាពធម្មជាតិដែលមានដើមឈើ ធំ តូច និងរុក្ខជាតិផ្សេងយ៉ាងច្រើន ។
- អ្វីដែលពិសេសនៅទីនោះ អ្នកនឹងទទួលបានខ្យល់ត្រជាក់បរិសុទ្ធ ពីជំនោលទន្លេមេគង្គពេញមួយឆ្នាំតែម្តង។
- ផ្ទះបុរាណខ្មែរ បង្ហាញពីវប្បធម៌ ក្នុងការរស់នៅរបស់ជនជាតិខ្មែរ
- ផ្ទះជនជាតិភាគតិច
- ដើមឈើហូបផ្លែ
- កន្លែងចិញ្ចឹមសត្វព្រៃ (ស្វា កាំប្រម៉ា ក្ងោក សំពោច.....)។

**រមណីយដ្ឋានកំពុងកែលំអ**

មានទីតាំងស្ថិតនៅភូមិកោះតូច កាលពីមុនរមណីយដ្ឋាននេះស្ថិតនៅក្រោមការគ្រប់គ្រងដោយក្រុមហ៊ុនចិន របស់លោកឧកញ៉ា ខ្វង ឈីវ ដែលមានឈ្មោះថា **Mekong Island Resort** ភាពទាក់ទាញនៅទីនោះ គឺសួនសត្វ ដែលមានសត្វច្រើនប្រភេទ ប៉ុន្តែដោយមានបញ្ហាហិរញ្ញវត្ថុ ក្រុមហ៊ុននោះក៏បានផ្ទេរសិទ្ធគ្រប់គ្រងទៅឲ្យក្រុមហ៊ុនបារាំង ហើយក៏បានដូរឈ្មោះទៅជា **ម៉ូណៃកោះមេគង្គ** ។ ម៉ូណៃកោះមេគង្គ បង្កើតសេវាកម្សាន្តដូចជា ការសម្តែងសិល្បៈផ្សេងៗលក្ខណៈបែបខ្មែរ សួនសត្វ កន្លែងសម្រាប់អង្គុយលេងនិងបរិភោគអាហារ មានអាហារបម្រើលក្ខណៈប៊ូហ្វេជាដើម ដោយពីមុនប្រព័ន្ធផ្សព្វផ្សាយមិនទាន់មានលក្ខណៈធំទូលាយដូចពេលបច្ចុប្បន្ន បណ្តាលឲ្យទេសចរមិនសូវបានស្គាល់ ជាហេតុធ្វើឲ្យទីនោះមិនសូវមានទេសចរទៅទស្សនាកម្សាន្ត ក៏មានបញ្ហាក្ស័យធន និងបញ្ឈប់អាជីវកម្មចាប់តាំងពីពេលនោះមក។ ជាក់ស្តែងបច្ចុប្បន្ន កន្លែងនោះត្រូវបានម្ចាស់ដីកំពុងតែតុបតែងកែលំអរឲ្យក្លាយជារមណីយដ្ឋានមួយដ៏ទាក់ទាញប្រចាំតំបន់។

### ២.១.៧ លក្ខណៈពិសេសនៃកសិទេសចរណ៍

កសិទេសចរណ៍ ជាទេសចរណ៍មួយបែបដែលបំរើដល់ទេសចរមិនចេះរឹងស្ងួត មិនមានរដូវកាលកំណត់ទៅតាមសកម្មភាពរបស់ទេសចរ និងមានលក្ខណៈស្រដៀងទៅនឹងអេកូទេសចរណ៍ ដោយត្រូវការអភិរក្សជាលក្ខណៈធម្មជាតិ និងធានាថាគ្មានផលប៉ះពាល់ដល់បរិស្ថាន ធម្មជាតិ វប្បធម៌ ព្រមទាំងជួយលើកកម្ពស់កម្រិតជីវភាពប្រជាជនក្នុងសហគមន៍មូលដ្ឋាន ចំណែកឯកសិទេសចរណ៍នៅតំបន់កោះឧកញ៉ាតី អាចនឹងមានសកម្មភាពមួយចំនួនសម្រាប់ឲ្យទេសចរកំសាន្តមានដូចជា៖

- ដើរកំសាន្តលក្ខណសាមញ្ញ : ថ្មើរជើង ម៉ូតូ កង់ រទេះគោ រទេះសេះ រថយន្តសហគមន៍ រឺ រថយន្តទេសចរខ្លួនឯង
- ស្នាក់នៅ រឺ ទទួលអាហារជាមួយប្រជាជនក្នុងតំបន់
- ប្រមូលផល (ប៉ះបន្លែ) ស្ទូចត្រី មកចំអិនជាអាហារ
- ជិះសេះ រឺ មើលការតាំងពិពណ៌ ទិញ ផលិតផលកសិកម្មផ្ទាល់នៅកសិដ្ឋាន
- ចូលរួមលេងកំសាន្តផ្សេងៗជាមួយប្រជាជនក្នុងសហគមន៍
- ចូលរួមដាំដំណាំជាមួយប្រជាជនក្នុងសហគមន៍។ល។

## ២.២ ការវិភាគភាពខ្លាំង ភាពខ្សោយ កាលានុវត្តន៍ភាព និងការគំរាមកំហែង

ការវិភាគពីតំបន់កោះឧកញ៉ាតីក្នុងការជម្រុញឲ្យក្លាយជាតំបន់កសិទេសចរណ៍ គឺយើងខ្ញុំបានវិភាគទៅលើភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមគំហែង គឺជាបច្ចេកទេសមួយដ៏មានសារៈសំខាន់ ក្នុងការវិភាគសក្តានុពល និងរកគន្លឹះល្អៗ ដើម្បីធ្វើការអភិវឌ្ឍតំបន់កសិទេសចរណ៍នៅក្នុងតំបន់កោះឧកញ៉ាតីឲ្យបានជោគជ័យ។ ហើយការវិភាគលើ SWOT នៃតំបន់កោះឧកញ៉ាតីមានដូចខាងក្រោម៖

### ក. ភាពខ្លាំង

ដោយយោងតាមលក្ខណភូមិសាស្ត្រ បរិស្ថាន ធនធានធម្មជាតិ អាកាសធាតុ នៅក្នុងតំបន់កោះឧកញ៉ាតី រួមផ្សំទាំងទេសភាពដ៏ស្រស់ស្អាតដែលហ៊ុំពាត់ទៅដោយទឹកទន្លេ និងដីមានអំណោយផលផ្នែកកសិកម្ម ជាមួយនឹងផលដំណាំជាច្រើនដែលងាយស្រួលដល់ការជំរុញទីនេះឲ្យក្លាយជាតំបន់កសិទេសចរណ៍ ខាងក្រោមនេះជាចំណុចខ្លាំងនៅក្នុងតំបន់កោះឧកញ៉ាតីមាន៖

- ជាតំបន់ដែលមានអំណោយផលខាងកសិកម្ម និងទេសចរណ៍
- មានទេសភាពធម្មជាតិស្រស់ស្អាត ទាក់ទាញ ព្រមជាមួយនឹងបរិយាកាសដ៏ល្អ
- បរិយាកាសក្នុងភូមិមានភាពស្ងប់ស្ងាត់ និងមានលក្ខណៈដូចជានៅតាមជនបទ

- មានអាកាសធាតុយ៉ាងអំណោយផល ខ្យល់អាកាសបរិសុទ្ធ
- ផ្លូវធ្វើដំណើរស្អាត ងាយស្រួលដល់ទេសចរទៅកម្សាន្ត
- មានសន្តិសុខ សុវត្ថិភាពល្អ និងមានផាសុកភាព
- មានទីតាំងល្អ មិនឆ្ងាយពីក្រុង និងអាចមើលឃើញទេសភាពទីក្រុងភ្នំពេញ
- មានចំការដំណាំច្រើនប្រភេទដូចជា បន្លែស្លឹក បន្លែមើម បន្លែផ្លែ និងឈើហូបផ្លែ(ចេក អំពៅ ស្វាយ ខ្នុរ) ដែលដាំដោយប្រជាជននៅទីនោះផ្ទាល់
- ប្រជាជនរួសរាយរាក់ទាក់ ។

**ខ. ភាពខ្សោយ**

- ពុំទាន់មានការផ្សព្វផ្សាយឲ្យបានទូលាយ ទេសចរមិនសូវបានស្គាល់
- ប្រជាពលរដ្ឋមិនទាន់មានការយល់ដឹងពីកសិទេសចរណ៍
- ការធ្វើកសិកម្មនៅតំបន់នោះ នៅមានលក្ខណៈទ្រង់ទ្រាយតូច និងផ្តោតតែទៅលើការដាំជាលក្ខណៈ ដំណាំក្នុងដី
- កង្វះការរៀបចំជាសេវាកម្មស្នាក់នៅ និង សេវាកម្មម្ហូបអាហារ

**គ. កាលានុវត្តន៍ភាព**

- នាពេលអនាគតទីនោះនឹងក្លាយទៅជាតំបន់ទេសចរណ៍បែបកសិទេសចរណ៍ដ៏ទាក់ទាញសម្រាប់ទេសចរជាតិ និងអន្តរជាតិ
- អាចក្លាយជាតំបន់កសិទេសចរណ៍ដំបូងគេ ដែលនៅមិនឆ្ងាយពីទីក្រុងភ្នំពេញ
- ប្រជាជនមូលដ្ឋានអាចមានឱកាស និងចាប់យកការងារពីវិស័យទេសចរណ៍
- អាចផ្តល់ឱកាសឲ្យនិស្សិត និងប្រជាជនដែលមានចំណាប់អារម្មណ៍ខាងកសិកម្មមកសិក្សាស្វែងយល់
- អាចនឹងមានការកើនឡើងទេសចរបែបកសិទេសចរណ៍នៅលើពិភពលោកកាន់តែច្រើន ជាពិសេសប្រទេសកម្ពុជា
- បង្កើនឲ្យមានការយកចិត្តទុកដាក់លើវិស័យកសិកម្ម និងទេសចរណ៍ ទាំងទេសចរ និងប្រជាពលរដ្ឋមូលដ្ឋាន។

**ឃ. ការគំរាមគំហែង**

- មនុស្សមិនមានការយល់ដឹងពីកសិទេសចរណ៍ ធ្វើឲ្យពុំមានគំនិតក្នុងការចូលរួមការអភិរក្សធនធានទាំងឡាយ

- មានការនាំចូលផលិតក្រៅស្រុកមកប្រើប្រាស់ ជាងផលិតផលក្នុងស្រុក
- ផលប្រយោជន៍ធ្លាក់ទៅលើអ្នកបោះវិនិយោគទុនធំៗ ដូចជារីស៊ត និងសណ្ឋាគារ
- ប្រទេសជិតខាងមានរមណីយដ្ឋានបែបកសិទេសចរណ៍ដែលជឿនលឿន និងមានការរីកចម្រើនជាងប្រទេសយើង
- អាចត្រូវបានគេមើលរំលង បើទោះបីជាតំបន់មួយដែលសំបូរទៅដោយប្រភពធនធានធម្មជាតិ និងកសិកម្មក៏ដោយ។

## ២.៣ បញ្ហាប្រឈមនៅតំបន់កោះឧកញ៉ាតី

តាមការសង្កេត និង ចុះស្រាវជ្រាវ ការអភិវឌ្ឍទេសចរណ៍ តំបន់កោះឧកញ៉ាតីមានការរីកចំរើនគួរឲ្យកត់សំគាល់ ប៉ុន្តែនៅមានចំនុចសំខាន់ៗ ផ្សេងៗទៀតដែលអាជ្ញាធរនិងស្ថាប័នពាក់ពន្ធ័គួរកត់សំគាល់ ព្រមទាំងពិចារណាក្នុងការកែលម្អតំបន់មួយនេះឲ្យរឹតតែប្រសើរឡើង ដើម្បីពន្យាពេលក្នុងការស្នាក់នៅរបស់ភ្ញៀវរឹតតែយូរ អាជ្ញាធរ និង ស្ថាប័នពាក់ពន្ធ័ គួរពិចារណាលើបញ្ហាមួយចំនួន ដូចជា បង្គន់អនាម័យ បរិស្ថាន សេវាកម្មអាហារ និង ស្នាក់នៅ។

### ២.៣.១ បង្គន់អនាម័យ

ជាការពិតការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈចាំបាច់បំផុតគឺបង្គន់អនាម័យ ។ គេមិនអាចនិយាយថា ប្រទេសមួយមានការអភិវឌ្ឍ និង ទីក្រុងមួយប្រកបដោយសោភ័ណ្ឌភាព រមណីយដ្ឋានមួយដ៏ស្រស់ត្រកាលបានទេ ដរាបណាបញ្ហាបង្គន់អនាម័យមិនត្រូវបានគិតគូរជាបឋមនោះ។ ជាទូទៅ តែងមានការលើកជាសំណួររិះគន់លើបញ្ហាបន្ទប់ទឹក ឬបង្គន់អនាម័យសាធារណៈនេះគ្រប់ទីកន្លែង។ តាមពិតមានបច្ច័យមិនល្អជាច្រើន នៅពេលដែលពុំមានបង្គន់អនាម័យនៅទីសាធារណៈ រឺ តំបន់រមណីយដ្ឋានទេសចរណ៍។

បន្ទាប់ពីមានការចុះសិក្សា ស្រាវជ្រាវនៅតំបន់កោះឧកញ៉ាតីមក បានឲ្យយើងបានដឹងច្បាស់នៅតំបន់នោះលើកលែងតែ តំបន់រមណីយដ្ឋានកែច្នៃចំការស្នេហ៍ គ្រប់កន្លែងនៅតំបន់កោះនោះ គឺពុំទាន់មាន បង្គន់អនាម័យតាមទីសាធារណៈ សំរាប់ឲ្យទេសចរដែលមកកំសាន្តនៅទីនោះនៅឡើយទេ។ ដោយសារតំបន់កោះឧញ៉ាតី មានសក្តានុពលទាក់ទាញចំពោះធម្មជាតិ និងខ្យល់អាកាសបរិសុទ្ធ បច្ចុប្បន្ននៅទីនោះកំពុងមានការទាក់ទាញទេសចរបែបជិះកង់។ ការពុំមានបង្គន់គ្រប់គ្រាន់អាចជាកត្តានាំឲ្យក្លាយជាបញ្ហាប្រឈមចំពោះតំបន់ទេសចរណ៍មួយនេះ ក្នុងពេលអនាគត។ យើងអាចលើកយកឧទាហរណ៍មួយមកបញ្ជាក់ ដោយសារមូលហេតុនេះហើយទើបទីសាធារណៈមួយចំនួនជាពិសេស នៅតាមច្រាំងទន្លេ មុខព្រះបរមរាជវាំង តែងតែជះក្លិនមិនល្អ ដោយសារ

តែមានការបន្ទោរបង់ ឬបត់ជើងតូចពាសវាលពាសកាល។ ចំណុចនេះ មកពីខ្វះខាតបង្គន់អនាម័យ ហើយមួយទៀតរួមផ្សំជាមួយ ឥរិយាបថរបស់ពលរដ្ឋខ្មែរមួយចំនួន ដែលមិនយកចិត្តទុកដាក់ និង មិនយល់ពីបញ្ហាអនាម័យ។ ហេតុដូច្នេះហើយជាហេតុធ្វើឲ្យបរិយាកាសដ៏ស្រស់ស្អាតជាពិសេស កន្លែងកម្សាន្តពោរពេញទៅដោយក្លិនមិនល្អ ប៉ះពាល់ដល់អារម្មណ៍ទេសចរដែលមកកំសាន្ត ជាពិសេសទេសចរអន្តរជាតិ។

**២.៣.២ បរិស្ថានសំរាម**

បន្ទាប់ពីធ្វើការចុះសង្កេតជុំវិញតំបន់កោះឧកញ៉ាតីតី ពុំទាន់មានធុងសំរាមសាធារណៈនៅឡើយទេ បើតាមការស្ទង់មតិ១០០ % នៃទេសចរ បាននាំគ្នាគាំទ្រឲ្យមានការដាក់ជាធុងសំរាមតាមផ្លូវសំខាន់ៗមួយចំនួន។ បញ្ហាមួយឲ្យកត់សំគាល់ និង គួរឲ្យយកចិត្តទុកដាក់មួយទៀតនោះ គឺភូមិចុងកោះ ផ្លូវឆ្ពោះទៅតំបន់ទេសចរណ៍ម៉ូណៃមេគង្គ ព្រមទាំងជិតវត្តចុងកោះ តាមកៀនផ្លូវទាំងនោះ ប្រមូលផ្ដុំទៅដោយកាកសំណល់សំរាម និងប្លាស្ទិចជាច្រើន ដែលអនាគតទៅចំនួនសំរាមដែលចោលគ្មានសណ្ដាប់ធ្នាប់ទាំងនោះនិងមានការកើនឡើង ហើយនាំឲ្យមានការកង្វក់ គ្មានអនាម័យដល់តំបន់ធម្មជាតិមួយនេះ។

**២.៣.៣ សេវាកម្មម្ហូបអាហារ និង ការស្នាក់នៅ**

ដូចដែលជាយើងដឹងស្រាប់ហើយថា តំបន់រមណីយដ្ឋានមួយអាចរីកចំរើន ព្រមទាំងទាក់ទាញទេសចរបាន គឺមិនអាចផ្អែកតែលើកត្តាទេសភាពល្អត្រកាលនោះទេ ប៉ុន្តែសេវាកម្មម្ហូបអាហារ និងការស្នាក់នៅ ក៏ចូលរួមជាផ្នែកសំខាន់ក្នុងការអភិវឌ្ឍផងដែរ។ សំរាប់តំបន់ទេសចរណ៍កោះឧកញ៉ាតី ផ្នែកសេវាកម្មម្ហូបអាហារពិតជាមានបញ្ហាមួយដែលត្រូវកែប្រែយ៉ាងប្រាកដ។ បញ្ហាគឺត្រង់ថាផ្សារធំជាងគេនៅតំបន់នោះ ចាប់បិទមុនម៉ោង ១២ ដែលជាម៉ោងបាយថ្ងៃត្រង់ ដែលជាផលវិបាកសំរាប់ទេសចរក្នុងការស្វែងរកកន្លែងទិញម្ហូបអាហារ តាមការអង្កេតឃើញ ចំពោះទេសចរជាតិពួកគាត់ត្រូវធ្វើការខ្ចប់ម្ហូបមកញ៉ាំខ្លួនឯង។ ចំពោះការស្នាក់នៅក៏ជាករណីសិក្សាមួយគួរ ឲ្យមានការយកចិត្តទុកដាក់ផងដែរ ព្រោះក្រៅពីតំបន់រមណីយដ្ឋានចំការស្នេហ៍ទៅតាមភូមិគឺពុំទាន់មានជាខ្ទម ឬកន្លែងអង្គុយលេងសំរាប់ភ្ញៀវទេសចរនោះទេ Homestay ក៏ពុំទាន់មាន ដែលវាជាបញ្ហាសំរាប់ប្រជាជនក្នុងតំបន់ ដោយពួកគាត់បាត់បង់ឱកាសក្នុងការទទួលបានចំនូលបន្ថែមពីវិស័យទេសចរណ៍។

## ២.៤ របកគំហើញនៃការសិក្សាស្រាវជ្រាវនៃតំបន់កោះឧកញ៉ាតី

### ២.៤.១ ការសម្ភាសជាមួយប្រជាជន

យោងតាមការបង្កើតជាកំរងសំនួរសម្ភាសជាមួយប្រជាជន នៅក្នុងឃុំកោះឧកញ៉ាតីដែលយើងដៅយកចំនួនប្រជាជន ១០០ នាក់ ដែលមានអាយុចាប់ពី១៨ ដល់ ៣០ឆ្នាំ ចំនួន ៥៦ភាគរយ អាយុ ៣១ ដល់ ៥០ឆ្នាំ ៤៥ភាគរយ និង អាយុ ៥១ ដល់ ៦០ឆ្នាំ ៩ភាគរយ។ ការវិភាគទិន្នន័យជាមួយប្រជាជននៅទីនោះ ដោយសារយើងចង់សិក្សាពីប្រជាជនក្នុងតំបន់ ពីការយល់ដឹងរបស់ពួកគេចំពោះទេសចរណ៍ បញ្ហាប្រឈម និង ការប្រកបរបបកសិកម្មផ្សេងៗនៅក្នុងតំបន់។

ផ្អែកទៅលើគំនូសតាងខាងក្រោមបង្ហាញពីអាយុ និងភាគរយប្រជាជនដែលចូលរួមឆ្លើយសំណួរភាគច្រើនចាប់ពីអាយុ ១៨ - ៣០ឆ្នាំ ចំនួន ៥០ភាគរយ និង ៣១ - ៥០ឆ្នាំ ចំនួន ៤០ភាគរយ ដោយអាចឲ្យយកមកធ្វើការវិភាគជាទន្និន័យបានយ៉ាងសារមានប្រសិទ្ធភាព ដោយសារប្រជាជនស្ថិតនៅក្នុង វ័យអាយុ ១៨ - ៣០ឆ្នាំ ពួកគាត់ជាប្រជាជនស្រទាប់ថ្មីដែលមានគំនិត និងការអភិវឌ្ឍការធ្វើរបរកសិកម្មរបស់គាត់ដោយប្រើបច្ចេកទេសថ្មី ចំណែកប្រជាជនដែលស្ថិតនៅក្នុងវ័យ ៣១-៥០ឆ្នាំ គាត់មានបទពិសោធន៍ច្រើនក្នុងការឲ្យជាគំនិតយោបល់ ព្រមទាំងការយល់ដឹងពីបញ្ហាជុំវិញតំបន់ដែលគាត់រស់នៅ។ (**សូមពិនិត្យរូបទី១**)

(រូបទី១)ស្តីពីអាយុរបស់ប្រជាជនក្នុងតំបន់ផ្ទាល់




តាមការសាកសួរ យើងបានកំណត់បានថា ប្រជាជនដែលយើងបានធ្វើការសាកសួរទាំងពីភេទស្ត្រីមាន ៥៥ ភាគរយ និង បុរស ៤៥ ភាគរយ។ (**សូមពិនិត្យរូបទី២**)

(រូបទី២) ភេទរបស់ប្រជាជនក្នុងតំបន់




តាមការស្រាវជ្រាវ និង សំភាសន៍ យកកំណត់បានតួលេខពីមុខរបរប្រជាជនក្នុងតំបន់កោះឧកញ៉ាតី ដូចក្រាបដែលបានបង្ហាញខាងក្រោម ៦០ភាគរយនៃប្រជាជនក្នុងតំបន់នោះប្រកបរបរធ្វើចំការ។

**(សូមពិនិត្យរូបទី៣)**

**(រូបទី៣) តារាងមុខរបរប្រជាជនក្នុងតំបន់**




**សំណួរទី១** ទាក់ទងនិងចំណូលជាមធ្យមបានប៉ុន្មានក្នុងមួយថ្ងៃក្នុងការប្រកបរបរប្រចាំថ្ងៃរបស់ពួកគាត់។ សំណួរនេះមានសារៈសំខាន់ ព្រោះបានបញ្ជាក់ឲ្យយើងបានដឹងពីកត្តាជីវភាពប្រជាជនក្នុងតំបន់នោះ ប្រាក់ចំណូលក្នុងការផ្គត់ផ្គង់គ្រួសារប្រចាំថ្ងៃជាដើម។ ក្នុងនោះយើងបានលើកឡើងពីកត្តាប្រាក់ចំនូលពី ក្រោម៥ ដុល្លារ មាន ៥ភាគរយ ដោយពួកគាត់ប្រកបរបរជាជាងប៉ះកង់ និង លក់របស់របររបស់ហូបនៅតាមផ្ទះដូចជាចេក ស្វាយជាដើម។ ចំនែកឯ ៥ ដល់១០ ដុល្លារ មាន ២០ភាគរយ ជាអាជីវករនៅក្នុងផ្សារដែលលក់ដូរតិចតួច និង ១០ដុល្លារឡើងទៅ ៨០ភាគរយ ដែលពួកគាត់ភាគច្រើនលក់ជាបន្លែ ត្រីសត្វ និង របស់របរប្រើប្រាស់ផ្សេងៗ បន្ទាប់ពីធ្វើការសំភាសន៍ជាមួយពួកគាត់ក្រុមប្រជាជនទាំងនេះ អាចរកប្រាក់ជាមធ្យម ១០ ម៉ឺនក្នុងមួយថ្ងៃ។**(សូមពិនិត្យរូបទី៤)**

**(រូបទី៤) តារាងចំនួលប្រជាជនក្នុងតំបន់**




**សំណួរទី២** ទាក់ទងនិងការប្រកបរបរកសិកម្មរបស់ប្រជាជន ក្នុងសំនួរនេះមានសារៈសំខាន់សំរាប់យើងក្នុងការសិក្សា & ស្រាវជ្រាវ អំពីការធ្វើកសិកម្មរបស់ពួកគាត់ជាលក្ខណៈគ្រួសារ រឺ ជាលក្ខណៈជាអាជីវកម្មត្រូវការជួលកម្មករ? ព្រោះការសិក្សានេះ អាចឲ្យយើងដឹងពីទំហំនៃការប្រកបរបរកសិកម្មដែលពួកគាត់ តាមក្រាហ្វិចដែលបានបង្ហាញខាងក្រោម បញ្ជាក់ឲ្យឃើញថាប្រជាជនក្នុងតំបន់ឧកញ៉ាតី ៦០ភាគរយ នៃប្រជាជនប្រកបរបរកសិកម្មជាលក្ខណៈគ្រួសារ ហើយមានតែ ៤០ភាគរយប៉ុណ្ណោះដែលមានចំការធំហើយត្រូវការជួលកម្មករបន្ថែម ។

(សូមពិនិត្យរូបទី៥)

(រូបទី៥) ភាគរយការដាំដុះរបស់ប្រជាជនក្នុងតំបន់



**សំណួរទី៣** ពាក់ពន្ធ័និងបន្លែ និង ភោគផលដែលគាត់យកមកលក់មានប្រភពមកពីណា? ក្នុងសំនួរនេះយើងអាចស្រង់ដឹងពីភាគរយប្រជាជនដែលដាំដុះកសិកម្មក្នុងគោលបំណងជាអាជីវកម្ម មានប៉ុន្មានភាគរយ? ក្នុងគោលបំណងព្យាករណ៍ និង កំណត់ប្រជាជនដែលប្រកបកសិកម្មខ្នាតតូច&ធំ តាមការសំភាសន៍ប្រជាជននៅតាមផ្សារ ៥០ភាគរយ គឺយកភោជផលទាំងនោះមកលក់ដោយការដាំដុះផលដំណាំខ្លួនឯង និង ៤៥ភាគរយទៀត គឺយកពីគេមកលក់បន្ត ចំណែកឯ ៥ភាគរយ ទៀត គឺគាត់បេះកសិផលដែលវាដុះដោយឯកឯងយកមកលក់។

**(សូមពិនិត្យរូបទី៦)**

**(រូបទី៦) ប្រភពការលក់ភោគផលរបស់ប្រជាជនក្នុងតំបន់**




**សំណួរទី៤** ផ្អែកក្នុងសំនួរនេះ សំខាន់សំរាប់អ្នកសិក្សាទាំងឡាយដែលចង់ដឹងពីការប្រើឧបករណ៍ក្នុងការធ្វើកសិកម្មរបស់ប្រជាជនក្នុងតំបន់នោះ។ តាមការសង្កេត និង សំភាសន៍ ជាមួយប្រជាជនផ្ទាល់ ពួកគាត់ភាគច្រើនប្រើប្រាស់ម៉ាស៊ីនដូចជា គោយន្ត ត្រាក់ទ័រក្នុងការធ្វើចំការ មានចំនួន ៦៥ភាគរយ ដូចដែលគំនូរតាងបានបង្ហាញនៅខាងក្រោម ចំពោះប្រជាជនដែលប្រើប្រាស់សត្វពាហនៈ ដូចជាគោឬក្របីជាដើម មាន៣៥ភាគរយ ហើយសត្វទាំងនោះគេភាគច្រើនគឺចិញ្ចឹមសំរាប់ទុកលក់ឲ្យឈ្មួញ។ **(សូមពិនិត្យរូបទី៧)**

**(រូបទី៧) មធ្យោបាយប្រើប្រាស់ធ្វើកសិកម្មរបស់ប្រជាជនក្នុងតំបន់**




**សំណួរទី៥** ក្នុងសំនួរនេះពាក់ពន្ធ័និងការប្រើប្រាស់ជីក្នុងការដាំដុះដំណាំរបស់ពួកគាត់។ តាមការសាកសួរអ្នកភូមិដោយសារពួកគាត់ភាគច្រើនធ្វើចំការរបស់គាត់ជាលក្ខណៈគ្រួសារខ្នាតតូច ម្យ៉ាងទៀតដោយសារអាជ្ញាធរបានអប់រំពីជីធម្មជាតិច្រើន ដូចដែលក្រាបបានបញ្ជាក់នៅខាងក្រោម ការប្រើប្រាស់ជីធម្មជាតិមាន ៤៥ភាគរយ ជីគីមី ៣០ភាគរយ និង ប្រើលក្ខណៈចំរុះមាន ២៥ភាគរយ។

(សូមពិនិត្យរូបទី៨)

(រូបទី៨) ការប្រើប្រាស់ជីធ្វើកសិកម្មរបស់ប្រជាជន




**សំណួរទី៦** ក្នុងក្រាបនេះបញ្ជាក់ពីទីតាំងពេលទទួលផល ពួកគាត់យកផលដំណាំទាំងនោះយកទៅលក់នៅឯណា? តាមការសិក្សា ៤០ភាគរយ នៃប្រជាជនគឺយកទៅលក់នៅឯទីផ្សារ ២០ភាគរយសំដៅទៅលើអ្នកដែលមានអាជីវកម្មហើយយកផលទាំងនោះយកទៅលក់ដល់នៅភ្នំពេញ ២៥ភាគរយ លក់ទៅ ឲ្យឈ្មួញកណ្តាល និង ១៥ភាគរយ គឺលក់តាមភូមិ ឬតាមផ្ទះ ក្នុង ១៥ភាគរយ នេះ

សំដៅទៅលើការលក់នៅពេលរសៀល ឬពេលយប់ដោយសារផ្សារក្នុងតំបន់លក់ត្រឹមតែមួយព្រឹក ហើយនៅពេលរសៀលគឺលក់នៅតាមផ្ទះ។ (សូមពិនិត្យរូបទី៩)

(រូបទី៩) ភាគរយការលក់កសិកម្មរបស់ប្រជាជន




**សំណួរទី៧** ផ្អែកតាមសំនួរនេះ ក្នុងគោលបំណងកំណត់ពីបញ្ហាដែលអាចជាផលប៉ះពាល់ដល់សន្តិសុខ និង សុវត្ថិភាពរបស់ទេសចរមកលេងកំសាន្តនៅតំបន់នោះ។ យើងបានធ្វើការសំភាសន៍ជាមួយអាជ្ញាធរនៅតំបន់នោះ ចំលើយដែលបានមកវិញគឺបញ្ហា សន្តិសុខ ក៏ដូចជា សុវត្ថិភាព នៅតំបន់នោះគឺមានលក្ខណៈល្អប្រសើរ ប៉ុន្តែដើម្បីឲ្យកាន់តែច្បាស់យើងធ្វើការសាកសួរប្រជាជនរស់នៅទីនោះផ្ទាល់ ចំពោះបញ្ហាសន្តិសុខ និងសុវត្ថិភាពនៅតំបន់ឧកញ៉ាតី ប្រជាជនភាគច្រើនដែលយើងសំភាសន៍ គឺពួកគាត់បានឲ្យដឹងថា សន្តិសុខ-សុវត្ថិភាពនៅតំបន់ពួកគាត់ល្អគឺមិនចោទជាបញ្ហាទេ ម្យ៉ាងនៅពេលយប់ក្នុងភូមិនីមួយៗ គឺមានប្រជាការពារក្នុងភូមិប្តូរវេនគ្នាចល័តយ៉ាងតឹងរឹង ។ តាមក្រាបដែលបានបង្ហាញខាងក្រោម ៩០ភាគរយនៃប្រជាជនបានបញ្ជាក់ថា សុវត្ថិភាពនៅតំបន់ល្អណាស់ និង ១០ភាគរយ មធ្យម ចំពោះភាគរយដែលថា សុវត្ថិភាពនៅទីនោះខ្សោយ គឺពុំមាននោះទេ។ (សូមពិនិត្យរូបទី១០)

(រូបទី១០) ការសំភាសន៍ពីបញ្ហាសុវត្ថិភាពរបស់ប្រជាជនក្នុងតំបន់




**សំណួរទី៨** ពាក់ពន្ធ័និងការចុះមកធ្វើការបណ្តុះបណ្តាលពីជំនាញមន្ត្រីនៅមន្ទីរណាមួយ ដែលពាក់ព័ន្ធនឹងការដាំដុះ តាមការសាកសួរនៅអំឡុងឆ្នាំ ២០១៥-២០១៦ មានអង្គការមួយចុះមកធ្វើការបណ្តុះបណ្តាលពីកសិកម្ម និងចែកគ្រាប់ពូជឥតគិតថ្លៃដល់ប្រជាជន។ ប៉ុន្តែប្រជាជនប្រមាណ ៩០ភាគរយប៉ុណ្ណោះដែលបានចូលរួមការបណ្តុះបណ្តាល។ តាមការសំភាសន៍ពីហេតុផលរបស់ប្រជាជនភាគច្រើនដែលមិនបានចូលរួមពួកគាត់យល់ថា គ្រាប់ពូជដែលខាងអង្គការយកមកចែកជាប្រភេទដំណាំប្រភេទថ្មី ព្រមទាំងបច្ចេកទេសត្រូវចំណាយថវិកាច្រើនដែលពួកគាត់ពុំធ្លាប់ដាំហើយ គាត់គិតថាការចំណាយពេល និងដីសំរាប់សាកដំណាំថ្មី ទើបពួកគាត់មិនចង់ខ្វះខ្ជាយថវិកា ទើបពួកគាត់សំរេចចិត្តក្នុងការនៅតែប្រើនូវបច្ចេកទេសដែលគាត់ធ្លាប់ប្រើ ចៀសជាងការផ្លាស់ប្តូរថ្មី។

**សំណួរទី៩** ផ្តោតលើបញ្ហា អាជ្ញាធរក្នុងតំបន់ ក៏ដូចជារដ្ឋាភិបាល ធ្លាប់បានជម្រុញឬលើកទឹកចិត្ត ដល់ការដាំដុះនៅក្នុងតំបន់នេះដែរឬ? តាមការស្រង់មតិពីប្រជាជនក្នុងតំបន់ ពួកគាត់បានសរសើរដល់អាជ្ញាធរតំបន់ ដែលពួកគាត់ព្យាយាមអប់រំប្រជាជនឲ្យមានការដាំជាដើមឈើ ក្នុងការលំអរសោភណ្ឌ័ភាពក្នុងភូមិ ក៏ដូចជាការអភិរក្សរុក្ខជាតិបៃតង កសិផលជាដើម តាមរូបភាពការចែកជាគ្រាប់ពូជ កូនឈើដោយឥតគិតថ្លៃ និង ការចុះអង្កេតព្រមទាំងឲ្យជាយោបល់ទាំងឡាយដល់កសិករក្នុងតំបន់។

**សំណួរទី១០** តាមសំនួរនេះគឺ យើងធ្វើគឺស្រង់មតិពីការពេញចិត្ត ក៏ដូចជាយោបល់ពីប្រជាជនក្នុងតំបន់នេះ ចំពោះការអភិវឌ្ឍតំបន់កោះឧកញ៉ាតី ឲ្យក្លាយជាតំបន់កសិ-ទេសចរណ៍ ១០០ ភាគរយនៃប្រជាជនដែលយើងបានធ្វើការសំភាសន៍ មានការរីករាយ និងពេញចិត្តជាខ្លាំងក្នុងការ

អភិវឌ្ឍ ព្រមទាំងមានការសំណូមពរឲ្យអាជ្ញាធរក្នុងតំបន់ រាជរដ្ឋាភិបាល ក៏ដូចក្រសួងកសិកម្ម ឲ្យជួយគិតគូរពីបញ្ហាតំលៃកសិផលរបស់ពួកគាត់ ពីបញ្ហាទីផ្សារ និងកត្តាធ្លាក់ចុះនៃតំលៃកសិផល។

## ២.៤.២ ការសម្ភាសជាមួយទេសចរ

### ✸ ទេសចរបរទេស

ផ្អែកតាមកំរងសំនួរសម្ភាសដែលយើងបានរៀបចំសំរាប់សំភាសន៍ជាមួយទេសចរអន្តរជាតិមកកំសាន្តនៅក្នុងឃុំកោះឧកញ៉ាតី យើងបានកំណត់ចំនួនភ្ញៀវទេសចរចំនួន ១០០នាក់ តែភ្ញៀវទេសចរបរទេសដែលបានសហការ និង ផ្តល់ពេលវេលាឲ្យយើងធ្វើការសំភាសន៍ជាមួយមានចំនួន ៤៥ នាក់ ដែលមានអាយុចាប់ពី ២២ ដល់ ៣០ឆ្នាំ ចំនួន ៥៨ភាគរយ អាយុ ៣១ ដល់ ៥០ឆ្នាំ ៣៣ភាគរយ និង អាយុ ៥១ ដល់ ៦០ឆ្នាំ ៩ភាគរយ។ ផ្អែកទៅលើគំនូសតាងខាងក្រោម បង្ហាញពីអាយុនិងភាគរយភ្ញៀវទេសចរបរទេសដែលចូលរួមឆ្លើយសំណួរភាគច្រើនចាប់ពីអាយុ ១៨ - ៣០ឆ្នាំ ចំនួន ៥០ភាគរយ ដែលអាចឲ្យយកមកធ្វើការវិភាគជាទន្និន័យបានយ៉ាងច្បាស់លាស់ និង មានប្រសិទ្ធភាព ដោយសារប្រជាជនស្ថិតនៅក្នុងវ័យនេះ ពួកគាត់ជាទេសចរដែលបានយល់ដឹងច្រើនពីតំបន់ទេសចរណ៍ច្រើន មានគំនិតថ្មីៗ ព្រមទាំងចូលចិត្តធ្វើដំណើរទេសចរណ៍ច្រើន។

(សូមពិនិត្យរូបទី១)

(រូបទី១)ស្តីពីអាយុរបស់ទេសចរបរទេស




ផ្អែកទៅលើការសំភាសន៍ យើងបានរកឃើញចំនួនភ្ញៀវទេសចរដែលចូលមកកំសាន្តនៅតំបន់កោះឧកញ៉ាតី ភ្ញៀវទេសចរជាស្រ្តីមាន ៦០ភាគរយ ចំណែកបុរសមាន ៤០ភាគរយ។ ដែលបានបង្ហាញឲ្យយើងសន្និដ្ឋានបានថា ភ្ញៀវទេសចរមកកំសាន្តនៅតំបន់កោះឧកញ៉ាតីភាគច្រើនជាស្រ្តីច្រើនជាងបុរស។ (សូមពិនិត្យរូបទី២)

(រូបទី២)ស្តីពីភេទរបស់ទេសចរបរទេស




**សំណួរទី៣** សំណួរនេះពាក់ពន្ធ័ពីប្រទេសកំណើតដែលភ្ញៀវទេសចរដែលមកកំសាន្តនៅតំបន់នេះ ដែលអាចឲ្យយើងកំណត់ពីសញ្ជាតិ និង ចំណង់ចំណូលចិត្តរបស់ភ្ញៀវទេសចរបរទេសបាន។ តាមការសាកសួរយើងអាចបែងចែកដូចក្រាបដែលបង្ហាញខាងក្រោម កាណាដា ៥ភាគរយ សហរដ្ឋអាមេរិច ១៥ភាគរយ ចិន ១០ភាគរយ កូរ៉េ ១០ភាគរយ អង់គ្លេស ១៥ភាគរយ អូស្ត្រាលី ១៥ភាគរយ ជនជាតិខ្មែរ ៣០ភាគរយ។ (**សូមពិនិត្យរូបទី៣**)

**(រូបទី៣)ស្តីពីសញ្ជាតិភ្ញៀវទេសចរ**




## ✸ ទេសចរជាតិ

យោងតាមកំរងសំនួរដែលយើងបានរៀបចំសំរាប់សំភាសន៍ជាមួយទេសចរជាតិមកកំសាន្តនៅក្នុងឃុំកោះឧកញ៉ាតី យើងបានកំណត់ចំនួនភ្ញៀវទេសចរចំនួន ១០០នាក់ ដែលមានអាយុចាប់ពី ១៨ ដល់ ៣០ឆ្នាំ ចំនួន ៦០ភាគរយ អាយុ ៣១ ដល់ ៥០ឆ្នាំ ៤០ភាគរយ និង អាយុ ៥១ ដល់ ៦០ឆ្នាំ ១០ភាគរយ។ ផ្អែកទៅលើគំនូសតាងក្រាបខាងក្រោម យើងបានក្រុមអាយុភ្ញៀវទេសចរចាប់ពី

អាយុ ១៨ - ៣០ឆ្នាំ ចំនួន ៦០ភាគរយ ដែលពួកគាត់ភាគច្រើនមកកំសាន្តជាលក្ខណៈក្រុម ចំណែកភ្ញៀវទេសចរអាយុ ៣១ ដល់ ៥០ឆ្នាំ ភាគច្រើនជាទេសចរក្រុមជិះកង់ ចំនែកឯ ១០ភាគរយ គឺជាវ័យដែលគាត់មកជាមួយក្រុមគ្រួសាររបស់គាត់។ **(សូមពិនិត្យរូបទី៤)**

**(រូបទី៤)ស្តីពីអាយុភ្ញៀវទេសចរជាតិ**




យោងទៅតាមការសំភាសន៍ ចំនួនភ្ញៀវទេសចរជាតិដែលចូលមកកំសាន្តនៅតំបន់កោះឧកញ៉ាតី ភ្ញៀវទេសចរជាស្ត្រីមាន ៥៥ភាគរយ ចំណែកបុរសមាន ៤៥ភាគរយ។ ដែលបានបង្ហាញឲ្យយើងសន្និដ្ឋានបានថា ភ្ញៀវទេសចរមកកំសាន្តនៅតំបន់កោះឧកញ៉ាតីទាំងភេទស្ត្រី-បុរស គឺមានចំនួនប្រហាក់ប្រហែលគ្នា។ **(សូមពិនិត្យរូបទី៥)**

**(រូបទី៥)ស្តីពីភេទភ្ញៀវទេសចរជាតិ**



**សំណួរទី៤** ចំពោះសំនួរនេះ យើងធ្វើការស្រាវជ្រាវពីចំនួនភាគរយដែលធ្លាប់មកកំសាន្តនៅក្នុងតំបន់កោះឧកញ៉ាតីលើសពីមួយដង។ បើតាមការសំភាសន៍ជាមួយភ្ញៀវទេសចរជាតិ & អន្តរជាតិ យើងទទួលបានលទ្ធផលដូចដែលបានបង្ហាញក្នុងក្រាបខាងក្រោម ៥៥ភាគរយ នៃភ្ញៀវទេសចរដែលភាគច្រើនជាភ្ញៀវជាតិពួកគាត់ចូលចិត្តមកលេងកំសាន្តនៅតំបន់កោះឧកញ៉ាតីជាញឹកញាប់ ជាពិសេសនៅថ្ងៃចុងសប្តាហ៍ ដោយជិះកង់ជាក្រុម ឬមកកំសាន្តជាលក្ខណៈគ្រួសារ ចំនែក ៤៥ភាគរយ ទៀតភាគច្រើនជាភ្ញៀវទេសចរអន្តរជាតិ ដែលចូលមកក្នុងគោលបំណងទស្សនារមណីយដ្ឋានចំការស្នប់ និងជិះរ៉ឺម៉ក់កង់បី មើលទេសភាពជុំវិញ។ (**សូមពិនិត្យរូបទី៦**)

**(រូបទី៦) ក្រាបបង្ហាញពីការមកកំសាន្តរបស់ភ្ញៀវ**




**សំណួរទី៥** ក្នុងសំនួរនេះ គឺសំខាន់ក្នុងការស្វែងរកប្រភពដែលទាំងភ្ញៀវទេសចរជាតិ &អន្តរជាតិស្គាល់តំបន់កោះឧកញ៉ាតីតាមរបៀបណា? ដូចដែលបានធ្វើការសំភាសន៍ ៤៥ភាគរយ គឺស្គាល់តាមមិត្តភក្តិណែនាំ ៣០ភាគរយ គឺមកជាមួយសាច់ញាតិ ឬគ្រួសារ ២០ភាគរយ គឺស្គាល់តាមប្រពន្ធ័អ៊ីនធឺណេត និង ៥ភាគរយ ពីហេតុផលផ្សេងៗទៀត។ (**សូមពិនិត្យរូបទី៧**)

**(រូបទី៧) ប្រភពពីការស្គាល់តំបន់កោះឧកញ៉ាតី**




**សំណួរទី៩** ចំពោះសំនួរនេះគឺជាសំនួរដែលពាក់ពន្ធ័ពីការដឹងលឺ និងស្គាល់របស់ភ្ញៀវទេសចរពីទេសចរណ៍បែបកសិទេសចរណ៍។ យោងតាមការសំភាសន៍ជាមួយទេសចរជាច្រើន ភ្ញៀវទេសចរជាតិមួយភាគធំប្រហែល ៥០ភាគរយ គឺមិនបានធ្លាប់ស្គាល់ពីកសិទេសចរណ៍នោះទេ ពួកគាត់មកលេងតំបន់នេះផ្តោតលើធម្មជាតិជាង ១០ភាគរយទៀតធ្លាប់លឺ ចំណែកចំពោះភ្ញៀវទេសចរអន្តរជាតិ ៤០ភាគរយនៃភ្ញៀវគឺស្គាល់ពីកសិទេសចរណ៍ច្រើន ។ (**សូមពិនិត្យរូបទី៨**)

**(រូបទី៨) ប្រភពពីការស្គាល់ពីកសិទេសចរណ៍**




**សំណួរទី១០** ក្នុងចំនុចនេះ តាមបទសំភាសន៍គឺ យើងចង់ដឹងចំណង់ចំនូលចិត្តពីតំបន់ទេសចរណ៍គោលដៅដែលពួកគាត់ចង់ទៅទស្សនា លទ្ធផលដែលយើងទទួលបានដូចបានបង្ហាញក្នុងក្រាបខាងក្រោម ទេសចរណ៍វប្បធម៌មាន ៣០ភាគរយ ទេសចរណ៍ធម្មជាតិ ២០ភាគរយ ទេសចរណ៍តំបន់សមុទ្រ ២៥ភាគរយ កសិទេសចរណ៍ ២០ភាគរយ។(**សូមពិនិត្យរូបទី៩**)

(រូបទី៩) ប្រភេទគោលដៅទេសចរណ៍



# ជំពូកទី ៣

# ទស្សនាទានក្នុងការរៀបចំ
# អភិវឌ្ឍន៍តំបន់កោះ
# ឧកញ៉ាតីក្លាយជា
# តំបន់កសិទេសចរណ៍

# ជំពូកទី ៣

# ទស្សនាទានក្នុងការរៀបចំអភិវឌ្ឍន៍តំបន់កោះឧកញ៉ាតីក្លាយជាតំបន់កសិទេសចរណ៍

ដើម្បីជំរុញ អភិវឌ្ឍតំបន់កោះឧកញ៉ាតីឲ្យក្លាយជាតំបន់សក្តានុពលកសិទេសចរណ៍មួយបាន និងការរៀបចំសណ្តាប់ធ្នាប់នៅទីនោះឲ្យរឹតតែប្រសើរ តាមការចុះស្រាវជ្រាវតំបន់នោះបានរកឃើញទស្សនាទានមួយចំនួន ក្នុងការដោះស្រាយបញ្ហាប្រឈម និង អភិវឌ្ឍន៍ កែលំអរ ឲ្យរឹតតែមានភាពទាក់ទាញភ្ញៀវទេសចរ។ ប្រសិនបើតំបន់ទេសចរណ៍មួយនេះ ចង់ប្រែក្លាយជាតំបន់សក្តានុពលបែបកសិទេសចរណ៍បាន គួរយកចិត្តទុកដាក់លើ ទស្សនាទានមួយចំនួនតាមដំណាក់កាលនីមួយៗ ដូចខាងក្រោម ៖

## ៣.១ អនាម័យ និង បរិស្ថាន

### ក. បង្គន់អនាម័យ

បង្គន់អនាម័យឬបន្ទប់ទឹកសាធារណៈ គឺជាបញ្ហាអាទិភាព ខណៈដែលប្រទេសកម្ពុជាមានការអភិវឌ្ឍ តំបន់កំសាន្តនានា ដូចជាទីលំហែកាយសាធារណៈ ទីប្រជុំជនទេសចរណ៍ និងរមណីយដ្ឋានធម្មជាតិ នានានៅតាមបណ្តាខេត្ត-រាជធានី។ កង្វះខាតទីតាំងសំខាន់ទាំងនេះ បានជះឥទ្ធិពលខ្លាំងដល់វិស័យទេសចរណ៍ និងមុខមាត់ប្រទេសជាតិ ជាពិសេសជុំវិញបញ្ហាអនាម័យនិងបរិស្ថាន។

ចំពោះតំបន់រមណីយដ្ឋានកែច្នៃចំការស្នេហ៍ ទៀតសោត ក្នុងរមណីយដ្ឋាននោះ បន្ទប់ទឹកមានពីរកន្លែង សរុប៨ បន្ទប់ នៅជាប់កន្លែងតម្បាញ ផ្នែកខាងមុខមាន៤ បន្ទប់ ស្ត្រី ២ បន្ទប់ និង បុរស ២ បន្ទប់ ប៉ុន្តែបន្ទាប់ពីការចុះទៅផ្ទាល់ឃើញថាបន្ទប់ទឹកមានសភាពមិនស្អាត ធុំក្លិន និង គ្មានអនាម័យទាំងបង្គន់ ព្រមទាំងជញ្ជាំងឥដ្ឋ។ ចំណែក៤ បន្ទប់ទឹកទៀតស្ថិតនៅផ្នែកខាងក្រោយ ជាលក្ខណៈបន្ទប់រួមមានលក្ខណៈ ស្អាតជាងផ្នែកខាងមុខច្រើន៧០% នៃទេសចរដែលមកកំសាន្តនៅទីនោះចង់ឲ្យមានការកែប្រែពីបញ្ហាបង្គន់ បញ្ហានេះ អ្នកគ្រប់គ្រងគួរតែមានការដោះស្រាយក្នុងការការពារហានីយភ័យ ដែលអាចឲ្យមានការបាត់បង់ភ្ញៀវទៅកំសាន្តតំបន់នោះ។

ជាដំណោះស្រាយ ដើម្បីកាត់បន្ថយចរិកបន្ទោរបង់ពាសវាលពាសកាល គប្បីរដ្ឋអំណាចមានយន្តការច្បាស់លាស់ពោលគឺ ធានាឲ្យបាននូវបង្គន់អនាម័យសាធារណៈនៅគ្រប់តំបន់កំសាន្តសប្បាយ ទីប្រជុំជននានា។ ដោយសារប្រទេសកម្ពុជានៅមានពលរដ្ឋក្រីក្រច្រើន ការរិះថាំប្រាក់បន្តិចបន្តួចគឺជាការចាំបាច់ ដូច្នេះគួរតែបង្កើតឲ្យមានទាំងពីរយ៉ាងគឺ បង្គន់បង់លុយដើម្បីទ្រទ្រង់ការសម្អាត និងបង្គន់បង់លុយតាមការស្ម័គ្រចិត្ត។ ប្រសិនបើនៅតែមានការបន្ទោរបង់តាមទីសាធារណៈទៀត នោះវាជាភារៈរបស់អាជ្ញាធរមានសមត្ថកិច្ច ដែលត្រូវចាត់វិធានការណែនាំ ដាក់ពិន័យ

ឬព្រមានឲ្យអ្នកប្រព្រឹត្តខុសវិលទៅរកភាពស្អាតស្អំ ផ្លាស់ប្តូរទំលាប់មិនល្អចោល ដើម្បីបរិស្ថានមួយដែលអាចទទួលយកបានទាំងពលរដ្ឋខ្មែរគ្នាឯង និងទេសចរក្រៅប្រទេស។

ដូចគ្នានេះដែរនៅតាមបណ្តាខេត្តមួយចំនួន នៅតាមតំបន់ទេសចរណ៍សំខាន់ៗនៅទូទាំងប្រទេសត្រូវគិតពីបញ្ហាបង្គន់និងបន្ទប់ទឹកជាការចាំបាច់ និងចៀសវាងការកំរិតយកប្រាក់ច្រើនពេកជាហេតុធ្វើឲ្យមនុស្សមានគំនិតគេចវេសពីការចូលរួមរក្សាអនាម័យនិងបរិស្ថាន។ ការបង្កើតឲ្យមានបង្គន់អនាម័យនៅតាមទីសាធារណៈសំខាន់ៗ ត្រូវតែមានការគិតគូរមុនគេ កន្លែងអនាម័យនេះទៀតសោធ គឺមិនមែនគ្រាន់តែឲ្យមាននោះទេ ត្រូវមានផ្លាកសញ្ញានិងការណែនាំឲ្យបានត្រឹមត្រូវក្នុងការថែរក្សាបរិស្ថានតំបន់ទេសចរណ៍ឲ្យមានភាពស្រស់ត្រកាល ទាំងខ្យល់អាកាស និងសក្តានុពលទេសភាពក្នុងតំបន់គោលដៅទាំងនោះ។

**ខ. សំរាម**

អាជ្ញាធរក្នុងតំបន់គួរតែគិតគូរក្នុងការដាក់ធុងសំរាម តាមទីតាំងសំខាន់ៗ សំរាប់ទុកឲ្យទេសចរដែលមកកំសាន្តបោះចោលកាកសំណល់ផ្សេងៗ។ ធនធានធម្មជាតិ និងបញ្ហាបរិស្ថាននៃតំបន់នេះរួមទាំងបញ្ហានៃការគ្រប់គ្រងកាកសំណល់អាជ្ញាធរតំបន់ គួរត្រួតពិនិត្យ និងរៀបចំគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងកាកសំណល់សំរាមទាំងឡាយ នៅក្នុងតំបន់ទេសចរណ៍។ ដូច្នេះអាជ្ញារធររួមទាំងប្រជាជន គួរតែគប្បីមានវិធានការណ៍ដោះស្រាយលើបញ្ហាដូចខាងក្រោម៖

- ត្រូវអនុវត្តន៍ និងត្រួតពិនិត្យរាល់ការចោលសំរាមរបស់ប្រជាជន និងទេសចរដែលមកកម្សាន្ត ធ្វើការណែនាំចំពោះប្រជាជន និងទេសចរណាដែលបានចោលសំរាមពាសវាលពាសកាល។
- ត្រូវដាក់ស្លាកសញ្ញាហាមចោលសំរាម និងការបែងចែកកាកសំណល់ជាមួយនឹងពាក្យស្លោកផ្សេងៗ។
- ត្រូវដាក់ធុងសំរាម នៅតាមតំបន់ពិសេសៗដូចជា កន្លែងសាធារណៈ ផ្សារ កន្លែងកម្សាន្តនានា ព្រមទាំងបែងចែកធុងសំរាមតាមប្រភេទនីមួយៗដូចជា សំរាមសើម សំរាមស្ងួតនិងសំរាមកែច្នៃ។
- ត្រូវរៀបចំឲ្យមានអ្នកប្រមូលសំរាមជារាងរាល់ថ្ងៃ ឬសប្តាហ៍។
- ត្រូវរៀបចំឡដុតសំរាមសម្រាប់កាកសំណល់ណាដែលមិនរលួយឲ្យបានត្រឹមត្រូវ។
- ធ្វើការណែនាំប្រជនពលរដ្ឋឲ្យពីវីធីសាស្រ្តក្នុងការកែច្នៃសំរាមឲ្យមានប្រយោជន៍ ដូចជាកែច្នៃសំរាមទៅជាជីកំប៉ុកសម្រាប់ដាក់ចំការដំណាំផ្សេងៗរបស់ពួកគាត់។

- លើកទឹកចិត្ត រឺផ្តល់ជាធុងសំរាម ដល់ប្រជាពលរដ្ឋមួយចំនួនដែលមានផ្ទះនៅតាមតំបន់កំសាន្តនានា ឬប្រជាជនដែលមានផ្ទះជាប់ផ្លូវធ្វើដំណើរ ដើម្បីឲ្យពួកគាត់ដាក់ធុងសំរាមនៅមុខផ្ទះពួកគាត់ ចៀសវាងការចោលសំរាមតាមផ្លូវ និង តំបន់ទេសចរណ៍ ដែលបណ្តាលឲ្យមានភាពកង្វក់ដល់បរិស្ថាន
- បន្ថែមពីលើនេះ អាជ្ញាធរគួរអប់រំប្រជាពលរដ្ឋឲ្យចូលរួមការពារថែរក្សាអនាម័យ ការពារបរិស្ថាន ការគ្រប់គ្រងកាកសំណល់ឲ្យបានត្រឹមត្រូវ ដើម្បីការពារសុខភាព សុវត្ថិភាពជីវិតរស់នៅរបស់មនុស្សសត្វ និងរុក្ខជាតិតទៅអនាគត ដែលវាជាចលនាមួយដែលបង្កើនការចូលរួមយ៉ាងផុសផុលពីសាធារណជននិងអាជ្ញាធរ ក្នុងការលើកកម្ពស់គុណភាពបរិស្ថាន កែលម្អសោភ័ណភាពតំបន់ទេសចរណ៍ ពីភាពគ្មានអនាម័យ និង គ្មានសណ្តាប់ធ្នាប់ផ្សេងៗ។

## ៣.២ ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ និងការដឹកជញ្ជូន គឺជាផ្នែកមួយដ៏សំខាន់នៃឧស្សាហកម្មទេសចរណ៍។ បើយោងទៅតាមបទសំភាសន៍ជាមួយភ្ញៀវទេសចរជាតិ និងអន្តរជាតិភាគច្រើនពួកគាត់បានបញ្ជាក់ ផ្លូវថ្នល់នៅកោះឧកញ៉ាតីមានសភាពល្អ ដោយសារផ្លូវបេតុង សមិទ្ធផលថ្មីៗជាច្រើនចាប់ផ្តើមសាងសង់ឡើង ដែលវាពុំជាបញ្ហាចោទទៅលើការធ្វើដំណើរកំសាន្តដល់ទេសចរទេ ដោយសរុបបានថាភាគរយនៃទេសចរពុំមានការរិះគន់ចំពោះផ្លូវថ្នល់នៅទីនោះទេ ប៉ុន្តែតាមការចុះស្រាវជ្រាវ ពួកយើងមានការកត់សំគាល់ចំពោះតំបន់ចុងកោះ អាជ្ញាធរគួរយកចិត្តទុកដាក់បន្ថែមទៀតទៅលើតំបន់ចុងកោះផ្លូវទៅកាន់រមណីយដ្ឋានម៉ូណៃមេគង្គ មានសភាពមិនសូវជាល្អប៉ុន្មាន ផ្លូវជាប្រភេទដីក្រហម ពិសេសក្នុងរដូវភ្លៀងដែលពិបាកក្នុងការធ្វើដំណើរ។ ដូច្នេះក្នុងការសំរួលការធ្វើដំណើរទៅកាន់រមណីយដ្ឋាននោះ អាជ្ញាធរ ក៏ដូចជាម្ចាស់រមណីយដ្ឋាន ដើម្បីទាក់ទាញភ្ញៀវទេសចរ ឲ្យចូលមកទស្សនាតំបន់រមណីយដ្ឋានកំពុងអភិវឌ្ឍថ្មីនេះ គួរយកចិត្តទុកដាក់ពីបញ្ហាសភាពផ្លូវក្នុងតំបន់ចុងកោះផងដែរ។

បន្ទាប់ពីចុះសិក្សាស្វែងយល់ពីតំបន់កោះឧកញ៉ាតី ហេដ្ឋារចនាសម្ព័ន្ធ និងការរៀបចំនៅតំបន់ល្អប្រសើរខ្លាំង យោងតាមបទសំភាសន៍ជាមួយទេសចរភាគច្រើន មានការសរសើរពីការរៀបចំពីតំបន់នោះ ផ្ទះប្រជាជននៅទីនោះមានការសាងសង់ពីឈើច្រើន ក្នុងស្ថាបត្យកម្មផ្ទះខ្មែរ នៅមុខផ្ទះមានដាំលំអរផ្កាក្រោកយ៉ាងស្រស់ស្អាត ហើយនៅតាមបណ្តោយផ្លូវមានដើមត្នោតអមសងខាងផ្លូវដែលបង្កើនជាទេសភាពមួយដ៏ត្រកាល។

## ៣.៣ សេវាកម្មម្ហូបអាហារ និង ស្នាក់នៅ

អាហារគឺជាធាតុសំខាន់មួយ ក្នុងបទពិសោធន៍នៃការធ្វើដំណើរទេសចរណ៍ របស់ទេសចរជាតិ និងអន្តរជាតិ ដើម្បីភ្លក់នូវរសជាតិម្ហូបអាហារប្លែកពីតំបន់របស់ពួកគាត់រស់នៅ។ ប៉ុន្តែជាមួយនិងវិស័យទេសចរណ៍ ដែលត្រូវបានគេចាត់ទុកថាជាវិស័យវិជ្ជមានមួយនៅក្នុងពិភពលោក ម្ហូបអាហារ ក៏ដើរតួនាទីយ៉ាងចាំបាច់ក្នុងការពិចារណា និងជំរុញទឹកចិត្តទេសចរ ក្នុងការមកដល់គោលដៅរមណីយដ្ឋានមួយ។

ផ្អែកទៅលើការសំភាសន៍ជាមួយភ្ញៀវទេសចរជាតិ និងអន្តរជាតិ ដែលមកកំសាន្តក្នុងរមណីយដ្ឋានចំការស្ពោ្ន ហ៍៨០% នៃទេសចរទាំងនោះចង់ឲ្យអាជ្ញាធរជំរុញ និងអប់រំឲ្យប្រជាពលរដ្ឋក្នុងតំបន់នោះ ក្នុងការបើកបន្ថែមកន្លែងលក់នូវម្ហូបអាហារផ្សេងៗព្រោះប្រសិនបើចង់ជំរុញ ព្រមទាំងការទាក់ទាញទេសចរឲ្យមកកំសាន្តតំបន់នេះរឹតតែច្រើន ហើយបន្ថែមកំរិតប្រាក់ចំនូលដល់ប្រជាជនក្នុងតំបន់អាជ្ញាធរគួរអប់រំអំពី ទេសចរណ៍ដល់ប្រជាជនឲ្យមានការយល់ច្បាស់ ជាមួយអត្តប្រយោជន៍ដែលពួកគាត់ត្រូវទទួលបានក្នុងការអភិវឌ្ឍវិស័យកសិទេសចរណ៍។

• សេវាកម្មស្នាក់នៅ ជាសេវាកម្មមួយដែលចូលរួមជាចំបងសម្រាប់បម្រើដល់ទេសចរ ក៏ដូចជាជួយពន្យាពេលនៃការធ្វើដំណើរកម្សាន្តរបស់ទេសចរឲ្យនៅកម្សាន្តនៅតំបន់កាន់តែយូរ។ ដូចនេះ គួរតែមានការរៀបចំជាផ្ទះលក្ខណគ្រួសារ ឬបន្ទប់ស្នាក់នៅ (Home stay) គួរតែមានការបង្កើតឲ្យមាននៅក្នុងតំបន់នោះ ព្រមទាំងមានគំនិតច្នៃប្រឌិតថ្មី ដូចជាការដាំដំណាំ និងឈើហូបផ្លែជុំវិញផ្ទះ ដើម្បីឲ្យទេសចរមានភាពងាយស្រួលក្នុងការបេះយកបរិភោគ។

## ៣.៤ គ្រប់គ្រងធនធានធម្មជាតិ

ការគ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ធ្វើឡើងដើម្បី ជួយថែរក្សាការពារតំបន់ធម្មជាតិ និងកាត់បន្ថយផលប៉ះពាល់បរិស្ថានធម្មជាតិក៏ដូចជាកាត់បន្ថយនូវរាល់ការប្រែប្រួលអាកាសធាតុនៅលើពិភពលោក។ ដូចនេះក្នុងនាមអាជ្ញាធរ ត្រូវតែមានវិធានការណ៍មួយចំនួនដូចជា៖

- ហាមឃាត់ដាច់ខាតរាល់ការបោះទីតាំងធ្វើសកម្មភាពផ្ទាល់ខ្លួន អាជីវកម្មបណ្តោះអាសន្ន និងសាងសង់សំណង់ផ្សេងៗ នៅតាមដងទន្លេ ដោយត្រូវគិតពីផលប៉ះពាល់ជាចម្បង។
- រៀបចំដាំកូនឈើបន្ថែមដើម្បីបង្កើតសោភ័ណភាព និងបរិយាកាសល្អនៅក្នុងភូមិ។
- ជំរុញ និងលើកទឹកចិត្តប្រជាជនឲ្យចូលរួមស្រលាញ់ និងការពារធនធានធម្មជាតិ ជាពិសេសចូលរួមដាំដើមឈើ។

## ៣.៥ ការគ្រប់គ្រងសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់

នាពេលបច្ចុប្បន្ននេះបញ្ហាភេរវកម្ម ការរីករាលដាលនៃជម្ងឺឆ្លង និងគ្រោះធម្មជាតិ គឺកំពុងតែមានការកើនឡើងទូទាំងពិភពលោក ដែលកំពុងតែមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះបញ្ហាទាំងនេះ។ កត្តាទាំងអស់នេះហើយដែលអាចបង្ករឲ្យមានការគំរាមគំហែងដល់សុវត្ថិភាព និងសន្តិសុខចំពោះទេសចរ។ ដូចនេះបញ្ហាសន្តិសុខ និងសុវត្ថិភាពជាកត្តាសំខាន់ដែលនាំឲ្យទេសចរមានភាពកក់ក្តៅនៅពេលពួកគេធ្វើដំណើរទៅតំបន់ទេសចរណ៍ណាមួយ។ ក្រៅពីនេះបញ្ហាម្ហូបអាហារ ការស្នាក់នៅ និងការធ្វើដំណើរក៏ត្រូវបានទាមទារឲ្យមានលក្ខណៈជាសុភាពទាំងផ្លូវកាយនិងផ្លូវអារម្មណ៍របស់ទេសចរក្នុងកំឡុងពេលធ្វើដំណើរទេសចរណ៍ផងដែរ។ បើទោះបីនៅក្នុងតំបន់កោះឧកញ៉ាតីនោះ មានសន្តិសុខល្អយ៉ាងណាក៏ដោយ ក៏យើងត្រូវតែមានការពង្រឹងបន្ថែមនូវសន្តិសុខ និងសុវត្ថិភាពជូនភ្ញៀវទេសចរដោយមានការចូលរួមពីអាជ្ញាធរដែនដី អាជ្ញាធរមានសមត្ថកិច្ច និងប្រជាជនម្ចាស់ស្រុកផ្ទាល់ដើម្បីអនុវត្តនៅកត្តាមួយចំនួនដូចខាងក្រោមៈ

- ពង្រឹងសន្តិសុខសុវត្ថិភាព និងពង្រីកប្រព័ន្ធការពារបន្ថែមទៀតទៅកាន់តំបន់ជុំវិញកោះ និងជាពិសេស នៅពេលមានទេសចរមកលេងកម្សាន្ត ហើយគ្រប់សន្តិសុខត្រូវមាន ពាក់ឯកសណ្ឋាន បណ្ណសម្គាល់ខ្លួនផ្សេងៗ។ ត្រូវមានស្លាកសញ្ញាសម្រាប់ផ្តល់ព័ត៌មានឲ្យច្បាស់នៅតំបន់ដែលគ្រោះថ្នាក់។
- ត្រូវមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងប្រជាជនម្ចាស់ស្រុក ដើម្បីរៀបចំឲ្យមានមណ្ឌលសុខភាពគ្រប់គ្រាន់ត្រឹមត្រូវទៅតាមតម្រូវការនៅពេលមានភ្ញៀវទេសចរមកកម្សាន្ត ឬប្រជាពលរដ្ឋនៅក្នុងតំបន់នោះជួបបញ្ហាសុខភាព។
- បណ្តុះបណ្តាលប្រជាជនមួយចំនួន ដែលមានចំណាប់អារម្មណ៍ចង់ចេះពីវិធីសង្គ្រោះបន្ទាន់ និងសង្គ្រោះបឋម។
- ត្រូវយកចិត្តទុកដាក់ជាអាទិភាព លើសុវត្ថិភាពចំណីអាហារ អនាម័យ ជាពិសេសនៅតាមរមណីយដ្ឋានទេសចរណ៍ក្នុងតំបន់នោះ និងត្រូវមានយន្តការគ្រប់គ្រង និងត្រួតពិនិត្យអប់រំជាប្រចាំនៅតាមអាហារដ្ឋាននានានៅក្នុងភូមិនិងនៅក្នុងរមណីយដ្ឋានទេសចរណ៍។

## ៣.៦ ការបណ្តុះបណ្តាលធនធានមនុស្ស

វិស័យទេសចរណ៍កម្ពុជាបានផ្តល់ឱកាសការងារប្រមាណ ៦២ម៉ឺននាក់ ស្មើ១៣% នៃការងារសរុបក្នុងប្រទេសរួមចំណែកប្រមាណ១៣%នៃGDP។ ជាការពិតដើម្បីការអភិវឌ្ឍវិស័យទេសចរណ៍មួយប្រកបដោយគុណភាព និរន្តរភាព មានកត្តាគន្លឹះយុទ្ធសាស្ត្រមូលដ្ឋានជាច្រើនក្នុងនោះ កត្តា

ធនធានមនុស្សពិសេសផ្នែក ជំនាញវិជ្ជាជីវៈទេសចរណ៍ជាកត្តាកំណត់ដ៏ចំបងមួយ។ គេមិនអាចនិយាយពីគុណភាពសេវាកម្មទេសចរណ៍បានទេ នៅពេលដែលគេមិនបានគិតគូរដល់ការបណ្តុះបណ្តាលធនធានមនុស្សពិសេសផ្នែកជំនាញវិជ្ជាជីវៈទេសចរណ៍នោះ។ ធនធានមនុស្សជាកត្តាមួយដ៏ចាំបាច់ និងដើរតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យទេសចរណ៍ ហើយដើម្បីធ្វើឲ្យមានការអភិវឌ្ឍទៅបាន គឺត្រូវតែមានធនធានមនុស្សជាចាំបាច់ដើម្បីទទួលបាននូវការបណ្តុះបណ្តាលដែលត្រឹមត្រូវ ហើយធ្វើយ៉ាងណាឲ្យពួកគេបានយល់ច្បាស់ពី អត្ថប្រយោជន៍នៃការចូលរួមថែរក្សា និងការពារធនធានទេសចរណ៍ដែលមានក្នុងតំបន់។ ការផ្តល់ចំណេះដឹងទាក់ទងទៅនឹងវិស័យទេសចរណ៍ ត្រូវរួមបញ្ចូលទាំងរបៀបផ្តល់សេវាកម្មដល់ភ្ញៀវទេសចរ ការឲ្យតម្លៃភ្ញៀវទេសចរដែលមកកម្សាន្តនៅទីនេះ ព្រោះពួកគេជានាំចំណូលដល់ផ្ទាល់ពីទេសចរ។ ដូចនេះយើងគួរបណ្តុះបណ្តាលបន្ថែមទៅលើមុខជំនាញវិជ្ជាជីវៈទេសចរណ៍មួយចំនួនដូចជា៖ ការធ្វើបដិសណ្ឋារកិច្ចល្អចំពោះភ្ញៀវ ការផ្តល់សេវាអាហារ និងភេសជ្ជៈ ជាអ្នកផ្តល់សេវាកម្មស្នាក់នៅ ឬសេវាកម្សាន្តផ្សេងៗដល់ទេសចរ។

ការអប់រំបណ្តុះបណ្តាលមានវិធីសាស្ត្រជាច្រើនដែលអាចប្រើប្រាស់សម្រាប់បណ្តុះបណ្តាលអ្នកជាប់ពាក់ព័ន្ធជាពិសេសអ្នកដែលពឹងអាស្រ័យផ្ទាល់ទៅលើវិស័យទេសចរណ៍ក្នុងតំបន់នេះដូចជា៖

- ចុះអប់រំប្រជាពលរដ្ឋតាមភូមិ
- រៀបចំមជ្ឈមណ្ឌលបណ្តុះបណ្តាលកសិកម្ម នៅក្នុងភូមិដើម្បីឲ្យប្រជាជននៅក្នុងតំបន់ សិស្សនិស្សិត និងភ្ញៀវដែលមានចំណាប់អារម្មណ៍ខាងផ្នែកកសិកម្មអាចមកសិក្សាបាន។
- បណ្តុះបណ្តាលវគ្គខ្លីៗ ពីវិធីសាស្ត្រក្នុងការដាំដុះដំណាំប្រកបដោយគុណភាពល្អ និងទទួលបានផលខ្ពស់ ដល់ប្រជាពលរដ្ឋ។
- ធ្វើការអប់រំតាមរយៈការបិតផ្សាយ តាមកន្លែងសាធារណៈ ឬតាមផ្ទះដែលគេអនុញ្ញាត។

## ៣.៧ ការអភិវឌ្ឍផលិតផល ការស្វែងរកទីផ្សារ និងការផ្សព្វផ្សាយ

គោលដៅក្នុងការអភិវឌ្ឍ គឺត្រូវមានយុទ្ធសាស្ត្រគ្នាក្នុងការដោះស្រាយលើចំណុចមួយចំនួនដូចជា អភិវឌ្ឍផលិតផល ការស្វែងរកទីផ្សារ និងផ្សព្វផ្សាយ។ ចំពោះចំណុចទាំងនេះមានសារៈសំខាន់ក្នុងការរៀបចំអភិវឌ្ឍន៍នៅតំបន់នេះ។ ដូចនេះយើងត្រូវតែយល់អំពីសេដ្ឋកិច្ចទីផ្សារទេសចរណ៍ត្រូវបានកំណត់តាមរយៈតម្រូវការ និងការផ្គត់ផ្គង់ហើយធាតុផ្សំទាំងពីរនេះមិនអាចញែកចេញពីគ្នាបានទេ។ ដោយសារតែការផ្គត់ផ្គត់ផលិតផលទេសចរណ៍ មានការទាក់ទងទាំងស្រុងក្នុងការបម្រើឲ្យវិស័យទេសចរណ៍ និងបំពេញតម្រូវការរបស់ទេសចរដូចជា អាកាសធាតុ សណ្ឋានដី សន្តិសុខ សុវត្ថិភាព សេវាកម្មស្នាក់នៅ សេវាកម្មចំណីអាហារ និងភេសជ្ជៈ ព្រមទាំងកន្លែងកម្សាន្តទាំងឡាយ។ល។

**ក.ការអភិវឌ្ឍផលិតផល**

ការអភិវឌ្ឍផលិតផល បម្រើឲ្យវិស័យទេសចរណ៍ក្នុងរមណីយដ្ឋាន គឺយើងត្រូវផ្ដោតទៅលើស្ថានភាពជាក់ស្ដែង ដោយសារសម្លឹងឃើញនូវចំណុចមួយចំនួនដែលនៃតំបន់កោះឧកញ៉ាតី គួរគប្បីបង្កើតនូវផលិតទេសចរណ៍បន្ថែមមួយចំនួនដូចជា៖

- ការកែច្នៃផលដំណាំក្នុងតំបន់ឲ្យទៅជាផលិតផលផ្សេងៗទៀត ដូចជាផ្លែខ្នុរ ស្វាយ ចេក ឲ្យទៅជាដំណាប់ ឬក៏យកទៅបំពងដោយមានការវេចខ្ចប់ត្រូវត្រឹមត្រូវប្រកបដោយគុណភាព និងមានរស់ជាតិឆ្ងាញ់ ដើម្បីលក់ទៅឲ្យទេសចរបរិភោគ ហើយធ្វើឲ្យពួកគេចងចាំរស់ជាតិមិនភ្លេចដើម្បីមកទីនេះម្ដងទៀត។
- បង្កើតឲ្យមានផ្សារលក់ផលិតផលផ្សេងៗកសិកម្មដែលប្រមូលបានពីចំការ ហើយដាក់លក់ផ្ទាល់នៅក្នុងតំបន់នោះតែម្ដង។
- បង្កើតឲ្យមានកន្លែងធ្វើវត្ថុអនុស្សាវរីយ៍ប្រចាំតំបន់ ដែលវាអាចបញ្ជាក់បានថាជាវត្ថុតំណាងក្នុងតំបន់ ឬប្រទេសហើយវាអាចបញ្ជាក់ថាទេសចរមកកម្សាន្តក្នុងតំបន់នេះ។
- បង្កើតកម្មវិធីផ្សេងៗ ដូចជាការប្រគុំតន្ត្រី ការតាំងពិព័រណ៍ក្នុងតំបន់ ដើម្បីធ្វើមានការទាក់ទាញពីសំណាក់ទេសចរ។
- ពង្រីកផ្ទៃដីការដាំដុះ និងដាំដំណាំ ផ្លែឈើឲ្យបានច្រើនប្រភេទបន្ថែមទៀត។
- រៀបចំឲ្យមានកន្លែងដាក់តាំងឧបករណ៍ធ្វើស្រែចំការ ដើម្បីឲ្យទេសចរបានយល់ដឹង និងស្គាល់ពីវិធីសាស្ត្រក្នុងដាំដុះដំណាំ។

**ខ. ការស្វែងរកទីផ្សារ និងការផ្សព្វផ្សាយ**

នាពេលបច្ចុប្បន្ននេះទីផ្សារទេសចរណ៍ គឺកំពុងតែមានការរីកចម្រើនជាលំដាប់។ ការស្វែងរកទីផ្សារ និងការផ្សព្វផ្សាយ គឺជាសកម្មភាពអនុវត្តន៍ដើម្បីឈានទៅដល់ភាពជោគជ័យ និងសម្រេចគោលបំណងដែលបានកំណត់។ ការផ្សព្វផ្សាយមានច្រើនប្រភេទ ច្រើនរបៀបទៅតាមសភាពការណ៍ ដើម្បីបញ្ច្រាបចូលទីផ្សារបានយើងគួរមានការផ្សព្វផ្សាយតាមរយៈការឃោសនាផ្សេងៗរួមមាន ទូរទស្សន៍ កាសែត ទស្សនាវដ្ដី បណ្ដាយសង្គម អ៊ីនធឺណែត ការតាំងពិព័រណ ការចូលរួមព្រឹត្តិការណ៍នានា។ល។

ការផ្សព្វផ្សាយតាមប្រព័ន្ធបច្ចេកវិទ្យាសម័យទំនើប មានភាពពេញនិយម (ការផ្សព្វផ្សាយតាមគេហទំព័រ) វាជម្រើសដ៏ប្រសើរ ព្រោះមធ្យោបាយនេះផ្ដល់នូវប្រសិទ្ធភាពខ្ពស់រហ័សហើយចូលជ្រៅដល់គ្រប់សកម្មភាពទីផ្សារ និងការចំណាយទាបបើធៀបនឹងការផ្សព្វផ្សាយដ៏ទៃទៀត។ ករណី

នេះត្រូវធ្វើយ៉ាងណាឲ្យតំបន់នេះត្រូវតែមានភាពទាក់ទាញខ្លាំង និងមានភាពល្អប្រសើរនៃការធ្វើបដិសណ្ឋារកិច្ចល្អរបស់ប្រជាពលរដ្ឋទៅកាន់ភ្ញៀវ។

### ៣.៨ ការជំរុញ និងលើកទឹកចិត្តឲ្យមានការវិនិយោគនៅក្នុងតំបន់

ជាការពិតណាស់ការជំរុញឲ្យមានការវិនិយោគ គឺសំខាន់បំផុតសម្រាប់វិស័យទេសចរណ៍។ ដូច្នេះហើយរាជរដ្ឋាភិបាល រដ្ឋអំណាចដែលនៅតំបន់កោះឧកញ៉ាតី និងសហគ្រាសទេសចរណ៍គួររិះរកវិធានការណាដែលនាំឲ្យមានការវិនិយោគទេសចរណ៍ (អ្នកវិនោយោគក្នុងស្រុក និងក្រៅស្រុក) ដែលនាំមកនូវផលចំណេញដល់តំបន់នេះ ព្រមទាំងមានលើកកម្ពស់ជីវភាពប្រជាជនក្នុងតំបន់។ ដូចនេះដើម្បីជំរុញនិងលើកទឹកចិត្តឲ្យមានអ្នកវិនិយោគត្រូវផ្អែកលើចំណុចមួយចំនួនដូចខាងក្រោម៖

- លើកទឹកចិត្តដល់អ្នកវិនិយោគទុនក្នុងវិស័យទេសចរណ៍ ដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងតំបន់ដូចជាកាត់បន្ថយពន្ធ សម្រួលខាងផ្នែកច្បាប់នៅពេលដែកការវិនិយោគកើនឡើង និងមានការផ្តល់ជាប្រាក់កម្ចីពីគ្រឹះស្ថានហិរញ្ញវត្ថុនានា របស់រដ្ឋាភិបាលដោយយកអត្រាការប្រាក់ទាប ជាពិសេសសម្រាប់ប្រជាជនក្នុងតំបន់នោះតែម្តង។
- រៀបចំឲ្យមានសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់នៅក្នុងតំបន់ ដើម្បីបង្កើនទំនុកចិត្តដល់អ្នកវិនិយោគទាំងជាតិ និងអន្តរជាតិ។
- ធ្វើការអនុម័តលើគម្រោងស្នើរសុំឲ្យបានឆាប់រហ័ស ដើម្បីជំរុញដល់អ្នកវិនិយោគឲ្យអនុម័តគម្រោងឲ្យទាន់ពេលវេលាដែលបានស្នើរ។
- បើមានបញ្ហាខ្វះខាតលើកិច្ចដំណើរការរបសើគម្រង ស្ថាប័យត្រូវជួយណែនាំបន្ថែមដើម្បីឲ្យអ្នកវិនិយោគមានលទ្ធភាពគ្រប់គ្រាន់ក្នុងការអនុវត្តគម្រោង។ ក្នុងករណីអ្នកវិនិយោគមានលទ្ធភាពគ្រប់គ្រាន់អនុវត្តបានល្អក្នុងការវិនិយោគគួរតែមានវិធានការដោះស្រាយឲ្យបានសមរម្យដូចជា ការជួយណែនាំ និងការផាកពិន័យជាដើម។ តែក្នុករណីមិនរាងចាលទើបអាចឈានដល់ការបញ្ឈប់គម្រោងនោះតែម្តង។

### ៣.៩ ការចូលរួមរបស់អ្នកជាប់ពាក់ព័ន្ធ

ដើម្បីឲ្យការអភិវឌ្ឍវិស័យទេសចរណ៍បានល្អប្រសើរ គឺអាស្រ័យលើការចូលរួមពីផ្នែកនានាជាច្រើន ដែលជាប់ពាក់ព័ន្ធនឹងការអភិវឌ្ឍនេះ។ ការចូលរួមជាកត្តាមួយសំខាន់បំផុតដើម្បីធ្វើឲ្យការអភិវឌ្ឍទាំងអស់ទទួលបានប្រសិទ្ធភាពស្ថិតស្ថេរគង់វង្ស និងមានតម្លៃតទៅអនាគត។ អ្នកចូលរួមក្នុងការធ្វើឲ្យមាននិរន្តរភាពចំពោះការអភិវឌ្ឍនេះ អាចចូលរួមដោយផ្ទាល់ ឬដោយប្រយោលពី

បណ្តាលសមាសធាតុពាក់ព័ន្ធជាច្រើនដែលការចូលរួមទាំងនេះមានតួនាទីផ្សេងៗគ្នា និងរបៀបនៃការអនុវត្តផ្សេងៗគ្នាដែរ។

អ្នកចូលរួមក្នុងការជួយឲ្យមាននិរន្តភាពចំពោះវិស័យទេសចរណ៍ត្រូវបានបែងចែកជា៥ក្រុមផ្សេងៗគ្នាដូចតទៅ៖

**ក.ការចូលរួមពីរដ្ឋាភិបាល និងអាជ្ញាធរដែនដី**

ក្រុមនេះ គឺជាក្រុមយ៉ាងសំខាន់ និងមានឥទ្ធិពលបំផុតចំពោះការអភិវឌ្ឍវិស័យទេសចរណ៍។ រដ្ឋាភិបាលមានតួនាទីសំខាន់ក្នុងការកំណត់ននូវគោលនយោបាយតម្រង់ទិសការអភិវឌ្ឍថាតើគួរអភិវឌ្ឍន៍នៅតំបន់ណាខ្លះ គួរអភិវឌ្ឍន៍ដោយរបៀបណា ទីណាគួរអនុវត្តន៍សកម្មភាពទេសចរណ៍អ្វីអ្វីដែលមិនត្រូវបាន អនុញ្ញាតឲ្យបង្កើតមានក្នុងតំបន់អភិរក្សណាមួយ។ល។ ច្បាប់ និងគោលនយោបាយក្នុងការអភិវឌ្ឍ ទេសចរណ៍មានសារៈសំខាន់ណាស់ក្នុងការជួយឲ្យមាននិរន្តរភាពយូរអង្វែង តម្លាភាព និងទទួលបាននូវផលប្រយោជន៍ខ្ពស់។

ចំពោះអាជ្ញាធរដែនដីជាសេនាធិការរបស់រដ្ឋាភិបាល ក៏ដូចជារាជរដ្ឋាភិបាលថ្នាក់លើដែរ គឺមានតួនាទីសំខាន់ក្នុងការជួយសម្រួលរាល់គម្រោងវិនិយោគដែលមានក្នុងដែនដីរបស់ខ្លួនឲ្យដំណើរការទៅបានល្អដោយផ្តល់ជា គោលការណ៍ណែនាំអំពីកន្លែងដែលគួរសាងសង់កន្លែង ដែលគួរបង្កើតសកម្មភាពទេសចរណ៍ កន្លែងណាដែលគួរអភិរក្សទុកបានល្អនោះ។ អាជ្ញាធរមូលដ្ឋានត្រូវចេះធ្វើការអប់រំដល់ប្រជាពលរដ្ឋឲ្យចូលរួមថែរក្សាការពារ និងស្រូបយកប្រយោជន៍ផងដែរ។

**ខ. ការចូលរួមពីផ្នែកឯកជន**

ឯកជនជាផ្នែកមួយនៃការអភិវឌ្ឍ គឺជាម្ចាស់គម្រោងវិនិយោគ ឬជាអ្នករកស៊ីក្នុងអាជីវកម្មទេសចរណ៍នៅតំបន់នោះ។ ដូចនេះផ្នែកឯកជនមានតួនាទីសំខាន់ក្នុងការអភិវឌ្ឍទេសចរណ៍ប្រកដដោយនិរន្តរភាពយូរអង្វែង។ ពោល គឺរាល់គម្រោងវិនិយោគឯកជនទាំងអស់ចាំបាច់ត្រូវបានគិតគូរបញ្ហានិរន្តរភាពធ្វើយ៉ាងណាអនុវត្តន៍គម្រោងកុំឲ្យបង្កនូវផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច វប្បធម៌ សង្គម និងបរិស្ថានក្នុងតំបន់។ ផ្នែកនេះក៏ត្រូវគោរពឲ្យបាននូវគោលនយោបាយច្បាប់ និងការណែនាំពីរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន។

**គ. ការចូលរួមពីអង្គការ សមាគមន៍ក្នុង និងក្រៅរដ្ឋាភិបាល**

អង្គរការសមាគមន៍ក្នុងនិងក្រៅរដ្ឋាភិបាលជាច្រើន ដែលគេបង្កើតឡើងដើម្បីធ្វើការគាំទ្រ និងអង្កេតពិនិត្យមើលទៅលើបរិស្ថានធម្មជាតិ វប្បធម៌ និងទៅលើសេដ្ឋកិច្ចនៅទូទាំងពិភពលោក។ អង្គការ សមាគមន៍នានាមានតួនាទីសំខាន់ក្នុងការជួយផ្តល់ជាគោលការណ៍ណែនាំអំពីបញ្ហានិរន្តរភាព

ធ្វើយ៉ាងណាមិនឲ្យមានផលប៉ះពាល់ជាអវិជ្ជមានកើតមានឡើងនៅក្នុងតំបន់ណាមួយឡើយ។ គ្រប់បណ្តាក្រុមអង្គការ សមាគមន៍ជាច្រើន គឺជាសមាសធាតុមួយក្នុងកិច្ចពិភាក្សា ផ្តល់យោបល់ចំពោះការអភិវឌ្ឍថាតើគួរអភិវឌ្ឍន៍ ឬមិនគួរ ហើយក្រុមនេះក៏ដើរតួរយ៉ាងសំខាន់មួយផងដែរ ដែលរងចាំអង្កេតមើលសកម្មភាពរបស់ម្ចាស់គម្រោងដែលបានអនុវត្ត និងធ្វើការកែលម្អនូវអ្វីដែលមិនសមហេតុផលធ្វើឲ្យមានផលប៉ះពាល់បរិស្ថានក្នុងតំបន់ ទៅលើសង្គមវប្បធម៌ក៏ដូចជាទៅលើសេដ្ឋកិច្ច។

**ឃ. ការចូលរួមពីប្រជាជនក្នុងតំបន់**

ប្រជាជនមូលដ្ឋានជាផ្នែកមួយដែលមានឥទ្ធិពលចំពោះតំបន់ទេសចរណ៍។ ប្រជាពលរដ្ឋនៅក្នុងតំបន់ទេសចរណ៍ គឺជាមនុស្សសំខាន់ដែលមិនអាចខ្វះបានក្នុងការជួយអភិរក្សបរិស្ថាន ការថែ-រក្សាវប្បធម៌ក្នុងតំបន់របស់ខ្លួន។ នៅពេលណាដែលប្រជាជនទាងអស់បានយល់ដឹងពីតម្លៃ និងអត្ថប្រយោជន៍របស់ទេសចរណ៍ និងធនធានទាំងនេះនៅក្នុងជីវិតរបស់ពួកគាត់។ មិនតែប៉ុណ្ណោះប្រសិនបើប្រជាពលរដ្ឋក្នុងតំបន់ពុំទទួលយលព្រមចំពោះគម្រោងអភិវឌ្ឍន៍ក្នុងតំបន់របស់គាត់ទេគម្រោងនោះពុំអាចដំណើរការទៅបានទេហើយសកម្មទេសចរណ៍ក៏ពុំអាចរីកចម្រើនបានដែរ។

**ង. ការចូលរួមពីទេសចរ** (**ក្នុងស្រុក និងបរទេស**)

ទេសចរ គឺជាអ្នកដែលប្រើប្រាស់ផលិតផលទេសចរណ៍ ទេសចរ គឺជាអ្នកចូលមកកម្សាន្តក្នុងតំបន់ទេសចរណ៍។ បើសិនជាគ្មានអ្នកទេសចរ សកម្មភាពនៃការអភិវឌ្ឍទេសចរណ៍កុំអាចកើតមានដែរ ហើយអ្វីទាំងអស់អស់ក៏មិនអាចមានសកម្មភាពនៅក្នុងតំបន់ទេសចរណ៍បានទេ។ ដូចនេះនៅពេលដែលភ្ញៀវទេសចរបានទៅទស្សនាកម្សាន្តនៅទីណាមួយ ពួកគាត់មានតួនាទីសំខាន់ណាស់សម្រាប់ធ្វើឲ្យតំបន់នោះក្លាយជាតំបន់កសិទេសចរណ៍។ ការចូលរួមពីទេសចរ គឺជាផ្នែកមួយក្នុងការជួយឲ្យតំបន់ទេសចរណ៍មានការអភិវឌ្ឍ បរិស្ថានល្អ និងមានការពេញចិត្តពីទេសចរគ្រប់រូបការពេញចិត្តពីម្ចាស់ស្រុក និងអ្នកប្រតិបត្តិគម្រោងអភិវឌ្ឍន៍នេះ ថែមទាំងធានាបាននូវនិរន្តរភាពល្អទាំងប្រជាប្រិយភាព និងទីផ្សារ ហើយអាចទទួលបាននិរន្តរភាពលើគ្រប់វិស័យទាំងអស់ដែលពាក់ព័ន្ធនឹងគម្រោងការអភិវឌ្ឍមួយនេះ។

## ៣.១០ យុទ្ធសាស្ត្រក្នុងការច្នៃប្រឌិតដើម្បីឲ្យតំបន់កោះឧកញ៉ាតីក្លាយទៅជាកសិ-ទេសចរណ៍




✓ **ការច្នៃប្រឌិតគោលដៅទេសចរណ៍(Creative Destination)** ជាមូលហេតុចម្បងដែលបណ្តាលឲ្យទេសចរមានការចង់ធ្វើដំណើរទេសចរណ៍ គឺតម្រូវឲ្យមានការអភិវឌ្ឍនូវចំនុចលេចធ្លោរ ដើម្បីជាជំហរមួយការទាក់ទាញភ្ញៀវទេសចរ ថែមទាំងការអភិរក្សធម្មជាតិឲ្យមានភាពគង់វង្សជាមួយគ្នាផងដែរ (Richards, 2011)។ ក្នុងតំបន់កោះឧកញ៉ាតី មានសក្តានុពលទាំងកសិទេសចរណ៍ និងទេសចរណ៍ធម្មជាតិ ព្រមទាំងរមណីយដ្ឋានកែច្នៃផ្សេងៗទៀត ក្នុងការច្នៃប្រឌិតគោលដៅទេសចរណ៍មួយនេះ អាជ្ញាធរក៏ដូចជាក្រសួងទេសចរណ៍ត្រូវប្រើទ្រឹស្តីនៃការគិតច្នៃប្រឌិតយកមកប្រើធ្វើឱ្យប្រសើរឡើង ដើម្បីបន្ថែមតម្លៃដល់តំបន់ ដែលយើងអភិវឌ្ឍបរិយាកាសរបស់សង្គមនៃការរៀនច្នៃប្រឌិត ផ្តើមពីធនធានដែលមាននៅក្នុងតំបន់នោះផ្ទាល់ ដោយតាមរូបភាពផ្សេងៗ ជាពិសេសការរៀបចំឲ្យដំណើរទេសចរណ៍ អាចឲ្យភ្ញៀវមានឱកាសពិនិត្យចូលរួមអនុវត្ត ទទួលបានគំនិតនៃការច្នៃប្រឌិត និងចំណេះដឹងខាងផ្នែកកសិកម្មរបស់ប្រជាជនក្នុងតំបន់នោះផងដែរ។

✓ **ការច្នៃប្រឌិតរបស់សហគ្រិន (Creative Entrepreneur)** មានសារៈសំខាន់សំរាប់ការគ្រប់គ្រង់ របបសេដ្ឋកិច្ចនៃការកែច្នៃ ព្រោះសហគ្រិនអាចចាត់បានថាជាអ្នកមានគំនិតក្នុងការច្នៃប្រឌិតដែលអាចលើកកម្ពស់ការអភិវឌ្ឍនៃដំណើរការច្នៃប្រឌិតមួយ ដែលបានបណ្តាលឱ្យមានការបង្កើតថ្មីឬផលិតផលថ្មីនៅក្នុងឧស្សាហកម្មទេសចរណ៍។ ក្នុងការអភិវឌ្ឍតំបន់កោះឧកញ៉ាតីឲ្យក្លាយជាតំបន់កសិទេសចរណ៍មួយបាន ក្រសួងទេសចរណ៍ រាជរដ្ឋាភិបាល ឬអាជ្ញាធរក្នុងតំបន់អាចសហ

ការជាមួយក្រុមហ៊ុនទេសចរណ៍ ដែលក្រុមហ៊ុនទេសចរណ៍ភាគច្រើនជាអ្នកបង្កើតជាកញ្ចប់ទេសចរណ៍ សំរបសំរួលគំនិតច្នៃប្រឌិតថ្មីរួមគ្នាបង្កើតជាការអភិវឌ្ឍនូវផលិតផលទេសចរណ៍ថ្មីមួយយ៉ាងមានសក្តានុពល។

✓ **ការច្នៃប្រឌិតក្នុងសហគមន៍ (Creative Locals)** សំរាប់ការប្រែក្លាយតំបន់កោះឧកញ៉ាតីឲ្យក្លាយជាតំបន់កសិទេសចរណ៍ ប្រជាជនក្នុងសហគមន៍ដើរតួនាទីមួយយ៉ាងសំខាន់ ក្នុងការអភិវឌ្ឍទេសចរណ៍មួយបាន ប្រជាជនក្នុងសហគមន៍អាចប្រើអត្តសញ្ញាណវប្បធម៌ បច្ចេកទេសរបៀបធ្វើកសិកម្មរបស់សហគមន៍មូលដ្ឋាន ដោយមានការច្នៃប្រឌិតជាលក្ខណៈរបស់ខ្មែរដល់ទេសចរដែលចូលមកទស្សនាចំការរបស់ពួកគាត់។ ម្យ៉ាងវិញទៀតប្រជាជនក្នុងសហគមន៍ ត្រូវមានការចេះចុះសម្រុង សហការគ្នាក្នុងការចែករំលែកចំណេះដឹង ជំនាញថ្មីៗ និងការគ្រប់គ្រងរបស់អាជ្ញាធរធ្វើឱ្យប្រសើរឬប្រែប្រួលទៅបរិបទនៃប្រភេទទេសចរណ៍ស្របទៅតាមតំបន់របស់គាត់។ ក្នុងគោលបំណងការលើកកម្ពស់ការយល់ដឹងអំពីអត្ថប្រយោជន៍របស់កសិទេសចរណ៍ដល់ប្រជាជនក្នុងសហគមន៍ដើម្បីបង្កើតឱកាសសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍ក្នុងតំបន់ខ្លួន។

✓ **ការច្នៃប្រឌិតផលិតផល & សកម្មភាពទេសចរណ៍ (Creative Activities & Products)** គឺជាអាជីវកម្មឬ ជាផលិតផលមួយដែលសាងបទពិសោធន៍ ឬជាការសេវាកម្មដែលចាប់មិនបាន តែអាចស្ថិតក្នុងការពេញចិត្តរបស់ទេសចរដែលវាជាបទពិសោធន៍មួយយ៉ាងល្អ។ នៅពេលដែលក្នុងតំបន់មានការគ្រប់គ្រងល្អ បូករួមជាមួយធនធានមនុស្សប្រកបដោយគំនិតច្នៃប្រឌិតក្នុងការអភិវឌ្ឍធនធានកសិកម្មឬសកម្មភាព ផលិតផលក្នុងការផ្តល់ជូនដល់ភ្ញៀវទេសចរ នូវបទពិសោធន៍និងជំនាញក្នុងការចូលរួមផ្ទាល់ក្នុងការធ្វើកសិកម្មផ្សេងៗ។ បច្ចុប្បន្ននេះ រមណីយដ្ឋានទេសចរណ៍ក្នុងប្រទេសជាច្រើន ព្យាយាមលើកចំនុចលេចធ្លោទាក់ទាញទេសចរដោយបង្កើតជារមណីយដ្ឋានធម្មជាតិ និង ប្រភេទកសិដ្ឋានស្ទើរគ្រប់ប្រភេទ ភ្ជាប់ជាមួយការអភិវឌ្ឍទៅជាមួយការទេសចរណ៍ អ្នកទេសចរណ៍អាចទិញផលិតផលកសិកម្មដោយគ្មានជាតិគីមី សិក្សាបច្ចេកទេស ឬចូលរួមផ្ទាល់ក្នុងការដាំជាដើម ហើយអ្នកទេសចរអាចនិងមកកសិដ្ឋានម្តងទៀតដើម្បីមើលផលិតផលដែលពួកគាត់បានដាំ។ បើមានការចូលពិភាក្សារួមគ្នាជាមួយសហគមន៍ សហគ្រិន រដ្ឋាភិបាលបង្កើតជាផលិតផលកសិកម្មថ្មីៗ ប្រកបដោយការច្នៃប្រឌិត យើងអាចនិយាយបានតំបន់កោះឧកញ៉ាតីប្រាកដជាមានការអភិវឌ្ឍក្លាយជាតំបន់រមណីយដ្ឋានកសិទេសចរណ៍ និងតំបន់ធម្មជាតិមួយដ៏សំបូរបែប។

✓ **ការច្នៃប្រឌិតនៃការទំនាក់ទំនង (Creative Communication)** ការទំនាក់ទំនង គឺជាចំនុចមួយយ៉ាងសំខាន់ ព្រោះក្នុងការអភិវឌ្ឍតំបន់មួយឲ្យក្លាយជាតំបន់ទេសចរណ៍បាន ចំបាច់ត្រូវមានការ

យល់ដឹងពីទេសចរណ៍ឲ្យបានច្បាស់លាស់ក្នុងការអភិវឌ្ឍ ព្រមទាំងការស្នើឲ្យមានមតិរួមគ្នា ហើយមានការយល់ព្រមទាំងផ្នែកប្រជាជន រដ្ឋ សហគ្រិន ពិតណាស់ថាដើម្បីឲ្យការអភិវឌ្ឍទេសចរណ៍ចាំបាច់ត្រូវសង្កត់ធ្ងន់ទៅលើការបង្កើតគោលនយោបាយ ការធ្វើផែនការ ការគ្រប់គ្រង និងការចូលរួមចំនែកពីផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ពិសេសគឺសហគមន៍។ ចំពោះក្នុងទំនាក់ទំនងជាមួយភ្ញៀវទេសចរ យើងអាចនិយាយបានមួយបែបទៀតថាជាការផ្សព្វផ្សាយ គ្រប់ទំរង់នៃទំនាក់ទំនងសង្គមទាំងអស់បានបើកយ៉ាងទូលំទូលាយ និងជាប្រព័ន្ធផ្សព្វផ្សាយមួយដ៏មានឥទ្ធិពល។ សំរាប់ចំនុចនេះ អាជ្ញាធរក្នុងតំបន់ ក៏ដូចជាក្រសួងទេសចរណ៍ បន្ទាប់ពីមានការអភិវឌ្ឍតំបន់កោះឧកញ៉ាតីរួចក្រសួងអាចចាត់ជាយន្តការផ្សព្វផ្សាយពីតំបន់នេះ ក្នុងបណ្តាញសង្គមរបស់ក្រសួងផ្ទាល់ ក៏ដូចជាតាមស្ថានីយ៍ទូរទស្សន៍ ដើម្បីជាពត៌មានដល់ភ្ញៀវទេសចរបានទទួលដឹងពីតំបន់រមណីយដ្ឋានថ្មីមួយនេះ។

# សេចក្តីសន្និដ្ឋាន

# និង

# ការផ្តល់អនុសាសន៍

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១. សេចក្តីសន្និដ្ឋាន

តាមការសិក្សាស្រាវជ្រាវលើការជំរុញឲ្យមានការអភិវឌ្ឍតំបន់កោះឧកញ៉ាតីឲ្យក្លាយជាតំបន់កសិទេសចរណ៍ ព្រមទាំងវិភាគ និងបកស្រាយនៅរាល់ជំពូកខាងលើយើងអាចសន្និដ្ឋានបានថា តំបន់កោះឧកញ៉ាតី គឺជាតំបន់មួយដែលមានសក្តានុពលសម្រាប់កសិទេសចរណ៍ ព្រមទាំងទេសភាព និងបរិយាកាសមានលក្ខណៈអំណោយផល ដែលអាចទាក់ទាញទេសចរ និងការអភិវឌ្ឍឲ្យមានភាពល្អប្រសើរ។ ស្របគ្នានេះដែរការអភិវឌ្ឍតំបន់នេះឲ្យក្លាយជាតំបន់កសិទេសចរណ៍ វាពិតជាអាចរួមចំណែកយ៉ាងខ្លាំងក្នុងការជំរុញនូវរាល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ និងការកែច្នៃផ្នែកកសិកម្មឲ្យមានទំនាក់ទំនងជាមួយទេសចរណ៍ ដែលអាចទទួលបានផលប្រយោជន៍ជាច្រើនពីវិស័យទេសចរណ៍ និងវិស័យកសិកម្ម។ លើសពីនេះទៅទៀត ការអភិវឌ្ឍតំបន់នេះ ឲ្យក្លាយជាតំបន់កសិទេសចរណ៍ បានធ្វើឲ្យប្រជាពលរដ្ឋដែលជាម្ចាស់ស្រុករស់នៅក្នុងមូលដ្ឋាន និងសាធារណៈជនទូទៅ ទេសចរ បានយល់ដឹងពីសារៈប្រយោជន៍នៃ កសិទេសចរណ៍ និងការចូលរួមអភិរក្សផ្សេងៗរបស់ពួកគាត់។ ម្យ៉ាងវិញទៀតធ្វើឲ្យពួកគាត់រឹតតែស្រលាញ់ ថែរក្សា និងអភិវឌ្ឍន៍នូវអ្វីដែលពួកគាត់មានស្រាប់ដូចជា ចម្ការ សត្វពាហនៈ ផលដំណាំរបស់ពួកគាត់ ឧបករណ៍កសិកម្មដែលពួកគាត់មានសម្រាប់ដាក់តាំងបង្ហាញដល់ទេសចរបានទស្សនា។

ជាងនេះទៅទៀត ការជំរុញឲ្យមានការអភិវឌ្ឍកសិទេសចរណ៍នៅតំបន់កោះឧកញ៉ាតី ពិតជាបានផ្តល់ផលប្រយោជន៍ជាច្រើនចំពោះ ប្រជាជនក្នុងតំបន់នោះ ក៏ដូចជាបានផ្តល់ឱកាសការងារជាច្រើនដល់ពួកគាត់ផងដែរ។ លើសពីនេះបើសិនជាមានការអភិវឌ្ឍ វាអាចជួយកាត់បន្ថយភាពក្រីក្រ ការធ្វើចំណាកស្រុក លើកកម្ពស់វិស័យទេសចរណ៍ និងកសិកម្មផងដែរ។ ម្យ៉ាងវិញទៀតបានធ្វើឲ្យគេឃើញពីតម្លៃនៃវប្បធម៌ ប្រពៃណី ការរស់នៅរបស់ប្រជាជនខ្មែរ ហើយបានធ្វើឲ្យទេសចរមានទំនាក់ទំនងល្អជាមួយប្រជាពលរដ្ឋក្នុងមូលដ្ឋាន ធ្វើឲ្យពួកគាត់ស្គាល់ពីតម្លៃនៃជីវិត ធ្វើឲ្យទេសចរស្គាល់ពីអត្ថប្រយោជន៍នៃការដាំដុះបន្លែផ្លែឈើធម្មជាតិទទួលទានដោយខ្លួនឯង ធ្វើឲ្យគាត់ចេះស្រលាញ់សុខភាព បណ្តុះគំនិតស្រលាញ់ធម្មជាតិដល់ពួកគាត់ និងបរិភោគអាហារដែលគ្មានជាតិគីមីមិនបង្ករផលប៉ះពាល់ដល់សុខភាពរបស់គាត់។ ទោះបីជាទីនេះមិនទាន់បានក្លាយទៅជាតំបន់កសិទេសចរណ៍ក៏ដោយ ក៏ទីនេះអាចមានឱកាសអភិវឌ្ឍន៍ក្លាយជាតំបន់កសិទេសចរណ៍បានដែរ ដោយផ្អែកលើសក្តានុពលក្នុងតំបន់ យើងសង្ឃឹមយ៉ាងមុតមាំថានាពេលអនាគតខាងមុខទីនេះនឹងមានការអភិវឌ្ឍ ព្រមទាំងមានការចាប់អារម្មណ៍ពីសំណាក់ទេសចរគ្រប់មជ្ឈដ្ឋានទាំងជាតិ និងអន្តរជាតិ ហើយដើម្បីសម្រេចបាននូវគោលដៅទាំងនេះ លុះត្រាតែមានការចូលរួមពីគ្រប់ផ្នែកទាំងអស់

ដែលជាប់ពាក់ព័ន្ធ ដូចជាក្រសួងទេសចរណ៍ ក្រសួងកសិកម្ម ក្រសួងសុខាភិបាល និងផ្នែកពាក់ព័ន្ធផ្សេងៗជាច្រើនទៀត ដែលអាចជាកត្តាជំរុញតំបន់កោះឧកញ៉ាតីអាចក្លាយជាតំបន់កសិទេសចរណ៍ដ៍ទាក់ទាញជំបូងគេនៅក្បែរទីក្រុងភ្នំពេញនាពេលអនាគត ពេលនោះហើយនឹងធ្វើឲ្យវិស័យកសិកម្ម និងទេសចរណ៍ក្នុងស្រុកយើងមានភាពរីកចម្រើនជឿនលឿនទៅមុខដូចប្រទេសនៅជិតខាងយើង ហើយអាចប្រកួតប្រជែង និងដើរទាន់ជាមួយប្រទេសសមាហរកម្មអាស៊ានដទៃទៀត។

## ២. ការផ្ដល់អនុសាសន៍

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើការជំរុញការអភិវឌ្ឍកសិទេសចរណ៍នៅតំបន់កោះឧកញ៉ាតី ថាមានចំណុចខ្វះខាតមួយចំនួន និងចំណុចល្អមួយចំនួន។ ដើម្បីចូលរួមចំណែកដល់ការអភិវឌ្ឍ និងទាក់ទាញទេសចរឲ្យមកកំសាន្តនៅតំបន់នេះបាន យើងខ្ញុំសូមផ្ដល់ជាមតិយោបល់មួយចំនួន ដើម្បីបំពេញបន្ថែមនូវចំណុចខ្វះខាត ដែលក្នុងនោះត្រូវមានការចូលរួមពីសំណាក់អាជ្ញាធរ ប្រជាពលរដ្ឋក្នុងមូលដ្ឋាន គប្បីគួរតែបំពេញបន្ថែមនូវចំណុចខ្វះខាតមួយចំនួនដូចខាងក្រោម៖

- រៀបចំបណ្ដុះបណ្ដាលឲ្យប្រជាជននៅក្នុងតំបន់នោះ ឲ្យយល់ដឹងពីអត្ថប្រយោជន៍នៃវិស័យទេសចរណ៍ និងវិស័យកសិកម្ម
- ត្រូវបណ្ដុះបណ្ដាលប្រជាពលរដ្ឋឲ្យដឹងពីរបៀបទទួលរាក់ទាក់ភ្ញៀវ ការផ្ដល់សេវាទៅកាន់ភ្ញៀវ
- បណ្ដុះបណ្ដាលប្រជាជនក្នុងតំបន់នោះឲ្យចេះកែច្នៃ និងបង្កើតនូវផលិតផលថ្មីៗ ដើម្បីទាក់ទាញទេសចរ
- គួរបង្កើតបង្គន់អនាម័យសាធារណៈសម្រាប់ឲ្យទេសចរប្រើប្រាស់ឲ្យបានគ្រប់គ្រាន់
- ត្រូវរៀបចំកន្លែងទុកដាក់សំរាមឲ្យបានត្រឹមត្រូវ ជៀសវាងការចោលសំរាមផ្ដេសផ្ដាសរបស់ប្រជាពលរដ្ឋក្នុងតំបន់ និងទេសចរ
- ជម្រុញឲ្យប្រជាពលរដ្ឋដាំដំណាំ និងផ្លែឈើឲ្យបានច្រើនប្រភេទ
- អាជ្ញាធរគួររៀបចំបង្កើតឲ្យមានជាប្រព័ន្ធធារាសាស្ត្រដើម្បីឲ្យប្រជាពលរដ្ឋងាយស្រួលក្នុងការស្រោចស្រប់ដំណាំ។

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## កម្រងសំណួរស្រាវជ្រាវ

## ស្តីពី

## "ជំរុញការអភិវឌ្ឍកសិទេសចរណ៍ នៅកោះឧកញ៉ាតី"

① សម្រាប់ប្រជាពលរដ្ឋ

ជំរាបសួរ! យើងខ្ញុំជានិស្សិតឆ្នាំទី៤ ជំនាន់ទី៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សូមគោរពសុំការអនុញ្ញាត ពី លោកលោកស្រី អ្នកនាង កញ្ញា ព្រមទាំងទេសចរទាំងអស់ដែលស្ថិតនៅក្នុងភូមិកោះឧញ៉ាតីនេះ មេត្តាជួយបំពេញ និងឆ្លើយនូវរាល់សំណួរដូចខាងក្រោមនេះ ដោយក្តីអនុគ្រោះផង។

សូមគូសសញ្ញា √ ក្នុងប្រអប់ ☐ និងបំពេញចន្លោះ(...........) ដែលជាចម្លើយរបស់លោកអ្នក។

**បញ្ជាក់ ៖** រាល់ពត៌មានស្រាវជ្រាវ ទាំងអស់របស់លោកអ្នកនេះ គឺសម្រាប់គោលដៅសិក្សាតែប៉ុណ្ណោះ។

អាយុ............ ភេទ............... ស្ថានភាពគ្រួសារ................................

ដាំដំណាំរយៈពេលវែង ឬខ្លី .........................................................................

១. តើចំណូលជាមធ្យមបានប៉ុន្មានក្នុងមួយថ្ងៃក្នុងការប្រកបរបរប្រចាំថ្ងៃរបស់លោកអ្នក?

☐ក្រោម៥ ដុល្លា ☐ ៥ដល់១០ ដុល្លា ☐១០ដុល្លាឡើងទៅ

២. តើអ្នកដាំដុះជាលក្ខណៈគ្រួសារ ឬអាជីវកម្ម?

☐គ្រួសារ ☐អាជីវកម្ម

* បើលក្ខណៈអាជីវកម្ម តើលោកអ្នកបានកម្លាំងពលកម្មមកពីណា?

.............................................................................................................

៣. តើលោកអ្នកប្រើមធ្យោបាយអ្វីក្នុងការដាំដុះ?

☐ម៉ាស៊ីន ☐ គោឬក្របី

៤. តើការដាំដុះរបស់លោកអ្នកមានលក្ខណៈបែបណា?

☐ធម្មជាតិ ☐ប្រើជីគីមី ☐ចម្រុះ

៥.តើមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ហើយឬនៅ?

☐គ្រប់គ្រាន់ ☐មិនគ្រប់គ្រាន់

៦. ពេលទទួលផល តើលោកអ្នកយកទៅលក់នៅឯណា?

☐ក្នុងភូមិ ☐ក្នុងផ្សារ ☐តាមឈ្មួញកណ្ដាល ☐ផ្សេងៗ

៧. តើលោកអ្នកមានការពេញចិត្ត និងចូលរួមទេ បើនៅតំបន់នេះបានអភិវឌ្ឍន៍ទៅជារមណីយដ្ឋានបែបកសិទេសចរណ៍?

☐ពេញចិត្ត ☐ធម្មតា ☐មិនពេញចិត្ត

សូមបញ្ជាក់៖.........................................................................................................

៨. តើលោកអ្នកគិតយ៉ាងណាចំពោះសន្តិសុខ និងសុវត្ថិភាពនៅក្នុងតំបន់នេះ?

☐ល្អណាស់ ☐ល្អ ☐បង្គួរ ☐មធ្យម ☐ខ្សោយ

សូមបញ្ជាក់៖.........................................................................................................

៩. តើធ្លាប់មានមន្ត្រីនៅមន្ទីរណាមួយចុះមកធ្វើការបណ្ដុះបណ្ដាលពីជំនាញដែលពាក់ព័ន្ធនឹងការដាំដុះនៅក្នុងតំបន់នេះពីមុនមកដែលឬទេ?

☐ធ្លាប់ ☐មិនធ្លាប់

សូមបញ្ជាក់៖.........................................................................................................

១០. តើរាជរដ្ឋាភិបាលធ្លាប់បានជម្រុញឬលើកទឹកចិត្ត ដល់ការដាំដុះនៅក្នុងតំបន់នេះដែរឬទេ?

☐ធ្លាប់ ☐មិនធ្លាប់

សូមបញ្ជាក់៖.........................................................................................................

សូមអរគុណ!!!

## កម្រងសំណួរស្រាវជ្រាវ

## ស្តីពី

## "ជំរុញការអភិវឌ្ឍកសិទេសចរណ៍ នៅកោះឧកញ៉ាតី"

③ សម្រាប់អាជ្ញាធរ

ជំរាបសួរ! យើងខ្ញុំជានិស្សិតឆ្នាំទី៤ ជំនាន់ទី៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សូមគោរពសុំការអនុញ្ញាតពី លោកលោកស្រី អ្នកនាង កញ្ញា ព្រមទាំងទេសចរទាំងអស់ដែលស្ថិតនៅក្នុងភូមិកោះឧញ៉ាតីនេះ មេត្តាជួយបំពេញ និងឆ្លើយនូវរាល់សំណួរដូចខាងក្រោមនេះ ដោយក្តីអនុគ្រោះផង។

ការចូលរួមផ្តល់មតិរបស់លោកអ្នក គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍផលិតផលទេសចរណ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាជំរុញឲ្យមានការប្រែក្លាយ តំបន់កោះឧញ៉ាតីឲ្យក្លាយជាតំបន់ទេសចរណ៍ដែលមានភាពទាក់ទាញមួយ នាពេលអនាគត។ ជាងនេះទៅទៀត វាជាផ្នែកមួយដែលជំរុញឲ្យ ការស្រាវជ្រាវរបស់ពួកយើង ទទួលបានលទ្ធផលក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកនេះផងដែរ។

សូមគូសសញ្ញា √ ក្នុងប្រអប់ ☐ និងបំពេញចន្លោះ(...........) ដែលជាចម្លើយរបស់លោកអ្នក។

**បញ្ជាក់ ៖** រាល់ពតិមានស្រាវជ្រាវ ទាំងអស់របស់លោកអ្នកនេះ គឺសម្រាប់គោលដៅសិក្សាតែប៉ុណ្ណោះ។

អាយុ............ ភេទ៖...........

មុខងារ និងតួនាទី៖..........................................................................................

១.តើលោកអ្នក មានយន្តការក្នុងការអភិវឌ្ឍនៅតំបន់នេះដែរឬទេ?

☐ មាន ☐ មិនមាន

សូមបញ្ជាក់៖..................................................................................................

...................................................................................................................

២.តើលោកអ្នក ធ្លាប់មានការជំរុញនិងលើកទឹកចិត្តដល់ប្រជាពលរដ្ឋក្នុងតំបន់នេះ ឲ្យខិតខំបង្កើនកសិផល និងដាំដុះបន្ថែមដែរឬទេ?

☐ធ្លាប់ ☐មិនធ្លាប់

សូមបញ្ជាក់៖..........................................................................................................

៣. បើភ្ជាប់ពីភ្នំពេញមកទីនេះ តើអាចធ្វើដំណើរដោយមធ្យោបាយណាអ្វីខ្លះ?

..........................................................................................................................

..........................................................................................................................

៤.តើនៅក្នុងតំបន់នេះមានប្រព័ន្ធអគ្គីសនី និងប្រព័ន្ធទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់ឬនៅ?

☐មាន ☐មិនមាន ☐ផ្សេងៗ

សូមបញ្ជាក់៖ .........................................................................................................

៥. តើនៅក្នុងតំបន់នេះមានបញ្ហាប្រឈមដែរឬទេ? អ្វីខ្លះ?

☐ មាន ☐ មិនមាន

សូមបញ្ជាក់៖ .........................................................................................................

៦. តើនៅទីនេះមានសម្បទាទេសចរណ៍ ដូចជាផ្ទះស្នាក់សម្រាប់ទេសចរជួលស្នាក់នៅ ភោជនីយដ្ឋាន អាហារដ្ឋានផ្សេងៗ សម្រាប់បម្រើទេសចរដែរឬទេ?

☐មាន ☐មិនមាន

សូមបញ្ជាក់៖ .........................................................................................................

៧. តើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធនៅទីនេះ មានលក្ខណៈល្អប្រសើរ និងគ្រប់គ្រាន់ដែរឬទេ?

☐ ល្អ ☐ធម្មតា ☐អន់

☐គ្រប់គ្រាន់ ☐មិនគ្រប់គ្រាន់

សូមបញ្ជាក់៖ .........................................................................................................

៨. តើប្រជាពលរដ្ឋក្នុងតំបន់នេះភាគច្រើនដាំដំណាំអ្វីច្រើនជាងគេ?

..................................................................................................................................

..................................................................................................................................

៩.បើសិនជាតំបន់នេះអភិវឌ្ឍន៍ក្លាយជាតំបន់កសិទេសចរណ៍ តើថ្នាក់ដឹកនាំនៅទីនេះមានការសារទ និងគិតថាវាផ្តល់អត្ថប្រយោជន៍អ្វីខ្លះដល់ភូមិឃុំនេះ?

..................................................................................................................................

..................................................................................................................................

១០.តើក្នុងនាមជាមន្ត្រី អាជ្ញាធរ តើលោកអ្នកមានសំណូមពរអ្វីខ្លះដល់រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងទេសចរណ៍ ក្នុងការអភិវឌ្ឍន៍តំបន់នេះ ឲ្យក្លាយជាតំបន់កសិទេសចរណ៍?

..................................................................................................................................

..................................................................................................................................

..................................................................................................................................

សូមអរគុណ!!!

**កម្រងសំណួរស្រាវជ្រាវ**

**ស្តីពី**

**"ជំរុញការអភិវឌ្ឍកសិទេសចរណ៍ នៅកោះឧកញ៉ាតី"**

② សម្រាប់ទេសចរ និងនិស្សិត

ជំរាបសួរ! យើងខ្ញុំជានិស្សិតឆ្នាំទី៤ ជំនាន់ទី៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាញទេសចរណ៍ និងបដិសណ្ឋារកិច្ច សូមគោរពសុំការអនុញ្ញាត ពី លោកលោកស្រី អ្នកនាង កញ្ញា ព្រមទាំងទេសចរទាំងអស់ដែលស្ថិតនៅក្នុងភូមិកោះឧញ៉ាតីនេះ មេត្តាជួយបំពេញ និងឆ្លើយនូវរាល់សំណួរដូចខាងក្រោមនេះ ដោយក្តីអនុគ្រោះផង។

សូមគូសសញ្ញា √ ក្នុងប្រអប់ ☐ និងបំពេញចន្លោះ(...........) ដែលជាចម្លើយរបស់លោកអ្នក។

**បញ្ជាក់ ៖** រាល់ពតិមានស្រាវជ្រាវ ទាំងអស់របស់លោកអ្នកនេះ គឺសម្រាប់គោលដៅសិក្សាតែប៉ុណ្ណោះ។

អាយុ............ ភេទ................ សញ្ជាតិ.................

មុខរបរ...................................................................

១. តើលោកអ្នកធ្លាប់ស្គាល់ ឬមកកំសាន្តនៅតំបន់កោះឧញ៉ាតីដែរឬទេ?

☐ ធ្លាប់ ☐ មិនធ្លាប់

២. តើលោកអ្នកធ្លាប់ស្គាល់ ឬមកកំសាន្តតំបន់កោះឧកញ៉ាតីដែរឬទេ?

☐ ធ្លាប់ ☐ មិនធ្លាប់

៣. តើអ្នកស្គាល់តំបន់កោះឧញ៉ាតីនេះដោយរបៀបណា?

☐ សាច់ញាតិ ឬគ្រួសារ ☐ បងប្អូន ឬមិត្តភក្តិ ☐ ប្រព័ន្ធអ៊ីនធើណែត ☐ ផ្សេងៗ

៤. តើអ្នកធ្វើដំណើរមកទីនេះតាមមធ្យោបាយអ្វី?

☐ កង់ ☐ ម៉ូតូ ☐ រថយន្ត ☐ ផ្សេងៗ

៥. តើអ្នកយល់ឃើញយ៉ាងណាចំពោះសន្តិសុខ សុវត្ថិភាពនៅក្នុង និងក្បែរតំបន់នេះ ?

☐ ល្អណាស់ ☐ ល្អបង្គួរ ☐ ធម្មតា ☐ មិនល្អ

សូមបញ្ជាក់៖.............................................................................................................

៦. តើបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធនៅទីនេះមានលក្ខណៈបែបណាដែរ?

បរិយាកាស ៖ ☐ ល្អណាស់ ☐ ល្អបង្គួរ ☐ ធម្មតា ☐ មិនល្អ

ភាពទាក់ទាញ ៖ ☐ គួរឲ្យចាប់អារម្មណ៍ ☐ ធម្មតា ☐ មិនគួរឲ្យចាប់អារម្មណ៍

ផ្លូវថ្នល់ ៖ ☐ ល្អណាស់ ☐ ល្អបង្គួរ ☐ ធម្មតា ☐ មិនល្អ

៧. តើអ្នកចូលចិត្តដាំបន្លែ ផ្លែឈើដោយខ្លួនឯងដែរឬទេ?

☐ ចូលចិត្ត ☐ ធម្មតា ☐ មិនចូលចិត្ត

៨. តើអ្នកចង់ទិញ និងបរិភោគបន្លែ ផ្លែឈើស្រស់ៗ ដោយគ្មានសារធាតុគីមីដែរឬទេ?

☐ ចង់ ☐ ធម្មតា ☐ មិនចង់

៩. តើអ្នកធ្លាប់បានលឺ និងដឹងពីទេសចរណ៍បែបកសិទេសចរណ៍ដែរឬទេ?

☐ ធ្លាប់ ☐ មិនធ្លាប់

✓ បើធ្លាប់សូមបញ្ជាក់ ៖ ..........................................................................................

១០. តើអ្នកចូលចិត្តទេសចរណ៍ប្រភេទណាខ្លះ?

ទេសចរណ៍វប្បធម៌ ☐

ទេចរណ៍ធម្មជាតិ ☐

ទេចរណ៍ផ្សងព្រេង ☐

កសិទេចរណ៍ ☐

ផ្សេងៗ(សូមបញ្ជាក់)៖.....................................................................................................

១១. បើសិនជាមានទេសចរណ៍បែបកសិកម្ម តើអ្នកចូលចិត្តធ្វើសកម្មភាពណាជាងគេ?

☐ ដើរទស្សនា ☐ ចូលរួមសកម្មភាព

ផ្សេងៗ (សូមបញ្ជាក់)៖ ...................................................................................................

១២. តើអ្នកមានមតិយោបល់អ្វីក្នុងការកែប្រែ  ក៏ដូចជាជំរុញការអភិវឌ្ឍតំបន់នេះឲ្យកាន់តែប្រសើរឡើងដែរឬទេ?

..........................................................................................................................

..........................................................................................................................

១៣. ចំពោះអ្នកផ្ទាល់ តើអ្នកគិតថាទេសចរណ៍ប្រភេទកសិកម្ម ផ្តល់ផលប្រយោជន៍អ្វីខ្លះដល់សង្គមជាតិ?

..........................................................................................................................

..........................................................................................................................

សូមអរគុណ!!!

# ឧបសម្ព័ន្ធទី២

៩ ទិដ្ឋភាពនៅកំពង់ចម្លងទៅតំបន់កោះដាច់- កោះឧកញ៉ាតី



កន្លែងអង្គុយកំសាន្តនៅក្បែរកំពង់ចម្លង




**រូបទី១** តារាងបង់ប្រាក់កំពង់ចម្លងកោះដាច់- កោះឧកញ៉ាតី





ទូកចម្លងទៅកាន់កោះដាច់ និងកោះឧកញ៉ាតី

៤. ទេសភាពក្នុងតំបន់ទេសចរណ៍កោះឧកញ៉ាតី





ស្ពានឆ្លងទៅតំបន់កោះឧកញ៉ាតី






សាលាឃុំកោះឧកញ៉ាតី



គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ម៉ាកស៊ី



ផែនទីក្នុងតំបន់កោះទាំងមូល



ប៉ុស្តិ៍ប្រជាការពារក្នុងភូមិ



ការឃោសនាពីការដាំ



ចំការពោត និង ចំការចេក



ចំការអំពៅ និងសណ្ដែក



ចំការចេក និងស្វាយ





ការប្រមូលផលខ្ញី



ការប្រមូលផលត្រាវ



រចនាបទផ្ទះប្រជាជនក្នុងភូមិ




ដំណាំហូបផ្លែខ្នុរ ផ្លែមៀនតាមផ្ទះ




ទេសភាពក្នុងភូមិ




ទិដ្ឋភាពផ្សារកោះឧកញ៉ាតី នាពេលព្រឹក



ទិដ្ឋភាពផ្សារកោះឧកញ៉ាតី នាពេលរសៀល



ការជិះយកកសិផលទៅលក់



ការលក់របស់តិចតួច និង កសិផលនៅតាមផ្ទះ






ការសម្ភាសជាមួយអាជ្ញាធរក្នុងតំបន់



ការសម្ភាសន៍ជាមួយអ្នកគ្រប់គ្រងរមណីយដ្ឋានចំការស្នេហ៍




ការសម្ភាសជាមួយប្រជាជនក្នុងតំបន់









ការសម្ភាសជាមួយទេសចរក្នុងរមណីយដ្ឋានចំការស្នេហ៍







ទេសចរជិះកង់កំសាន្តក្នុងភូមិ



បញ្ហាសំរាម





បញ្ហាផ្លូវនៅតំបន់ចុងកោះ

# ឯកសារពិគ្រោះ

## ឯកសារជាភាសាខ្មែរ


- កម្រងគតិយុត្តិទេសចរណ៍ រៀបចំដោយសាស្ត្រាចារ្យ ស៊ូ គឹមព្រឹទ្ធា ឆ្នាំ២០១៥
- សេចក្តីផ្តើមទេសចរណ៍ រៀបរៀងដោយ បណ្ឌិត ឈុន ពហុ អនុបណ្ឌិត ជា ស៊ីថា ហុង វណ្ណៈ និង សាំង ចន្ទ បោះពុម្ព ថ្ងៃទី០១ តុលា ២០១៤
- ការគ្រប់គ្រងគោលដៅទេសចរណ៍ សាស្ត្រាចារ្យ លោក ហ៊ាន វណ្ណារិន ឆ្នាំសិក្សា ២០១៦-២០១៧
- Tourism development strategic plan 2012-2020
- ការគ្រប់គ្រង និង អភិវឌ្ឍន៍រមណីយដ្ឋានទេសចរណ៍ បណ្ឌិត ឯក វដ្ឋា ~ គឹម ប៊ុនណារ៉ា អនុបណ្ឌិត ឯម ខេឌី ~ នួន សារី (២០១២)
- ការគ្រប់គ្រងសេវាកម្ម សាស្ត្រាចារ្យបណ្ឌិត សួន រ៉ានី (២០១២)
- វិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា-ការអភិវឌ្ឍកសិទេសចរណ៍នៅរមណីយដ្ឋានពិកនិក ស្រុកកំពង់សិលា ខេត្តព្រះសីហនុ (២០១៦)
- អេកូទេសចរណ៍ ចក្ខុវិស័យ និងការអភិវឌ្ឍបណ្ឌិត សួន រ៉ានី ហុង វណ្ណៈ ឈឹម ផាន់ណា


## ឯកសារពីអ៊ីនធើណែត


- (https://en.wikipedia.org/wiki/International_tourism)
- **Tourism Product Definition ~ New Atlantis**
  http://lokatourconsultant.blogspot.com/2013/04/tourism-product-definition.html
- Chinese Academy Agricultural science- 农业旅游发展的国际经验
  http://www.caas.cn/nykjxx/fxyc/237113.shtml (ចូលទស្សនា ថ្ងៃទី ១៤ ឧសភា ២០១៧)
- http://baike.baidu.com/item/%E7%94%9F%E6%80%81%E5%86%9C%E4%B8%9A%E6%97%85%E6%B8%B8 (百度百科：生态农业旅游) [12]
- http://www.farmthailand.com/163 **การท่องเที่ยวเชิงเกษตร (11/09/2013)**
- Sustained growth in international tourism despite challenges
  PR No.: PR 17003 -17 Jan 17 (15-June-2017)
  http://www2.unwto.org/press-release/2017-01-17/sustained-growth-international-tourism-despite-challenges
- UNWTO Commission for Asia and the Pacific meets in Bangladesh
  PR No.: PR 17066 - 18 May 17 (16-Jun-2017)
  http://media.unwto.org/press-release/2017-05-18/unwto-commission-asia-and-pacific-meets-bangladesh

- Agri-tourism Ideas and Resources by *Martha A. Walker, Ph.D., Community Viability Specialist, Virginia Cooperative Extension*
- Model of Creative Tourism Management in Suan Phueng - Veridian E-Journal, Silpakorn University by ปิรันธ์ ชิณโชติ (PirunChinachot) ธีระวัฒน์ จันทึก (Thirawat Chantuk)